ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង
យុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)

# របាយការណ៍

# ការឃ្លាំមើល និងការផ្ដល់ពិន្ទុលើលទ្ធផល
# នៃការបំពេញ/អនុវត្តន៍គោលនយោបាយ
# របស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី២








- វាយតម្លៃលើការបំពេញ/អនុវត្តន៍គោលនយោបាយមានសូចនាករច្បាស់លាស់
- ផ្ដល់ពិន្ទុលើការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល

**ខែកុម្ភៈ ឆ្នាំ២០១៦**

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី២

ឆ្នាំទី២នៃនីតិកាលទី៥ រាជរដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានសម្រេចពេញលេញនូវការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ (៣៧,៥%)នៃ១៦ ចំណុចនៃគោលនយោបាយដែលមានសូនាករច្បាស់លាស់ រួមមានដូចជា៖ ១.កំណើនកំណើនសេដ្ឋកិច្ច ៧%ក្នុងមួយឆ្នាំ ២.ការកាត់បន្ថយភាពក្រីក្រក្នុងអត្រា០១%ក្នុងមួយឆ្នាំ ៣.ការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ៤.ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ៥.គោលដៅនៃចំនួនទេសចរណ៍ពីក្រៅប្រទេស និង៦.ការបង្កើតគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ។

ចំណែកគោលនយោបាយចំនួន០៧រួមមាន ១.ការរក្សាផ្ទៃនៃសាទទឹកសាប, ២.ការចុះបញ្ជីដីធ្លី, ៣.ការកសាងគោលនយោបាយជាតិស្តីពីសិទ្ធិលំនៅស្ថាន, ៤.ប្រជាជនទទួលសេវាទឹកស្អាត, ៥.ពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ, ៦.បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ និង៧.ការនាំចេញអង្ករឲ្យបាន០១លានតោននៅឆ្នាំ២០១៥ ត្រូវបានរាជរដ្ឋាភិបាលបានអនុវត្តន៍ ឬ/និងសម្រេចបានខ្លះ។ ឯគោលនយោបាយចំនួន០៣ រាជរដ្ឋាភិបាលបានអនុវត្តតែមិនអាចសម្រេចបាន ឬបានតិចតួចតាមការសន្យារបស់ខ្លួនមានដូចជា ១.ការរក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ ២.ការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន និង៣.ការកែលម្អផ្លូវលំជនបទ។

ចំពោះការផ្តល់ពិន្ទុសម្រាប់ឆ្នាំទី២លើគោលនយោបាយដែលមិនមានសូចនាករច្បាស់លាស់ មានប្រជាពលរដ្ឋចំនួន៧៩៧នាក់បានចូលរួមផ្តល់ពិន្ទុ ក្នុងនោះប្រមាណ២៦%ពេញចិត្ត ប្រមាណ៦២%ពេញចិត្តខ្លះ និងប្រមាណ១២% មិនពេញចិត្តនឹងលទ្ធផលការបំពេញ/អនុវត្តគោលនយោបាយទាំងនោះ។ បើពិនិត្យពីការផ្តល់ពិន្ទុលើវិស័យនីមួយៗវិញ គេឃើញថា វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងចំណោមប្រជាពលរដ្ឋបានផ្តល់ពិន្ទុ មានប្រជាពលរដ្ឋ ចំនួន២៨%ពេញចិត្ត, ៥៨%ពេញចិត្តខ្លះ និង១៣%មិនពេញចិត្ត។ ចំណែកឯវិស័យពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយត្រូវបានផ្តល់ពិន្ទុដោយប្រជាពលរដ្ឋចំនួន២៦%ពេញចិត្ត, ៦០%ពេញចិត្តខ្លះ និង១៣%មិនពេញចិត្ត។ វិស័យការអភិវឌ្ឍន៍សេដ្ឋកិច្ចវិញក៏ត្រូវបានប្រជាពលរដ្ឋចំនួន២២%ពេញចិត្ត, ៦៦%ពេញចិត្តខ្លះ និង១០%មិនពេញចិត្ត។ ជាមួយគ្នានោះដែរ វិស័យការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ចត្រូវបានប្រជាពលរដ្ឋចំនួន២៧% ពេញចិត្ត, ៦២% ពេញចិត្តខ្លះ និង ៩% មិនពេញចិត្ត។

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

បើប្រៀបធៀបលទ្ធផលផ្តល់ពិន្ទុឆ្នាំ២០១៤ និង២០១៥នៅរាជធានីភ្នំពេញ ដែលមានវិធីសាស្រ្តឲ្យអ្នកចូលរួមផ្តល់ពិន្ទុដូចគ្នានោះ ក្នុងឆ្នាំ២០១៥ ចំនួនប្រជាពលរដ្ឋមិនពេញចិត្ត និងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលធ្លាក់ចុះពី៥៥% នៅឆ្នាំ២០១៤ មកត្រឹម៥០% ផ្ទុយមកវិញចំនួនប្រជាពលរដ្ឋពេញចិត្តខ្លះកើនឡើងពី៣៥% ទៅ ៤០%។ ដូចនេះ ប្រជាពលរដ្ឋដែលផ្តល់ពិន្ទុនៅរាជធានីភ្នំពេញចំនួន៥% បានប្រែលប្រួលពីមិនពេញចិត្ត ទៅពេញចិត្តខ្លះ។ ខណៈដែលចំនួនប្រជាពលរដ្ឋពេញចិត្តនឹងការអនុវត្តន៍គោលនយោបាយទាំងនោះ មិនមានការប្រែប្រួលនោះទេ នេះបើប្រៀបធៀបការផ្តល់ពិន្ទុឆ្នាំ២០១៤ និងឆ្នាំ២០១៥។

បើពិនិត្យមើលថវិកាជាតិដែលគ្រោងចំណាយឆ្នាំ២០១៥ ចំនួន៣.៧៥៨លានដុល្លារសហរដ្ឋអាមេរិកវិញ រាជរដ្ឋាភិបាលគ្រោងចំណាយលើវិស័យសង្គមកិច្ចចំនួន២៧,៨២%, វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈចំនួន ១៦,២៤%, វិស័យសេដ្ឋកិច្ចចំនួន២៨,៥៧% និងវិស័យរដ្ឋបាលទូទៅចំនួន១១,១៨% នៃថវិកាជាតិសរុបដែលរួមបញ្ចូលទាំងថវិកាមិនទាន់បែងចែង។ ហើយការចំណាយលើវិស័យសេដ្ឋកិច្ច គឺច្រើនជាងគេ បើធៀបនឹងវិស័យបីផ្សេងទៀត។

ចំណែកការអនុវត្តន៍គោលនយោបាយការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈត្រូវបានប្រជាពលរដ្ឋមិនពេញចិត្តច្រើនជាងគេរហូតដល់ប្រមាណ១៣% ក្នុងចំណោមគោលនយោបាយទាំងអស់។ រាជរដ្ឋាភិបាលបានគ្រោងចំណាយថវិកាជាតិច្រើនមានចំនួន១៦,២៤%លំដាប់ទី៣ ចំពោះការអនុវត្តន៍គោលយោបាយវិស័យនេះ។

សម្រាប់ឆ្នាំទី២នេះ ចំនួនសមាជិករាជរដ្ឋាភិបាលដែលត្រូវបានចែងក្នុងច្បាប់ ស្តីការបង្កើត និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្រ្តី មិនមានការប្រែប្រួលនោះទេ។ ប៉ុន្តែគេក៏នៅតែឃើញមានការកើនឡើងនូវអនុរដ្ឋលេខាធិការចំនួន២៨រូបនៅតាមបណ្តាក្រសួងចំនួន១៥ និងទីប្រឹក្សារាជរដ្ឋាភិបាលចំនួន៤៣រូបដែលមានឋានៈស្មើនឹងសមាជិករាជរដ្ឋាភិបាល ខណៈពេលដែលមានការបញ្ចប់ដំណែងចំនួន០៥រូបតែប៉ុណ្ណោះ (០៣រូបជាអនុរដ្ឋលេខាធិការ និង២រូបជាទីប្រឹក្សារាជរដ្ឋាភិបាល)។

ក្នុងរយៈពេល០៩ខែ នៃឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យចំនួន១.២២២អនុក្រឹត្យ និងប្រកាសចំនួន៧៥ប្រកាស។ ប្រមាណ៥%នៃអនុក្រឹត្យទាំងនោះ អំពីការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ការផ្ទេរតណទានថវិកា និងការកាត់ផ្ទៃដីចេញពីគម្របព្រៃឈើ និងគម្រោងសម្បទានសេដ្ឋកិច្ច។ ចំណែកអនុក្រឹត្យផ្សេងទៀត អំពីការជូនមេដាយ និងតែងតាំង ផ្ទេរភារកិច្ចមន្រ្តីរាជការជាដើម។

ខុមហ្វ្រែលបានរៀបចំរបាយការណ៍ ស្តីពីការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី២ ផ្អែកលើការវិភាគព័ត៌មាន ឬទិន្នន័យដែលមានស្រាប់មកពី ប្រព័ន្ធផ្សព្វផ្សាយរបាយការណ៍បឋមរបស់អង្គការជាតិ និងអន្តរជាតិ សារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងស្ថាប័នជាតិ និងអន្តរជាតិផ្សេងៗ ដើម្បីវាយតម្លៃលើការបំពេញ/អនុវត្តន៍គោលនយោបាយមានសូចនាករច្បាស់លាស់។ សម្រាប់មួយផ្នែកផ្សេងទៀតគឺការផ្តល់ពិន្ទុដោយប្រជាពលរដ្ឋ តាមរយៈវេទិកាម្ចាស់ឆ្នោតត្រូវបានរៀបចំឡើង នៅក្នុងរាជ/ធានីខេត្ត

ចំនួន២៤ ដែលមានប្រជាពលរដ្ឋចូលរួមប្រមាណ៧៩៧នាក់។ ប្រជាពលរដ្ឋផ្តល់ពិន្ទុចំនួនពីរលើក[1] លើការបំពេញ/អនុវត្តន៍គោលនយោបាយ ដែលមិនមានសូចនាករច្បាស់លាស់ចំនួន៣៣ចំណុចរបស់រាជរដ្ឋាភិបាល ដែលខុមហ្វ្រែល បានរកឃើញ នៅក្នុងកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នេះ។

កម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥បានបែងចែងជា០៤វិស័យធំៗ រួមមាន៖១. ការការពារជាតិសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ២. ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ ៣.ការអភិវឌ្ឍសេដ្ឋកិច្ច និង ៤. ការអភិវឌ្ឍវិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច។

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖*

| | | |
|---|---|---|
| ១.លោក **គល់ បញ្ញា** | នាយកប្រតិបត្តិ | ០១២ ៩៤ ២០ ១៧ |
| ២.លោក **កន សាវាង្ស** | មន្ត្រីជាន់ខ្ពស់ នៃកម្មវិធីផ្នែកអង្កេត | ០១១ ៨៨ ៤៨ ៤០ |
| ៣.លោក **សៀន ប៊ុនរិទ្ធ** | មន្ត្រីផ្នែកអង្កេត | ០៨៩ ២១ ២១ ១០ |

**បេសកកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/**ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

[1] លើកទី១ផ្អែកលើព័ត៌មាន ឬចំណេះដឹងរបស់ប្រជាពលរដ្ឋផ្ទាល់, លើកទីពីរផ្អែកលើព័ត៌មាន ឬចំណេះដឹងរបស់ប្រជាពលរដ្ឋ រួមទាំងព័ត៌មានដែលបានផ្តល់ជូនដោយវាគ្មិន

Phnom Penh, 23th February 2016

# Press Release

## 'Assessment and Voters' Score Card on the Second Year Fulfillment of Political Platform of the Fifth Mandate of Government'

During the second year of the fifth mandate of the National Assembly (NA), the Royal Government of Cambodia (RGC) led by the Cambodian People's Party (CPP) has fully fulfilled 6 (37.5%) of 16 political platforms with precise indicators. They are: annual 7% economic growth, annual 1% poverty reduction, halting of economic land concessions, transportation policy creation, an increase in foreign tourists, and the creation of a national policy related to jobs and careers.

While another seven political platforms related to water for family fishing, land title registration, national housing policy design, people's access to running water, village electricity supplies, secondary school construction in all communes, and one million tons of rice exports in 2015, have only been partly fulfilled or/and implemented by the RGC. Three political platform promises have been implemented, but when compared to the previous performance the RGC is unlikely to fulfill them. For example, these include maintenance of existing forest cover, and implementation of retirement allowance in the private sector and improvement of rural roads.

For the second year, voters' score card on the fulfillment of political platform with imprecise indicators, 26% of participants are satisfied, 62% of them are partly satisfied, while 12% are not satisfied. Looking at the score of each of the four sectors, it can be shown that the first sector on national defence security and public order is satisfied by 28% of participants, partly satisfied by 58% and not satisfied by 13%.The second sector on improvement of public administration, decentralization and deconcentration, law and justice, and anti-corruption activities is satisfied by 26% of participants, partly satisfied by 60% and not satisfied by 13%. The third sector on economic development is satisfied by 22% of participants, partly satisfied by 66% and not satisfied by 10%. And the last sector on development of education, health, labor, culture and social affairs is satisfied by 27% of participants, partly satisfied by 62% and not satisfied by 9% of them.

To compare with the score card results in Phnom Penh in 2014,where the method of scoring is the same to 2015, in 2015 the number of participants dissatisfied decreases from 55% in 2014 to 50%, while the number of participants partly satisfied increases from 35% to 40%. As the result 5% of participants in Phnom Penh turn from dissatisfied to partly satisfied in 2015, while the percentage of participants satisfied with the fulfillment of RGC remains the same.

Looking at the 2015 national budget, the RGC planned to spend US $3,758 million 16% of which is not allocated. The RGC planned to allocate 27.82% of the budget to social affairs, 16.24% to

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

national defence, security and public order, 28.57% to the economic sector, and 11.18% to general administration. Among the four sectors, the expenditure on the economic sector is the highest.

It is noted that fulfillment of national defence, security and public order sector is the most not-satisfied of the four sectors. 13% of participants are not satisfied with the fulfillment, while the RGC planned to spend 16.24% of national budget which is the third highest amount.

By the second year of the fifth mandate, the number of cabinet members categorized in law on preparation and functioning of cabinet remains the same when compared to the previous year. However, the number of undersecretary of state has increased by 28 in 15 ministries, and Royal Government of Cambodia's advisor ranked as members of the cabinet has increased by 43, while only five had been fired (three undersecretaries of state and two RGC's advisors)

By September 2015, RGC had issued 1,222 sub degrees and 75 announcements. Around 05% of sub degrees concerned the transferring of public property to the private property of state, transferring of budget and taking land out from area of forest cover and economic concessions. The reamainder concerned the awarding of of medals commendations and the promotion of government officials.

The report on the Assessment and Voters' Score Card on the Second Year Fulfillment of the Political Platform of the Fifth Mandate of Government compiled by COMFREL is based on analysis of existing primary data from NGO, INGO, press agencies and national institutions for making an assessment on the fulfillment of political platforms with precise indicator. For an assessment on fulfillment of the political platform with imprecise indicators, 24 voters' score card forums were conducted in 24 capital/provinces with approximately 797 participants. 33 points with imprecise indicator found in political platform were scored twice[1].

The political platform of the fifth mandate government is categorized into four main sectors: 1: National defence, security and public order, 2: Improvement of public administration, decentralization and deconcentration, law and justice, and anti-corruption activities, 3: Development of economics and 4: Development of education, health, labor, culture and social affairs.

***For Further information please contact:***


1. ***Mr. Koul Panha*** Executive Director 012 94 20 17
2. ***Mr. Korn Savang*** Senior Program Officer, Monitoring Unit 01188 48 40
3. ***Mr. Sean Bunrith*** Monitoring Officer 089 21 2110


**បេសកកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/**ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

[1] Political platforms with imprecise indicator is first scored with participant's knowledge and second scored with not only the their knowledge but also information of fulfillment of them from the speaker.

# របាយការណ៍

## ស្តីពី

## ការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផល
## នៃការបំពេញ/អនុវត្តន៍គោលនយោបាយ
## របស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី២

ខែកុម្ភៈ ឆ្នាំ ២០១៦

**មាតិកា**

I. **ខ្លឹមសារសង្ខេប** ........ 1

II. **សេចក្តីផ្តើម** ........ 2

III. **ការប្រែប្រួលសមាសភាពសមាជិករាជរដ្ឋាភិបាល** ........ 2

IV. **អនុក្រឹត្យ និងប្រកាសរបស់រាជរដ្ឋាភិបាលឆ្នាំ២០១៥** ........ 4

V. **ការរកឃើញ និងការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយសម្រាប់ឆ្នាំទី១** ........ 4

1. **ការបំពេញ/អនុវត្តន៍គោលនយោបាយមានសូចនាករច្បាស់លាស់** ........ 5

*០១. ខិតខំសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧% ក្នុងមួយឆ្នាំ ដើម្បីធ្វើឲ្យកម្ពុជាអាចចាកចេញផុតពីប្រទេសមានចំណូលទាប ឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិតទាបយ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។* ........ 5

*០២. សម្រេចឲ្យបានគោលដៅកាត់បន្ថយអត្រានៃភាពក្រីក្រជាង១% ក្នុងមួយឆ្នាំ។* ........ 5

*០៣. បន្តខិតខំសម្រេចនូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឲ្យបាន១លានតោននៅឆ្នាំ២០១៥ សំដៅប្រែក្លាយកម្ពុជាទៅជាប្រទេសផលិតស្បៀងនាំមុខមួយ នៅលើពិភពលោក។* ........ 7

*០៤. រក្សាផ្ទៃនេសាទទឹកសាបសម្រាប់ប្រជាជន ធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព។* ........ 8

*០៥. រក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ ដោយបង្កើនការការពារធនធានព្រៃឈើ ពិសេសការពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីព្រៃឈើ ការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ ជំរុញការដាំដើមឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើនៅលើមូលដ្ឋានធានាវិរភាព និងប្រសិទ្ធភាពគ្រប់គ្រង។* ........ 10

*០៦. បញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច។* ........ 13

*០៧. សម្រេចឲ្យបាន១០០% នូវការចុះបញ្ជីដីតាមផែនការនៃបទបញ្ជាលេខ០១ របស់រាជរដ្ឋាភិបាលជិត២លានហិចតា នៅរវាងដើមឆ្នាំ២០១៤ ក្នុងក្របខណ្ឌនៃការអនុវត្តន៍ «នយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី» និងសម្រេចឲ្យបាន៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដីដែលត្រូវចុះបញ្ជីសរុប៦ ទៅ៧លានក្បាលដីនៅទូទាំងប្រទេស។* ........ 15

*០៨. កសាងគោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅស្ថាន ដើម្បីដោះស្រាយលំនៅស្ថានជូនប្រជាជនក្រីក្រ សម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពថ្លៃថ្នូរ។* ........ 16

*០៩. កែលម្អផ្លូវលំជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហម ទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងឲ្យបានពី៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំ តាមស្តង់ដារឯកភាពជាតិមួយ។* ........ 18

*១០. រៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ជាពិសេសរាជធានីភ្នំពេញសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធ កសាងមធ្យោបាយដឹងជញ្ជូន ដើម្បីរួមជាប្រយោជន៍សម្រាប់ដោះស្រាយបញ្ហាការកកស្ទះចរាចរណ៍ និងពង្រឹងសណ្តាប់ធ្នាប់ចរាចរណ៍ទីក្រុង។* ........ 19

*១១. ដល់ឆ្នាំ២០១៨ ប្រជាជនចំនួន៨៥% ដែលរស់នៅរាជធានីខេត្ត និងប្រជាជនចំនួន៦០% ដែលរស់នៅតាមបណ្ដាឃុំ បានទទួលសេវាទឹកស្អាតដែលមានគុណភាពល្អ និងថ្លៃសមរម្យប្រើប្រាស់។*................20
*១២. ពីឆ្នាំ២០១៣ ដល់២០១៨ គឺពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្ដាញជាតិឲ្យដល់ភូមិចំនួន៨០% នៃចំនួនភូមិទាំងអស់។*................21
*១៣. ខិតខំសម្រេចគោលដៅទទួលទេសចរណ៍ពីក្រៅប្រទេសនៅឆ្នាំ២០១៥ ប្រមាណ៤,៥លាននាក់ឆ្នាំ២០១៨កើនដល់ ៦,១លាននាក់ រួមជាមួយទេសចរណ៍ក្នុងស្រុកប្រមាណ១០,៥លាននាក់។*................23
*១៤. បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ (ឃុំមួយអនុវិទ្យាល័យមួយ) ដែលនៅមិនទាន់មានអនុវិទ្យាល័យ។*................24
*១៥. រៀបចំគោលនយោបាយជាតិ ស្ដីពីមុខរបរ និងការងារស្របទៅនឹងការវិវឌ្ឍន៍នៃសង្គម-សេដ្ឋកិច្ច។*...25
*១៦. ការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍ សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជនឲ្យទទួលបានរបបប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការដែរ ចាប់ពីឆ្នាំ ២០១៥។*................26
2. **ការផ្ដល់ពិន្ទុការបំពេញ/អនុវត្តន៍គោលនយោបាយ**................26
ក. វិស័យទី១៖ការពារជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ................27
ខ. វិស័យទី២៖ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ................27
ទិន្នន័យខាងលើបង្ហាញថា មានប្រជាពលរដ្ឋភាគច្រើនជាងគេប្រមាណ៣១%ពេញចិត្តខ្លះ ចំពោះការបំពេញ/អនុវត្តន៍ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ។ ខណៈដែលភាគរយនៃការពេញចិត្តមធ្យម ឬពាក់កណ្ដាលមានចំនួនច្រើនបន្ទាប់ គឺប្រមាណ២៩%។ បើមើលពីកម្រិតនៃការពេញចិត្តជាមធ្យមវិញ មានកម្រិតពេញចិត្តខ្លះតែប៉ុណ្ណោះពោលគឺ Mean=២.២៧ សម្រាប់ការផ្ដល់ពិន្ទុលើកទី១ និង Mean=២,១៤ សម្រាប់ការផ្ដល់ពិន្ទុលើកទី២។28
គ. វិស័យទី3៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ច................28
ឃ. វិស័យទី4៖ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច................29
ង. គោលនយោបាយទាំង៤វិស័យ៖................29
ទំនាក់ទំនងរវាងខេត្ត និងការផ្ដល់ពិន្ទុ៖................30
ការប្រៀបធៀបលទ្ធផលឆ្នាំ២០១៤ និង ២០១៥ នៅរាជធានីភ្នំពេញ................30
................31
ច. លទ្ធផលជាមធ្យមនៃការពេញចិត្តចំពោះការអនុវត្តន៍/បំពេញគោលនយោបាយ របស់រាជរដ្ឋាភិបាល៖.31
VI. **សេចក្ដីសន្និដ្ឋាន**................33
- **វិធីសាស្ត្រ និងទំហំនៃរបាយការណ៍**................34
- **លក្ខណៈគោលនយោបាយ និងគោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥( សង្ខេប )**35
- **តារាងលទ្ធផលនៃការផ្ដល់ពិន្ទុតាមខេត្ត/រាជធានី**................68

ក. វិស័យទី១៖ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ 68

ខ. វិស័យទី២៖ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពំពើពុករលួយ 69

គ. វិស័យទី3៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ច 70

ឃ. វិស័យទី4៖ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច 71

ង. គោលនយោបាយទាំង៤វិស័យ៖ 72

- **រូបភាពសកម្មភាពវេទិកាម្ចាស់ឆ្នោត** 73
- **តារាងព័ត៌មានទំនាក់ទំនងរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនីតិកាលទី៥** 77
- **អត្ថបទសារព័ត៌មានចុះផ្សាយអំពីរបាយការណ៍៖** 85

# I. ខ្លឹមសារសង្ខេប

រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥ ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាបាន និងកំពុងអនុវត្ត គោលនយោបាយរបស់ខ្លួនបានរយៈពេល២ឆ្នាំមកហើយ។ រដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយរបស់ខ្លួនដែលមាន០៤វិស័យធំៗ មានដូចជា៖ ១. ការការពារជាតិសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២. ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ ៣. ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង៤. ការអភិវឌ្ឍន៍វិស័យអប់រំសុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច។ ដើម្បីអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលក៏បានបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។

ក្នុងគោលបំណងបង្កើនតម្លាភាព និងជំរុញឱ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវខ្ពស់ ខុមហ្វ្រែលបានធ្វើការអង្កេត និងលើកទឹកចិត្តឱ្យម្ចាស់ឆ្នោត វាយតម្លៃលើការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។ ដោយសិក្សា និងវិភាគលើរបាយការណ៍ព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធ និងផ្តល់ឱកាសឲ្យប្រជាពលរដ្ឋផ្តល់ពិន្ទុលើការអនុវត្តន៍គោលនយោបាយនោះ។

សម្រាប់ឆ្នាំទី២នេះ ចំនួនសមាជិករាជរដ្ឋាភិបាលដែលត្រូវបានចែងក្នុងច្បាប់ ស្តីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីមិនមានការប្រែប្រួលនោះទេ។ ប៉ុន្តែគេក៏នៅតែឃើញមានការកើនឡើងនូវអនុរដ្ឋលេខាធិការចំនួន២៨រូប នៅតាមបណ្តាក្រសួងចំនួន១៥ និងទីប្រឹក្សារាជរដ្ឋាភិបាលចំនួន៤៣រូប ដែលមានឋានៈស្មើនឹងសមាជិករាជរដ្ឋាភិបាល ខណៈពេលដែលមានការបញ្ចប់តំណែងចំនួន០៥រូបតែប៉ុណ្ណោះ (០៣រូប ជាអនុរដ្ឋលេខាធិការ និង២រូបជាទីប្រឹក្សារាជរដ្ឋាភិបាល)។

ក្នុងរយៈពេល០៩ខែនៃឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យចំនួន១.២២២ និងប្រកាសចំនួន៧៥។ ប្រមាណ៥%នៃអនុក្រឹត្យទាំងនោះ ស្តីអំពីការធ្វើអនុបយោគទ្រព្យសម្បត្តិសាធាណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ការផ្ទេរតណទានថវិកា និងការកាត់ផ្ទៃដីចេញពីគម្របព្រៃឈើ និងគម្រោងសម្បទានសេដ្ឋកិច្ច។ ចំណែកអនុក្រឹត្យផ្សេងទៀត ស្តីអំពីការជូនមេដាយ និងតែងតាំង ផ្ទេរភារកិច្ចមន្ត្រីរាជការជាដើម។

សម្រាប់ឆ្នាំទី២ រាជរដ្ឋាភិបាលត្រូវបានសភាអនុម័តឲ្យគ្រោងចំណាយថវិកាប្រមាណ៣៧៥៨លានដុល្លារសហរដ្ឋអាមេរិក។ ថវិកាប្រមាណ១៦% ស្មើប្រមាណ៦១០លានដុល្លារសហរដ្ឋអាមេរិកត្រូវបានគ្រោងចំណាយឲ្យទៅក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ។ បើប្រៀបធៀបជាមួយឆ្នាំ២០១៤ វិស័យអប់រំត្រូវបានបន្ថែមថវិកាប្រមាណជិត១០០លានដុល្លារអាមេរិក។[1] អ្វីដែលគួរឲ្យកត់សម្គាល់មួយទៀតនោះ ថវិកាថ្នាក់ជាតិគ្រោងចំណាយមិនទាន់បែងចែងមានចំនួន១៦%នៅឆ្នាំ២០១៥ ប៉ុន្តែឆ្នាំ២០១៤ មានរហូតដល់ប្រមាណ៤៦%។

ក្នុងឆ្នាំទី២ រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥ ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាដែលគ្រោងចំណាថវិកាថ្នាក់ជាតិប្រមាណ៣.៧៥៨លានដុល្លារសហរដ្ឋអាមេរិក បានសម្រេចការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ចំណុច(៣៧,៥%) និងសម្រេចបានខ្លះចំនួន៧ចំណុច។ ខណៈដែលគោលនយោបាយចំនួន០៣ រាជរដ្ឋាភិបាលបានអនុវត្តតែមិនអាចសម្រេចបានតាមការសន្យារបស់ខ្លួន។ ចំពោះលទ្ធផលការបំពេញ/អនុវត្តន៍គោលនយោបាយ មិនមានសូចនាករច្បាស់លាស់វិញ ត្រូវបានប្រជាពលរដ្ឋចំនួនប្រមាណ២៦% ពេញចិត្តប្រមាណ៦២%ពេញចិត្តខ្លះ ប៉ុន្តែប្រជាពលរដ្ឋប្រមាណ១២% មិនពេញចិត្តនឹងលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយទាំងនោះ។

[1] https://www.cambodiadaily.com/news/cpp-lawmakers-push-through-3-8-billion-national-budget-73314/

## II. សេចក្តីផ្តើម

គិតត្រឹមឆ្នាំ២០១៥ រាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាបាន នឹងកំពុងបន្តអនុវត្ត គោលនយោបាយរបស់ខ្លួនមិនតិចជាងរយៈពេលពីរឆ្នាំនោះទេ។ ឆ្នាំ២០១៥ គឺជាឆ្នាំទី២នៃការអនុវត្តន៍/បំពេញ និងឃ្លាំមើល និងវាយតម្លៃគោលនយោបាយទាំងបួនវិស័យនេះ។ ក្នុងឆ្នាំទី១(ខែកញ្ញា ឆ្នាំ២០១៣ ដល់ឆ្នាំ២០១៤) ចំពោះគោលនយោបានមានសូចនាករច្បាស់លាស់ចំនួន១៦ចំណុច រាជរដ្ឋាភិបាលបានសម្រេចពេញលេញនូវការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ (៣៧,៥%) រួមមានដូចជា៖ កំណើនសេដ្ឋកិច្ច៧%ក្នុងមួយឆ្នាំ ការកាត់បន្ថយភាពក្រីក្រក្នុងអត្រា០១%ក្នុងមួយឆ្នាំ ការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ចការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង និងគោលដៅនៃចំនួនទេសចរណ៍ពីក្រៅប្រទេស។ ចំណែកគោលនយោបាយចំនួន០៧ រួមមានការរក្សាផ្ទៃនៃសាទទឹកសាប ការចុះបញ្ជីដីធ្លី ការកសាងគោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅស្ថាន ប្រជាជនទទួលសេវាទឹកស្អាត ពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ និងការរៀបចំគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារត្រូវបានអនុវត្ត ឬ/និងសម្រេចបានខ្លះ។ ឯគោលនយោបាយចំនួន០៣ រាជរដ្ឋាភិបាលបានអនុវត្ត តែមិនអាចសម្រេចបានតាមការសន្យារបស់ខ្លួន។ គោលនយោបាយទាំងបីនោះមានដូចជា គោលនយោបាយនាំចេញអង្ករឲ្យបាន១លានតោន នៅឆ្នាំ២០១៥ ការរក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ និងការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន។

ចំពោះការផ្តល់ពិន្ទុលើការអនុវត្តន៍/បំពេញគោលនយោបាយ ដែលមិនមានសូចនាករច្បាស់លាស់ចំនួន ៣៣ចំណុចវិញ (ករណីសិក្សានៅរាជធានីភ្នំពេញ និងខេត្តសៀមរាប) មានប្រជាពលរដ្ឋចំនួនភាគច្រើននៃ ៤៤,៤% ពេញចិត្តខ្លះចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយ ប៉ុន្តែប្រជាពលរដ្ឋរហូតដល់៥៥,៦% មិនពេញចិត្តនឹងការអនុវត្តន៍គោលនយោបាយទាំងនោះ នៅក្នុងឆ្នាំទី១កន្លងទៅនេះ។

ដើម្បីបន្តបង្កើនតម្លាភាព និងជំរុញឱ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវនូវអ្វីដែលបានសន្យា ខុមហ្វ្រែលបានធ្វើការសង្កេត ផ្តល់មធ្យោបាយ និងលើកទឹកចិត្តឱ្យម្ចាស់ឆ្នោតវាយតម្លៃលើការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។

សម្រាប់ការសង្កេត ខុមហ្វ្រែលបានសិក្សាលើរបាយការណ៍ព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធនឹងគោលនយោបាយដែលមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល។ ដោយឡែក ការផ្តល់ពិន្ទុវិញ ខុមហ្វ្រែលរៀបចំទម្រង់វាយតម្លៃដាក់ពិន្ទុដោយម្ចាស់ឆ្នោតទៅលើចំណុចនៃគោលនយោបាយ តាមរយៈវេទិកានៅតាមខេត្តនានា និងរាជធានីភ្នំពេញ ដោយប្រើប្រាស់វិធីសាស្ត្រពិភាក្សាជាក្រុមដែលអ្នកចូលរួមធ្វើការផ្តល់ពិន្ទុចំនួនពីរលើក។ ការផ្តល់ពិន្ទុលើកទី១ ធ្វើឡើងមុនពេលកិច្ចពិភាក្សា ហើយការផ្តល់ពិន្ទុលើកទី២ ធ្វើឡើងនៅក្រោយពេលពិភាក្សា និងវាគ្មិនចែករំលែក វិភាគលើទិន្នន័យបឋមរបស់ស្ថាប័ន ឬអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធនឹងវិស័យទាំងនោះ។

## III. ការប្រែប្រួលសមាសភាពសមាជិករាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនីតិកាលទី៥ មានក្រសួងចំនួន២៨ និងរដ្ឋលេខាធិកាដ្ឋានចំនួនមួយ។ មាត្រា៤ វាក្យខ័ណ្ឌទី១ មាត្រា៤នៃច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចែងថា សមាជិករាជរដ្ឋាភិបាលរួមមាន នាយករដ្ឋមន្ត្រី ឧបនាយរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។ រាជរដ្ឋាភិបាលនេះនៅតែមានចំនួន

ច្រើន បើប្រៀបធៀបជាមួយបណ្តាប្រទេសនៅក្នុងតំបន់។ ប្រៀបធៀបជាមួយឆ្នាំទី១ គិតត្រឹមពាក់កណ្តាលខែកញ្ញាឆ្នាំ២០១៥ (ចំនួន) សមាជិករាជរដ្ឋាភិបាលមិនមានការប្រែប្រួលឡើយ គឺមានចំនួន២៤៨រូប ប៉ុន្តែគេសង្កេតឃើញមានការកើនឡើងនូវអនុរដ្ឋលេខាធិការចំនួន២៨រូប (ស្រីចំនួន០១រូប) តាមបណ្តាក្រសួងមួយចំនួន ខណៈដែលមានអនុរដ្ឋលេខាធិការចំនួន០៣រូប បានបញ្ចប់តំណែងដោយសារលាលែង និងទទួលមរណភាព។ ចំនួនទីប្រឹក្សារាជរដ្ឋាភិបាលក៏មានការកើនឡើងចំនួន៤៣ (ស្រីចំនួន០១រូប) ចំណែកឯទីប្រឹក្សាដែលបានបញ្ចប់តំណែងមានចំនួន២ផងដែរ ក្នុងឆ្នាំទី២នៃរាជរដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា។ នេះមិនទាន់រាប់បញ្ចូលដល់ការកើនឡើងចំនួនទីប្រឹក្សានាយករដ្ឋមន្ត្រី ក្រសួង និងថ្នាក់ដឹកនាំក្រសួងផ្សេងៗដែលត្រូវបានតែងតាំងមានឋានៈស្មើរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនោះទេ។ បើពិនិត្យពីក្របខ័ណ្ឌច្បាប់វិញ ការកើនឡើងនេះ គឺដោយសារតែគ្មានបទបញ្ញត្តិនៃច្បាប់ចែងកំណត់អំពីចំនួនអនុរដ្ឋលេខាធិការ និងទីប្រឹក្សារាជរដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល ឬ/និងនាយករដ្ឋមន្ត្រី។

ចំនួនកើនឡើងចំនួនអនុរដ្ឋលេខាធិការតាមក្រសួងនានា៖

| ល.រ | ក្រសួង | ចំនួនកើនឡើង |
|---|---|---|
| ០១ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០៣ |
| ០២ | ក្រសួងអភិវឌ្ឍន៍ជនបទ | ០១ |
| ០៣ | ក្រសួងមុខងារសាធារណៈ | ០២ |
| ០៤ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ០២ |
| ០៥ | ក្រសួងយុត្តិធម៌ | ០១ |
| ០៦ | ក្រសួងការពារជាតិ | ០១ |
| ០៧ | ក្រសួងមហាផ្ទៃ | ០៧ |
| ០៨ | ក្រសួងព័ត៌មាន | ០៣ |
| ០៩ | ក្រសួងទេសចរណ៍ | ០១ |
| ១០ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ០១ |
| ១១ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា | ០១ |
| ១២ | ក្រសួងរ៉ែ និងថាមពល | ០១ |
| ១៣ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ |
| ១៤ | ក្រសួងអប់រំ យុវជន និងកីឡា | ០២ |
| ១៥ | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | ០១ (ស្រី) |
| | ចំនួនសរុប | ២៨ |

ចំនួនកើនឡើងទីប្រឹក្សារាជរដ្ឋាភិបាល ដែលមានឋានៈស្មើឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ៖

| ល.រ | ទីប្រឹក្សារាជរដ្ឋាភិបាលឋានៈស្មើ៖ | ចំនួនកើនឡើង |
|---|---|---|
| ១ | ឧបនាយរដ្ឋមន្ត្រី | ០១ |
| ២ | រដ្ឋមន្ត្រី | ១២ (ស្រី ០១) |
| ៣ | រដ្ឋលេខាធិការ | ១១ |
| ៤ | អនុរដ្ឋលេខាធិការ | ១៩ |
| | ចំនួនសរុប | ៤៣ |

## IV. អនុក្រឹត្យ និងប្រកាសរបស់រាជរដ្ឋាភិបាលឆ្នាំ២០១៥

ក្នុងឆ្នាំ២០១៥ គិតត្រឹមពាក់កណ្តាលខែកញ្ញា រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាបានចេញអនុក្រឹត្យចំនួន១.២២២អនុក្រឹត្យ ដែលភាគច្រើននៃអនុក្រឹត្យទាំងនោះ អំពីការជូនមេដាយ និងតែងតាំង ផ្ទេរភារកិច្ចមន្ត្រីរាជការ។ ក្នុងចំណោមអនុក្រឹត្យទាំងនោះ គេពិនិត្យឃើញមានអនុក្រឹត្យចំនួន៥%ភាគរយ អំពីការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ការផ្ទេរឥណទានថវិកា និងការកាត់ផ្ទៃដីចេញពីគម្របព្រៃឈើ និងគម្រោងសម្បទានសេដ្ឋកិច្ចជាដើម។ ចំណែកឯប្រកាសវិញ ក្នុងរយៈពេលដូចគ្នានេះ រាជរដ្ឋាភិបាលបានចេញប្រកាសចំនួន៧៥ប្រកាស។

| **ល.រ** | **ប្រភេទអនុក្រឹត្យ** | **ចំនួន** | **គិតជា** % |
|---|---|---|---|
| ១ | អនុក្រឹត្យស្តីពីអនុបយោគ | ០៩ | ០,៧៣% |
| ២ | អនុក្រឹត្យ ស្តីពីការផ្ទេរឥណទានថវិកា | ៤២ | ៣,៤៣% |
| ៣ | អនុក្រឹត្យ ស្តីពីការកាត់ផ្ទៃដី | ១១ | ០,៩០% |
| ៤ | អនុក្រឹត្យផ្សេងៗ | ១.១១៦ | ៩៤,៩២% |
| អនុក្រឹត្យសរុប | | ១.២២២ | ១០០% |

## V. ការរកឃើញ និងការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយសម្រាប់ឆ្នាំទី១

| ល.រ | វិស័យចំណាយថវិកា | គម្រោងថវិកា (ឯកតាលានរៀល) | ជាលានដុល្លារសហរដ្ឋអាមេរិក (១$= 4000៛) | គិតជាភាគរយ (%) |
|---|---|---|---|---|
| ១ | វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | 2,441,060.50 | 610.27 | 16.24 % |
| ២ | វិស័យរដ្ឋបាលទូទៅ | 1,681,092.40 | 420.27 | 11.18 % |
| ៣ | វិស័យសេដ្ឋកិច្ច | 4,295,133.50 | 1,073.78 | 28.57 % |
| ៤ | វិស័យសង្គមកិច្ច | 4,182,645.60 | 1,045.66 | 27.82 % |
| ៥ | ចំណាយមិនទាន់បែងចែក | 2,435,297.00 | 608.82 | 16.20 % |
| ៦ | ចំណាយសរុបរួម | 15,035,229.00 | 3,758.81 | 100.00 % |

សម្រាប់ឆ្នាំទី២ នៃនីតិកាលទី៥នៃរដ្ឋសភា ច្បាប់ស្តីពីហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងឆ្នាំ២០១៥ ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ដោយមានតែតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជាចំនួន៦៥រូបដែលបានបោះឆ្នោតគាំទ្រ។ មាត្រា២នៃច្បាប់នេះបានបញ្ញត្តិថា ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ គឺមានចំនួនប្រមាណ៣៧៥៨លានដុល្លារសហរដ្ឋអាមេរិក។ នេះមានន័យថា រាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា នឹងបន្តអនុវត្តគោលនយោបាយរបស់ខ្លួនក្នុងឆ្នាំទី២ ដោយប្រើប្រាស់ខ្ទង់ថវិកាដូចមានចែងក្នុងមាត្រា២នៃច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។ ថវិការប្រមាណ១៦% ស្មើប្រមាណ៦១០លានដុល្លារសហរដ្ឋអាមេរិក ត្រូវបានគ្រោងចំណាយឲ្យទៅក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ។ បើប្រៀបធៀបជាមួយឆ្នាំ២០១៤ វិស័យអប់រំ ត្រូវបានបន្ថែមថវិកាប្រមាណជិត១០០លានដុល្លារអាមេរិក។[2] អ្វីដែលគួរឲ្យកត់សម្គាល់មួយទៀតនោះ ថវិកាថ្នាក់ជាតិគ្រោងចំណាយមិនទាន់បែងចែងមានចំនួន១៦%នៅឆ្នាំ២០១៥ ប៉ុន្តែឆ្នាំ២០១៤ មានរហូតដល់ប្រមាណ៤៦%។

## 1. ការបំពេញ/អនុវត្តន៍គោលនយោបាយមានសូចនាករច្បាស់លាស់

*០១. ខិតខំសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧% ក្នុងមួយឆ្នាំ ដើម្បីធ្វើឲ្យកម្ពុជាអាចចាកចេញផុតពីប្រទេសមានចំណូលទាប ឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិតទាបយ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។[3]*

ក្នុងឆ្នាំ២០១៥ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (អង្គការអន្តរជាតិធ្វើការលើម៉ាក្រូហិរញ្ញវត្ថុ) ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) ហៅកាត់ថា ADB ធនាគារពិភពលោក (World Bank) និងមូលនិធិរូបិយប័ណ្ណអន្តរជាតិ (IMF) បានប៉ាន់ប្រមាណថា កម្ពុជានឹងមានកំណើតសេដ្ឋកិច្ចជុំវិញ៧%។

បញ្ហាដែលទាក់ទងនឹងកំណើនសេដ្ឋកិច្ចរបស់កម្ពុជានោះ គឺការបែកចែកផលពីកំណើនសេដ្ឋកិច្ចប្រកបដោយស្មើភាព។ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចកាន់តែធំ មានន័យថា ប្រជាពលរដ្ឋកម្ពុជាអាចទទួលផលពីកំណើនសេដ្ឋកិច្ចកាន់តែធំជាងមុន ប៉ុន្តែក៏មិនមែនមានន័យថា អាចទទួលបានផលពីកំណើននោះគ្រប់គ្នាទេ។ បញ្ហាឡើងថ្លៃទំនិញ ការបណ្តេញចេញពីគម្រោងអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល និងភាពអន់ខ្សោយនៃសេវាសាធារណៈក៏ត្រូវបានគេមើលឃើញ ស្របពេលដែលកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់ផងដែរនោះ។ ការបែងចែកកំណើនផលចំណេញដែលបានមកពីកំណើនសេដ្ឋកិច្ច គឺមិនត្រូវបានធ្វើឡើង ក្នុងលក្ខខណ្ឌប្រកបដោយសមធម៌ តម្លាភាពនៅឡើយទេ ដោយហេតុថា គម្លាតខ្ពស់រវាងអ្នកមាន និងអ្នកក្រនៅក្នុងសង្គមកម្ពុជា គឺនៅជាបញ្ហាចោទនៅឡើយ ឬអាចនិយាយបានថា គម្លាតនេះអាចកាន់តែរីកធំឡើងៗជាងមុនទៅទៀត។

សេចក្តីសន្និដ្ឋាន រាជរដ្ឋាភិបាលកម្ពុជាប្រាកដជាអាចសម្រេចបាននូវការរក្សាកំណើនសេដ្ឋកិច្ចឲ្យនៅត្រឹមរវាង៧ភាគរយក្នុងឆ្នាំទី២នេះ ប៉ុន្តែគម្លាតរវាងអ្នកមាន និងអ្នកក្រកាន់តែរីកធំឡើង។

*០២. សម្រេចឲ្យបានគោលដៅកាត់បន្ថយអត្រានៃភាពក្រីក្រជាង១% ក្នុងមួយឆ្នាំ។[4]*

រាជរដ្ឋាភិបាល និងសមាជិកអង្គការសហប្រជាជាតិជាច្រើនប្រទេសទៀត កាលពីខែកញ្ញា បានទទួលយកគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព សម្រាប់រយៈពេល១៥ឆ្នាំទៅមុខទៀត។ ការលុបបំបាត់ភាពក្រី

---

[2] https://www.cambodiadaily.com/news/cpp-lawmakers-push-through-3-8-billion-national-budget-73314/

[3] *"Political Platforms of the Royal Government of Cambodia of the Fifth Legislature of the National Assembly"*, Royal Government of Cambodia, (Sept 2013), at 15.

[4] *Supra* note 10, at 17.

ក្រគ្រប់រូបភាព និងការលុបបំបាត់ភាពអត់ឃ្លានគឺជាចំណុចសំខាន់ៗនៃគោលដៅអភិវឌ្ឍន៍។ អត្រានៃភាពក្រី នៅកម្ពុជាបានធ្លាក់ចុះគួរឲ្យកត់សំគាល់ គឺពី៤៧,៨ភាគរយក្នុងឆ្នាំ២០០៧ មកនៅត្រឹម១៨,៦ភាគរយក្នុងឆ្នាំ ២០១២។[5] អត្រានៃប្រជាជនដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ក៏បានធ្លាក់ចុះមកនៅតិចជាង២០ភាគរយ ផងដែរ ក្នុងឆ្នាំ២០១៤។ ការរំកិលធ្លាក់ចុះអត្រាភាពក្រីក្រនេះ ដោយសារសន្ទុះនៃកំណើនសេដ្ឋកិច្ច ដែលកម្ពុជា អាចរក្សាបានត្រឹមរវាង៧ភាគរយក្នុងមួយឆ្នាំ។ គិតត្រឹមឆ្នាំ២០១៣ អត្រាភាពក្រីក្របានធ្លាប់មកត្រឹម១៦% ដែលធ្វើឲ្យកម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កាត់បន្ថយភាពក្រីក្រមុនឆ្នាំ២០១៥ នេះបើ យោងតាមសន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងក្នុងកិច្ចប្រជុំកំពូលអង្គការសហប្រជាតិឆ្នាំ ២០១៥។

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានគណនានិយមន័យប្រជាជន ដែលស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ គឺ សំដៅទៅលើក្រុមប្រជាជន ដែលអាចរកប្រាក់ចំណូលបានតិចជាង១,២៥ដុល្លារអាមេរិកក្នុងមួយថ្ងៃ (1.25 UDS/Day)។[6] ទិន្នន័យរបស់ADB ចេញផ្សាយឆ្នាំ២០១៥ បង្ហាញថា កម្ពុជាមានអត្រាប្រពលរដ្ឋរស់នៅក្រោម បន្ទាត់ភាពក្រីក្រដែលរកចំណូលបានទាបជាង១.២៥ដុល្លារសហរដ្ឋអាមេរិកចំនួន១៩.៩% ក្នុងឆ្នាំ២០០៩។[7]

របាយការណ៍អង្គការធនាគារពិភពលោក អំពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាចេញផ្សាយខែមេសា ឆ្នាំ ២០១៥ បានបង្ហាញថា អត្រាភាពក្រីក្របាន និងកំពុងធ្លាក់ចុះ ប៉ុន្តែការធ្លាក់ចុះនាពេលបច្ចុប្បន្ននេះមានសភាព យឺតយ៉ាវ បើប្រៀបធៀបនឹងពេលកន្លងមក។ គិតត្រឹមឆ្នាំ២០១២ អត្រានៃភាពក្រីក្រមានចំនួន១៧.៧% ដែល បានធ្លាក់ចុះស្ទើរតែចំនួន៣% បើប្រៀបធៀបនឹងឆ្នាំ២០១១ ដែលត្រូវបានចាត់ទុកថា ជាការធ្លាក់ចុះដ៏ល ប្រសើរ ទោះបីជាអត្រានៃការធ្លាក់ចុះនេះមានចំនួនតិចជាងអំឡុងឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩។[8] ការធ្លាក់ចុះ អត្រានៃភាពក្រីក្រនៅតំបន់ជនបទ ទំនងជាធ្លាក់ចុះយឺត បើប្រៀបធៀបជាមួយពេលកន្លងមក ដោយសារប្រជា ពលរដ្ឋតំបន់នោះជួបបញ្ហាប្រឈម ដូចជាការបង្កបង្កើនផល និងតម្លៃទិន្នផលកសិកម្ម។ ការធ្លាក់ចុះនូវតម្លៃ ប្រេងបានផ្តល់ប្រយោជន៍តិចតួចដល់ប្រជាជនក្រីក្រ ដោយសារតែពួកគេមិនបានប្រើប្រាស់ប្រេងក្នុងសកម្មភាព សេដ្ឋកិច្ចរបស់គ្រួសារច្រើននោះទេ។ តួលេខធនាគារពិភពលោកខាងលើបង្ហាញថា ក្នុងឆ្នាំ២០១២ មានប្រជា ជនប្រមាណ៣លាននាក់កំពុងស្ថិតក្នុងភាពក្រីក្រ និងប្រមាណ៨.១លាននាក់ផ្សេងទៀត កំពុងស្ថិតក្នុងស្ថាន ភាពជិតក្រ ហើយដែលប្រមាណ៩០%នៃពលរដ្ឋទាំងនេះកំពុងរស់នៅតាមតំបន់ជនបទ។

ដោយឡែក យោងតាមរបាយការណ៍សន្ទស្សន៍ភាពស្រេកឃ្លានសកលឆ្នាំ២០១៥ ដែលចេញផ្សាយ នៅខែតុលា បង្ហាញថា ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ៦០ ក្នុងចំណោមប្រទេសទាំងអស់១១៧។ ចាប់ តាំងពីឆ្នាំ២០០០មក កម្ពុជាបានកាត់បន្ថយភាពស្រេកឃ្លានប្រមាណ៥០%។ របាយការណ៍បានឲ្យដឹងថា ស្ថានភាពស្រេកឃ្លានរបស់កម្ពុជា ស្ថិតក្នុងកម្រិតធ្ងន់ធ្ងរនៅឡើយ។ សន្ទស្សន៍ភាពស្រេកឃ្លានសកលឆ្នាំ ២០១៥ បង្ហាញដែរថា បច្ចុប្បន្នពលរដ្ឋកម្ពុជាប្រមាណ១៤,២% នៅមានបញ្ហាកង្វះអាហារូបត្ថម្ភ ក្មេងអាយុ ក្រោម៥ឆ្នាំ ៩,៦%មានបញ្ហាកង្វះទម្ងន់ កុមារក្រិនមានចំនួន៣២,៤% និងកុមារស្លាប់នៅអាយុក្រោម៥ឆ្នាំចំនួន ៣,៨%។[9]

---

[5] *Cambodia: Country Poverty Analysis 2014*, Asian Development Bank (ADB), 2014, at 4-5.
[6] *Id.*, at 5. See also *Basic Statistics 2014,* Economics and Research Department, The Asian Development Bank (ADB), April 2014, at 2-6.
[7] ADB Report on Basic Statistics 2015 isussed April 2015, page 2
[8] World Bank report on Cambodia Economic Update issued April 2015 Page 14
[9] http://www.rfa.org/khmer/news/social-economy/hunger-report-10192015070951.html

កម្ពុជាដាក់ចេញក្នុងការដេញថ្លៃនេះខ្ពស់ បើធៀបនឹងតម្លៃអង្ករដែលវៀតណាមបានដាក់ចេញ ប៉ុន្តែតម្លៃនេះ ជាតម្លៃល្អបំផុតហើយដែលកម្ពុជាអាចធ្វើបាន។[12]

មានកត្តាជាច្រើន ដែលជាឧបសគ្គសម្រាប់កម្ពុជា ក្នុងការផលិតទិន្នផលស្រូវ ឬអង្ករសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ។ កត្តាទាំងនោះរួមមាន កម្ពុជាខ្វះខាតហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផលិតស្រូវអង្ករ ដូចជាប្រព័ន្ធធារាសាស្ត្រ ឬប្រព័ន្ធស្រោចស្រព បច្ចេកទេសនៃការដាំដុះ និងការបង្កបង្កើនផលខ្វះខាតកម្លាំងពលកម្មខ្វះខាតឃ្លាំងផ្ទុកស្រូវអង្ករ និងម៉ាស៊ីនរោងចក្រ រោងចក្រកែឆ្នៃ ប្រជាពលរដ្ឋជាច្រើនខ្វះដីធ្វើកសិកម្មជាដើម។ ក្រៅពីនេះ នៅមានបញ្ហាជាច្រើនទៀតដូចជា បញ្ហាតំលៃជីកសិកម្ម តំលៃប្រេងសាំង ទីផ្សារ។ល។ ស្រូវមានតម្លៃថ្លៃ ហើយការកែច្នៃមិនទាន់អាចទាក់ទាញយកទិន្នផលផ្សេងៗ ដូចជាចុងអង្ករ កន្ទក់ និងអង្កាមពីស្រូវដើមឲ្យប្រជាកសិករបង្កើនប្រាក់ចំណូលបានឡើយ។ គេក៏សង្កេតឃើញថា ក្នុងសង្វាក់ផលិតកម្មផលិតអង្កររបស់កម្ពុជារាល់ដំណាក់កាលនីមួយៗ ត្រូវការចំណាយថ្លៃជាងគេ។ បន្ថែមពីបញ្ហាដែលបានលើកឡើង គេក៏ទទួលបានព័ត៌មានអំពីពុករលួយ និងការស្ទូកប៉ាន់នៅក្នុងដំណើរការនាំចេញអង្ករ។ ប្រធានផ្នែកលក់នៃក្រុមហ៊ុននាំអង្ករចេញម្នាក់ដែលបានផ្តល់បទសម្ភាសន៍ដល់កាសែតភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃទី២៤ ខែមិថុនាឆ្នាំ២០១៥ បានលើកឡើងថា «មន្ត្រីមួយចំនួនក្នុងជួររដ្ឋាភិបាល បានយកប្រាក់ក្រោមតុ ដើម្បីបង្កើនល្បឿនដំណើរការនាំចេញអង្ករ។ បើយើងពុំចំណាយប្រាក់បន្ថែមទេ មន្ត្រីរដ្ឋាភិបាលនឹងពន្យារពេលដំណើរការនាំចេញនេះ»។[13]

សេចក្តីសន្និដ្ឋាន បើទោះបីជាក្នុងរយៈពេល១០ខែ ឆ្នាំ២០១៥ ការនាំអង្កររបស់ប្រទេសកម្ពុជាមានការលើកឡើងក៏ដោយ ប៉ុន្តែរាជរដ្ឋាភិបាលសម្រេចគោលដៅនាំចេញអង្ករខ្លះក្នុងឆ្នាំ២០១៥នេះ ព្រោះគិតត្រឹមខែតុលានេះ ការនាំចេញអង្ករមិនដល់ចំនួន៥០% នៃគោលដៅនាំចេញចំនួន០១លានតោន។

## *០៤. រក្សាផ្ទៃនេសាទទឹកសាបសម្រាប់ប្រជាជន ធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព។*[14]

កំណែទម្រង់នេសាទ ដែលមានលក្ខណៈស៊ីជម្រៅ និងមានទ្រង់ទ្រាយធំ ត្រូវបានធ្វើឡើងក្នុងឆ្នាំនីតិកាលទី៤នៃរដ្ឋសភាក្នុងឆ្នាំ២០១២ ដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសន្យាជាមួយប្រជាពលរដ្ឋកម្ពុជាថាលោកនឹងលុបចោលប្រព័ន្ធឡូត៍នេសាទអាជីវកម្មឯកជនឲ្យអស់ និងរៀបចំដាក់ផ្ទៃទឹកសាបសម្រាប់សហគមន៍ប្រជានេសាទទូទៅជុំវិញបឹងទន្លេសាប ដើម្បីទទួលផលដោយផ្ទាល់ចំនួន៦៥% និងចំនួន៣៥ភាគរយ រក្សាទុកសម្រាប់ជាតំបន់អភិរក្សវិស័យជលផលក្នុងបឹងទន្លេសាប។[15] ជាលទ្ធផល ឡូត៍នេសាទឯកជនទាំង៣៧ឡូត៍ក្នុងបឹងទន្លេសាប និង៨០ឡូត៍នេសាទនៅទូទាំងប្រទេស ត្រូវបានលុបចោលដោយអនុក្រឹត្យ ក្នុងឆ្នាំ២០១២ ដោយក្នុងទូទាំងប្រទេសមានផ្ទៃទឹកសំរាប់ប្រជាសហគមន៍នេសាទចំនួន៧៦ភាគរយ និង២៤ភាគរយសម្រាប់រក្សាទុកជាផ្ទៃសម្រាប់ធ្វើការអភិរក្សវិស័យជលផល។[16] បច្ចុប្បន្ននេះ គ្មានឡូត៍នេសាទឯកជនណាមួយនៅសេសសល់

[12] http://goo.gl/rtQH4X
[13] http://goo.gl/R3i3NT
[14] [14] *Supra* note 10, at 21.
[15] *Fishery Reform on the Tonle Sap Lake: risks and opportunities for innovation*, 17(2), June 2013 at 1, Cambodia Development Review, (CDRI).
[16] Sub-decree No. 35 on cancellation of fishing lots in Kandal, Kampong Cham, Prey Veng and Takeo provinces for fish sanctuaries. Phnom Penh: Royal Government of Cambodia; RGC [Royal Government of Cambodia]. (2012b). Sub-decree No. 37 on cancellation of fishing lots in six provinces surrounding Tonle Sap Lake in Battambang, Banteay Meanchey, Siem Reap, Pursat, Kampong Chhnang and Kampong Thom provinces for family-scale fishing activity and fish sanctuaries. Phnom Penh: Royal Government of Cambodia. See also Il Oeur, Mam Kosal, Kim Sour and Blake D. Ratner (2014), *Innovations to strengthen aquatic resource governance on Cambodia's Tonle Sap Lake*, Program Report, Collaborating for Resilience, at 5-6.

ដើម្បីប្រកបអាជីវកម្មឡើយ។[17]

រាជរដ្ឋាភិបាល បានអនុវត្តកំណែទម្រង់ស៊ីជម្រៅលើវិស័យជលផល ដោយសម្រេចលុបឡូត៍នេសាទទាំងអស់សំរាប់ទុកឲ្យប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងជាកន្លែងអភិរក្សធនធានជលផល។ ជាមួយគ្នានោះដែរ ផ្អែកទិន្នន័យក្នុងរបាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ សហគមន៍នេសាទទឹកសាបចំនួន៤៧៧សហគមន៍ ត្រូវបានបង្កើត និងចងក្រងឡើងដោយមួយចំនួនបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ និងបានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រង និងអភិរក្សធនធានជលផលនៅកម្ពុជា ចំណែកឯសហគមន៍មួយចំនួនទៀត កំពុងរៀបចំសំណុំឯកសារស្នើសុំចុះបញ្ជី ខណៈសហគមន៍មួយចំនួនផ្សេងទៀតកំពុងដំណើរការចុះហត្ថលេខានៅថ្នាក់ក្រោមជាតិ[18]។ បើប្រៀបធៀបនឹងឆ្នាំមុន ចំនួនសហគមន៍នេសាទទឹកសាប មិនមានការកើនឡើងទោះទេ[19] ប៉ុន្តែការចុះបញ្ជីសហគមន៍នេសាទបានកើនឡើងចំនួន១០ ពី៣៦០ ឆ្នាំ២០១៤ ដល់៣៧០ ឆ្នាំ២០១៥។

ក្នុងគោលនយោបាយនីតិកាលទី៥ រាជរដ្ឋាភិបាលបានសន្យាថា នឹងរក្សាផ្ទៃនេសាទទឹកសាបសម្រាប់ប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព។ ជាការពិតណាស់ រាជរដ្ឋាភិបាលបានលុបបំបាត់ការធ្វើអាជីវកម្មលក្ខណៈឯកជនលើឡូត៍នេសាទទូទាំងប្រទេស ដើម្បីឲ្យប្រជាពលរដ្ឋធ្វើនេសាទ ប៉ុន្តែគេឃើញមានបញ្ហាប្រឈមអំពីការថែរក្សាផ្ទៃទឹកសាប និងគ្រប់គ្រងធានធានជលផលនៅក្នុងផ្ទៃទឹកទាំងនោះ។ ជាក់ស្តែង មានបទល្មើសដែលប្រព្រឹត្តដោយឈ្មួញមានលុយ និងអំណាចកើតមានជារឿយៗ។ នៅដើមខែមិថុនា ប្រជាពលរដ្ឋនៅខេត្តព្រះសីហនុ រិះគន់សកម្មភាពលុបរំលោភយកដីនៅតាមមាត់សមុទ្រ មាត់អូរ មាត់ព្រែក និងជាពិសេស លុបមាត់បឹងព្រែកទប់ មានទីតាំងនៅក្នុងសង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ ឧត្តមសេនីយ៍ឯកដែលមានតួនាទីជាប្រធាននាយកដ្ឋានព្រំដែនទឹកនៃក្រសួងមហាផ្ទៃ ត្រូវបានគេចោទប្រកាន់ថា ជាអ្នកនៅពីក្រោយសកម្មភាពចាក់ដីលុបបឹងព្រែកទប់។120 ទាក់ទងនឹងបទល្មើសនេសាទវិញ សហគមន៍អភិរក្សធនធានមច្ឆាជាតិនៅភូមិភ្លុក ឃុំភ្លុក ស្រុកសេសាន ខេត្តស្ទឹងត្រែងអះអាងថា បទល្មើសប្រើឧបករណ៍នេសាទខុសច្បាប់កើនឡើងច្រើន នៅដងទន្លេ ជាពិសេសកន្លែងអន្លង់ពងកូនរបស់ត្រី ហើយពួកគេកត់សម្គាល់ថា សមត្ថកិច្ចអាជ្ញាធរមូលដ្ឋានមិនបានយកចិត្តទុកដាក់បង្ក្រាបក្រុមនេសាទខុសច្បាប់នេះឡើយ ខណៈដែលសហគមន៍បានផ្តល់ព័ត៌មានអំពីបទល្មើសទាំងនេះ។ ពាក់ព័ន្ធនឹងបទល្មើសនេសាទនេះផងដែរ គេមានបញ្ហាភ្លើងឆេះព្រៃនៅជុំវិញបឹងទន្លេសាប ដែលបញ្ហានេះត្រូវបានគេរាយការណ៍ចាត់ទុកថា ប្រជាពរដ្ឋបានដុតព្រៃដើម្បីយកផ្ទៃដីប្រើប្រាស់ក្នុងវិស័យកសិកម្ម។[21] ថ្ងៃទី២៦ ខែមិថុនាឆ្នាំ២០១៥ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ ក៏បានចេញលិខិតព្រមានអភិបាលខេត្តពោធិ៍សាត់ពាក់ព័ន្ធនឹងករណីអនុញ្ញាតឲ្យមានបទល្មើសនេសាទខុសច្បាប់ក្នុងតំបន់អភិរក្ស។[22]

របាយការណ៍របស់ក្រសួងកសិកម្ម ក៏បានទទួលស្គាល់ចំណុចខ្វះខាត និងបញ្ហាប្រឈមមួយចំនួនទាក់ទងការរក្សាផ្ទៃទឹកសាប និងលុបបំបាត់បទល្មើសនេសាទផងដែរ។ បញ្ហាទាំងនោះមានដូចជា៖ ការបន្តកើត

---

[17] *Id.*, Il Oeur, Mam Kosal, Kim Sour and Blake D. Ratner, at 6.

[18] របាយការបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៤-២០១៥ ទំព័រ២០

[19] *Report on the Situation of Argriculture, Forestry and Fisheries 2013-2014*, Ministry of Argriculture, Firsheries and Forest, Government of Cambodia, at 68.

[20] ដែន អយុធ្យា,វិទ្យុអាស៊ីសេរី ផ្សាយ2015-06-08http://www.rfa.org/khmer/news/environment/people-criticize-authority-not-protect-lake-06082015051914.html

[21] Aqua satellite on April 15, 2015, **http://www.nasa.gov/content/goddard/fires-surround-tonle-sap-lake-in-cambodia/#.Vfy83d-qqkp**

[22] លិខិតក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ លេខ ៤០២៦ កសក ចុះថ្ងៃទី២៦ មិថុនា ២០១៥

២០០៩។ នេះបើតាមតួលេខរបស់អង្គការ WWF។ របាយការណ៍នេះបាននិយាយបន្តថា៖ «ការកាប់ឈើខុសច្បាប់ រួមទាំងក្នុងតំបន់អភិរក្ស គឺជាបញ្ហាចម្បងក្នុងប្រទេសកម្ពុជា មីយ៉ាន់ម៉ា ឡាវ ប៉ុន្តែក៏កើតមានច្រើនទូទាំងតំបន់ទាំងមូល»។ «ការរឹតបន្តឹងផ្នែកច្បាប់ និងគោលនយោបាយ ស្តីពីការកាប់ឈើក្នុងប្រទេសវៀតណាម ចិន និងថៃ រួមជាមួយនឹងតម្រូវការកើនឡើង កំពុងជំរុញឲ្យមានការកាប់ឈើខុសច្បាប់សម្រាប់ការនាំចេញក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា»។ ប៉ុន្តែបន្ថែមពីលើការកាប់ឈើខុសច្បាប់ ចម្ការកៅស៊ូក៏រួមចំណែកការបំផ្លាញព្រៃឈើក្នុងប្រទេសនេះផងដែរ។[28]

របាយការណ៍របស់អ្នកសិក្សាស្រាវជ្រាវនៅសាកលវិទ្យាល័យជាតិអូស្ត្រាលី ដែលបានចេញផ្សាយកាលពីដើមឆ្នាំ២០១៥ ស្តីអំពីការសិក្សាលំអិតអំពីអាស៊ីបាននិយាយថា លោកនាយករដ្ឋមន្ត្រីហ៊ុនសែនបានផ្តល់ផលប្រយោជន៍ តាមរយៈការកាប់ឈើខុសច្បាប់ដល់ឈ្មួញអ្នកមានទ្រព្យសម្បត្តិ ដែលមានទំនាក់ទំនងផ្នែកនយោបាយ ជាថ្នូរនឹងការធានានឹងការក្តោបក្តាប់អំណាចរបស់គណបក្សកាន់អំណាច។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតសេដ្ឋកិច្ចស្រមោលទាក់ទងនឹងការអនុផលព្រៃឈើ ដោយការរួមបញ្ចូលការវិនិយោគពីបរទេស ដែលគ្រប់គ្រង និងផ្តល់ទុនដោយរដ្ឋរបស់ប្រទេសគេ ដើម្បីសហការជាមួយនឹងអ្នកមានទ្រព្យសម្បត្តិដែលមានអំណាច[29]។

តាមគោលនយោបាយ លើវិស័យព្រៃឈើរបស់រដ្ឋាភិបាលកម្ពុជានៃរដ្ឋសភានីតិកាលទី៥នេះ រដ្ឋាភិបាលកម្ពុជាសន្យាថា នឹងបង្កើនចំនួនគម្របព្រៃឈើកម្ពុជាឲ្យបាន៦០ភាគរយនៅត្រឹមឆ្នាំ២០១៥នេះ។ របាយការណ៍ខាងលើបញ្ជាក់ថា កម្ពុជានៅតែទទួលរងវិនាសកម្មពីមួយឆ្នាំ ទៅមួយឆ្នាំ ដោយសារអត្រានៃការកាប់បំផ្លាញព្រៃឈើ និងបទបល្មើសមានទំហំធំធេងដោយខ្វះការទប់ស្កាត់ និងការអនុវត្តន៍ច្បាប់គ្មានប្រសិទ្ធភាព ប៉ុន្តែការដាំដុះកូនឈើ និងការអភិរក្សព្រៃឈើ ឬការទប់ស្កាត់បទល្មើសកាប់បំផ្លាញព្រៃឈើគ្មានប្រសិទ្ធភាព ឬមានប្រសិទ្ធភាពតិចតួច។ ការផ្តល់ដីសម្បទានដល់ក្រុមហ៊ុនបរទេស និងក្រុមហ៊ុនក្នុងស្រុកមួយចំនួនដែលមានទំនាក់ទំនង ឬខ្សែស្រឡាយជិតស្និទ្ធនឹងថ្នាក់ដឹកនាំកំពូលនៃរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលនៅតែទទួលរងការរិះគន់ថា បានបណ្តោយឲ្យក្រុមហ៊ុនដែលទទួលបានដីព្រៃសម្បទានមួយចំនួន ក្នុងចំណោមក្រុមហ៊ុនទាំងនោះ ប្រមូលផលធនធានធម្មជាតិ និងកាប់បំផ្លាញព្រៃឈើរួចទៅហើយ មុននឹងចាត់វិធានការដូច្នេះ។ អ្វីដែលជាការគួរឲ្យកត់សម្គាល់ គឺក្រុមហ៊ុនចំនួន២ ក្នុងចំណោមក្រុមហ៊ុន៣ដែលស្ម័គ្រចិត្តប្រគល់ដីសម្បទានសេដ្ឋកិច្ចឲ្យរដ្ឋគ្រប់គ្រងវិញ ជាក្រុមហ៊ុនរបស់លោក **ទ្រី ភាព** ជាឧកញ៉ាដ៏ល្បីឈ្មោះខាងជំនួញឈើ។ ក្រុមហ៊ុនទាំងពីរនោះគឺ ទ្រីភាព អ៊ីមផត អិចផត និងក្រុមហ៊ុន DMS THMORDA S.E.Z Co.Ltd ដែលក្រុមហ៊ុនទាំង២នេះទទួលបានដីសម្រាប់វិនិយោគកសិឧស្សាហកម្មនៅតំបន់ឧទ្យានជាតិវីរៈជ័យ ខេត្តរតនគិរី ជាជង្រុកព្រៃឈើនៅកម្ពុជាលើផ្ទៃដីសរុប១៨.៨៥៥ហិកតា។[30]

កំណើនបទល្មើសព្រៃឈើ និងភាពអនាធិបតេយ្យនៃការកាប់ទន្រ្ទានព្រៃឈើ និងកាប់ឈើធ្វើអាជីវកម្មសំរាប់លក់ឲ្យឈ្មួញធំៗ ការផ្តល់សិទ្ធិដល់ឈ្មួញធំៗ ដើម្បីប្រមូលទិញឈើយកទៅលក់នៅក្រៅប្រទេស ការផ្តល់ព្រៃសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនធំៗ និងការរុករករ៉ែ និងធ្វើទំនប់វារីអគ្គិសនីជាដើមសុទ្ធតែជាកត្តាសំខាន់ៗដែលជម្រុញឲ្យទំហំនៃគម្របព្រៃឈើនៅកម្ពុជាកាន់តែរួមតូចទៅៗ និងថយចុះជារៀងរាល់ឆ្នាំ ហើយទិសដៅនិងផែនការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដាក់ចេញថា នៅឆ្នាំ២០១៥ កម្ពុជានឹងមានគម្របព្រៃ

---

28 Report on Saving Forests at Risk in 2015 by WWF page: 35-36

29 Daniel Pye on Tue, 23 June 2015 http://www.phnompenhpost.com/national/loggings-roots-deep

30 ណុល ដារ៉ា *តើការដកដីសម្បទានសេដ្ឋកិច្ចពីក្រុមហ៊ុនមកវិញជាការគ្រប់គ្រាន់ទេ?* វិទ្យុសំឡេងប្រជាធិបតេយ្យ ថ្ងៃទី១៩ មករា ឆ្នាំ២០១៥។ see also *The Cost of Luxury: Cambodia's illegal trade in precious wood with China*, The Global Witness, Friday 6th February 2015.

សម្បទានសេដ្ឋកិច្ចដោយក្រុមហ៊ុនឯកជន។ ករណីវិវាទដីធ្លីដែលទាក់ទងនឹងសម្បទានសេដ្ឋកិច្ច ប៉ះពាល់គ្រួសារចំនួន១៧.១៥០ (ប្រមាណ៧៨.៩៩០នាក់)។[39] គេមើលឃើញថា ប្រសិទ្ធភាពនៃការដោះស្រាយវិបត្តិដីធ្លីនៅកម្ពុជានាពេលបច្ចុប្បន្ននៅមានកម្រិតទន់ខ្សោយ។ ជារឿយៗ គេតែងឃើញសកម្មជនទាមទារសិទ្ធិដីធ្លីអ្នករងគ្រោះដោយវិបត្តិដីធ្លី តែងតែស្រែកទាមទារ និងទ្រហោយំឥតឈប់ឈរ ដោយសារតែបញ្ហារបស់ពួកគេមិនត្រូវបានដោះស្រាយ ឬដោះស្រាយដោយប្រាសចាកគោលការណ៍យុត្តិធម៌។ ការដោះស្រាយបណ្តឹង មិនយុត្តិធម៌ពីសំណាក់ប្រព័ន្ធតុលាការ និងអាជ្ញាធរពាក់ព័ន្ធ ធ្វើឲ្យវិបត្តិដីធ្លីចេះតែកើនឡើង និងរីករាលដាល អូសបន្លាយ និងបង្កផលប៉ះពាល់កាន់តែធ្ងន់ធ្ងរឡើងៗ។[40] បញ្ហារំលោភបំពានដីធ្លី គឺជាបញ្ហាដ៏ចាប់អារម្មណ៍ជាងគេហើយដែលតែងតែមាននៅលើទំព័រកាសែត និងសារព័ត៌មានស្ទើរជារៀងរាល់ថ្ងៃ។

ទាក់ទងនឹងវិបត្តិនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដល់ក្រុមហ៊ុនឯកជនក្នុងស្រុក និងក្រុមហ៊ុនបរទេស ចាប់តាំងឆ្នាំ២០១៤មក រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការត្រួតពិនិត្យ និងវិនិច្ឆ័យឡើងវិញនូវលក្ខខណ្ឌ និងរយៈពេលផ្តល់ដីសម្បទានសេដ្ឋកិច្ចឲ្យក្រុមហ៊ុនទាំងនោះ។ រាជរដ្ឋាភិបាលបានសម្រេចជាគោលការណ៍ក្នុងការកាត់បន្ថយរយៈពេលនៃការអនុវត្តន៍គម្រោងវិនិយោគ អភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចទាំងអស់ នៅត្រឹមយ៉ាងយូរ៥០ឆ្នាំ។ នៅខែកក្កដា ឆ្នាំ២០១៥ ក្រសួងបរិស្ថានបានធ្វើការវាយតម្លៃលើក្រុមហ៊ុនសម្បទានសេដ្ឋកិច្ចចំនួន ១៦ នៅក្នុងខេត្តមណ្ឌលគិរី រតនគិរី និងកំពង់ស្ពឺ។ ក្រុមហ៊ុនទាំង១៦ ត្រូវបានតម្រូវឲ្យចុះកិច្ចសន្យាឡើងវិញ និងកាត់បន្ថយរយៈពេលវិនិយោគនៅត្រឹមរយៈពេល៥០ឆ្នាំវិញ។ មកទល់នឹងពេលនេះ ក្រសួងបានពិនិត្យ និងវាយតំលៃគម្រោងវិនិយោគចំនួន១១៣ ក្នុងនោះ គម្រោងរបស់ក្រុមហ៊ុនចំនួន២៣ ត្រូវបានរាជរដ្ឋាភិបាលសម្រេចដកហូតដីសម្បទានសេដ្ឋកិច្ចមកវិញ។ ស្របពេលដែលគម្រោងចំនួន៤ (៣២.២៨៧ហ.ត) ត្រូវបានក្រុមហ៊ុនស្ម័គ្រចិត្តប្រគល់ជូនរដ្ឋាភិបាលដើម្បីគ្រប់គ្រងវិញ។ ចំណែកឯគម្រោង៤ផ្សេងទៀត (១៤.៨៥៤,៧៥ ហ.ត) ត្រូវបានរាជរដ្ឋាភិបាលកាត់បន្ថយផ្ទៃដីវិនិយោគ និងគម្រោងចំនួន១៨ទៀត ត្រូវបានផ្តល់រយៈពេល០៦ ទៅ១២ខែ ដើម្បីបន្តនីតិវិធីចាំបាច់។[41]

ជាមួយគ្នានេះដែរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មកដល់ចុងខែកញ្ញា ឆ្នាំ២០១៥នេះ ក្រុមហ៊ុនចំនួន១១៨ត្រូវបានក្រសួងកសិកម្មត្រួតពិនិត្យ និងវាយតម្លៃ ដែលក្នុងនោះក្រុមហ៊ុនចំនួន១៥ត្រូវបានដកហូត ក្រុមហ៊ុនចំនួន១២ត្រូវបានឲ្យសម្រួលផ្ទៃដី ក្រុមហ៊ុន៧៧ត្រូវបានអនុញ្ញាតឲ្យបន្តនីតិវិធី។ ក្រុមហ៊ុន៣ ក្រសួងទុករយៈពេល១ឆ្នាំ ក្រុមហ៊ុន៥ទុករយៈពេល៦ខែ និងក្រុមហ៊ុន៣ទៀតទុករយៈពេល៣ខែ ដើម្បីតាមដានវឌ្ឍនភាពរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនប្រមាណ១២០នោះ ក្រសួងបានសម្រេចបន្ថយរយៈពេលវិនិយោគមក៥០ឆ្នាំវិញ។[42]

ការដកហូតអាជ្ញាប័ណ្ណ កែសម្រួល និងកំណត់កិច្ចសន្យាឡើងវិញជាមួយក្រុមហ៊ុនទាំងប៉ុន្មានខាងលើ ដែលបានទទួលសិទ្ធិសម្បទានអភិវឌ្ឍន៍ធ្វើឡើង ក្រោយពីរាជរដ្ឋាភិបាលកម្ពុជាបានតាមដាន និងរកឃើញថាក្រុមហ៊ុនទាំងនោះមិនបានអនុវត្តកាតព្វកិច្ច ដូចដែលមានចែងក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍន៍ដីក្នុងតំបន់ទាំងនោះជាច្រើនឆ្នាំ។

---

[39] របាយការណ៍ស្តីអំពី ការវិភាគស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជាឆ្នាំ២០១៤ ទំព័រទី ២៦, ៣១ និង៣៦ ដោយ NGO Forum on Cambodia

[40] See also, George Wright, *UN Envoy Critical as Tenure Draws to a Close*, the Cambodia Daily, January 24, 2015, at A3.

[41] សេចក្តីប្រកាសលេខ៖ ៦៨៣ ស.ជ.ណ.រ.ស្ក ចុះថ្ងៃទី២៨ កក្កដា ២០១៥

42 ដោយ៖ ស៊ុន ណារិន ផ្សាយថ្ងៃអង្គារ ទី29 កញ្ញា 2015 http://vodhotnews.com/32381

ត្រួតពិនិត្យឡើងវិញនូវល័ក្ខខ័ណ្ឌនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលត្រូវបានគេរាយការណ៍ថា ជាមូលហេតុនៃជម្លោះដីធ្លីនាពេលកន្លងមក។ បើតាមរបាយការណ៍អង្គការADHOC ក្នុងរយៈពេល០៦ខែ ឆ្នាំ២០១៥ ករណីជម្លោះដីធ្លីចំនួន៦៦ ត្រូវបានប្តឹងដោយប្រជាពលរដ្ឋ ខណៈពេលដែលក្នុង១២ខែ ឆ្នាំ២០១៤ មានបណ្តឹងរហូតដល់១៤០ករណី។[46] តួលេខនេះពិតជាបានបង្ហាញថា ចំនួនករណីជម្លោះដីធ្លីនៅឆ្នាំ២០១៥នេះហាក់ដូចធ្លាក់ចុះ។

ដោយឡែក សន្ទុះនៃការដោះស្រាយជម្លោះដីធ្លី ហាក់ដូចជាកើនឡើង ប៉ុន្តែប្រសិទ្ធភាព និងកំរិតនៃការដោះស្រាយជម្លោះនៅមានកំរិត និងមានចរិតនយោបាយច្រើនជាងការដោះស្រាយដោយឆន្ទៈ និងតម្រូវការពិតប្រាកដរបស់ពលរដ្ឋ។ ការដាក់ចេញនូវបទបញ្ជា០១របស់រាជរដ្ឋាភិបាល គឺបន្ថែមលើយន្តការនៃការចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋដែលមានស្រាប់។ ហើយយន្តការនេះត្រូវបានគេរិះគន់ថា ជាការកេងចំណេញផ្នែកនយោបាយរបស់គណបក្សកំពុងកាន់អំណាច និងបង្ហាញពីភាពអសមត្ថភាពរបស់មន្ត្រីរាជរដ្ឋាភិបាល ក្នុងការដោះស្រាយជម្លោះ និងផ្តល់កម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋនាពេលកន្លងមក។ របាយការណ៍ស្រាវជ្រាវមួយ ស្តីពីការអនុវត្តន៍នយោបាយចាស់ សកម្មភាពថ្មី និងផលប៉ះពាល់នៃបទបញ្ជាលេខ០១ របស់អង្គការ NGOs Forum បានបង្ហាញថា បទបញ្ជាលេខ០១ ស្តីពីបញ្ហាដីធ្លី នៅតែមានភាពស្មុគស្មាញសម្រាប់តំបន់ដែលមានជម្លោះដីធ្លី។ របាយការណ៍បានបន្ថែមថា មានប្រជាជនរស់នៅក្នុងតំបន់ខ្លះ ដែលបានវាស់វែងតាមបទបញ្ជា០១ ទទួលបានប័ណ្ណកម្មសិទ្ធ ប៉ុន្តែជាច្រើនខ្លះទៀតមិនត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិឲ្យនោះទេ។ លើសពីនេះ បទបញ្ជា០១ក៏បានផ្តល់នូវលទ្ធផលច្របូកច្របល់ នៅតំបន់ដែលធ្លាប់មានជម្លោះដីធ្លីផងដែរ។ ដីដែលមានជម្លោះពាក់ព័ន្ធជាមួយនឹងភាគីមានអំណាច ឬក្រុមហ៊ុនដីសម្បទាន កម្រនឹងត្រូវបានដោះស្រាយណាស់។ ជាងនោះទៅទៀត ក្នុងអំឡុងពេលអនុវត្តបទបញ្ជា០១នេះ ក៏ត្រូវបានគេរាយការណ៍ថា មានអំពើពុករលួយក្នុងដំណើរវាស់វែងផ្តល់កម្មសិទ្ធិ ដែលបានប្រព្រឹត្តដោយអ្នកមានទ្រព្យសម្បត្តិកំពុងកាន់កាប់ដីធ្លី។[47]

សេចក្តីសន្និដ្ឋាន រាជរដ្ឋាភិបាលសម្រេចបានខ្លះនូវផែនការចុះបញ្ជីដីសម្រេចឲ្យបាន៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដីដែលត្រូវចុះបញ្ជីសរុប៦ ទៅ៧លានក្បាលដីនៅទូទាំងប្រទេស។ យោងតាមសន្ទុះស្បន់នៃការកើនឡើង ក្នុងការអនុវត្តន៍ក្នុងឆ្នាំទី១ និងទី២នេះ ប្រសិនបើគ្មានការប្រែប្រួលទេនោះ រាជរដ្ឋាភិបាលនឹងសម្រេចបានតាមផែនការរបស់ខ្លួនក្នុងឆ្នាំ២០១៨ជាមិនខាន។

### *០៨. កសាងគោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅស្ថាន ដើម្បីដោះស្រាយលំនៅស្ថានជូនប្រជាជនក្រីក្រសម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពថ្លៃថ្នូរ។*[48]

តាមទិន្នន័យជំរឿនប្រជាពលរដ្ឋឆ្នាំ២០០៨ កម្ពុជានឹងមានប្រជាជនប្រមាណ១៨លាននាក់ នៅឆ្នាំ២០៣០ គឺអាចកើនប្រមាណ៣ ឬ៤លាននាក់បន្ថែមទៀត ហើយកំណើននេះភាគច្រើនកើនឡើងនៅតាមទីប្រជុំជនធំៗដែលមានសក្តានុពលវិស័យសេដ្ឋកិច្ច។ ការធ្វើជំរឿននេះ ក៏បានបង្ហាញផងដែរនូវនិន្នាការនៃការថយចុះទំហំគ្រួសារដែលអាចប៉ាន់ប្រមាណថា រហូតដល់ឆ្នាំ២០៣០ កម្ពុជាអាចត្រូវការលំនៅដ្ឋានថ្មីប្រមាណ១,១លានមន្ថែមទៀត ដោយមិនរាប់បញ្ចូលលំនៅដ្ឋានបច្ចុប្បន្ន។[49]

នៅក្នុងកិច្ចប្រជុំពេញអង្គ គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ កាលពីថ្ងៃទី០៩ ខែឧសភា

---

[46] Report on Whose Land? By ADHOC at page 28, 30 on 22 Jully 2015

[47] Report on "New Actions and Existing Policies" The Implementation and Impacts of Order 01, page 11

[48] *Supra* note 10, at 24.

[49] May Titthara, *Million-home dilemma* , The Phnom Penh Post, 12 May, 2014.

ការសន្និដ្ឋាន រាជរដ្ឋាភិបាលសម្រេចបានខ្លះការកសាងគោលនយោបាយជាតិ ស្តីពីលំនៅដ្ឋាន ប៉ុន្តែយើងមិនទាន់ដឹងថា ប្រជាពលរដ្ឋក្រីក្រ ជាពិសេសជនងាយរងគ្រោះពីការបណ្តេញចេញដោយបង្ខំនឹងទទួលបានផលប្រយោជន៍ពីគោលនយោបាយនោះក្នុងកម្រិតណានោះទេ។

*០៩. កែលម្អផ្លូវលំជនបទជាដំហានៗ ពីផ្លូវក្រាលក្រួសក្រហម ទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងឲ្យបានពី ៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំ តាមស្តង់ដារឯកភាពជាតិមួយ។*

រាជរដ្ឋាភិបាលបានចំណាយថវិកាជាតិ ជាមួយនឹងជំនួយ និងប្រាក់កម្ចីដ៏ច្រើនលើសលប់ដែលទទួលបានពីប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិ រួមមានធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោកជាដើម ដើម្បីសាងសង់ និងកែលំអផ្លូវជនបទជាច្រើនខ្សែដែលផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់កំណើនសេដ្ឋកិច្ចនៅកម្ពុជា។ ទន្ទឹមគ្នានឹងការរីកចំរើននៃវិស័យប្រព័ន្ធដឹកជញ្ជូន ដោយជួសជុល ស្តារ ស្ថាបនាសាឡើងវិញនេះដែរ បញ្ហាគុណភាពផ្លូវនៅតែជាបញ្ហា ដែលទទួលរងការរិះគន់យ៉ាងខ្លាំងពីប្រជាជនទូទៅដដែល។ អំពើពុករលួយក្នុងវិស័យនេះ ត្រូវបានគេរិះគន់យ៉ាងខ្លាំង មិនមែនត្រឹមតែប្រជាពលរដ្ឋ គណបក្សប្រឆាំង ឬក្រុមអង្គការសង្គមស៊ីវិលប៉ុណ្ណោះទេ សូម្បីតែមន្ត្រីជាន់ខ្ពស់នៃគណបក្សកាន់អំណាចមួយចំនួន ក៏បានរិះគន់ដោយចំហទៅលើអំពើពុករលួយដែលបាន និងកំពុងកើតមានឡើងក្នុងកិច្ចការស្ថាបនា កែលម្អ ជួលជុល និងកសាងផ្លូវជាតិ ឬផ្លូវលំជាដើមរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ។ ការកិបកេង ឬបន្លំពីគំរោងសាងសង់ផ្លូវជាតិនីមួយៗ គឺមានកំរិតធ្ងន់ធ្ងររហូតដល់៦០ភាគរយ ប្រព្រឹត្តដោយមន្ត្រីពាក់ព័ន្ធនឹងការសាងសង់។[51]

ក្នុងវិស័យកែលំអផ្លូវលំជនបទ រាជរដ្ឋាភិបាល ដែលមានក្រសួងអភិវឌ្ឍន៍ជនបទកំពុងបន្តគម្រោងកែលំអជួសជុល និងស្ថាបនាផ្លូវជនបទ (Rural Road Improvement Project-RRIP) ដែលមានរយៈពេលប្រាំឆ្នាំ(ឆ្នាំ២០១១ ដល់ឆ្នាំ២០១៦)។ ហើយក្នុងឆ្នាំ២០១៥នេះ ដែលរាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមអនុវត្តគំរោង កែលំអផ្លូវជនបទជំហានទី២ (Rural Road Improvement Project-RRIP2) ដែលមានរយៈពេល០៦ឆ្នាំ (ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០) ហើយគម្រោងនេះគ្រោងនឹងចំណាយថវិកាសរុបចំនួន១៩២,៧១លានដុល្លារអាមេរិក ដែលជាថវិការបស់រាជរដ្ឋាភិបាលប្រមាណ០៩% និងជំនួយរបស់របស់ដៃគូអភិវឌ្ឍន៍ ព្រមទាំងស្ថាប័នផ្សេងៗដូចជា៖ ធនាគារអភិវឌ្ឍន៍អាស៊ី ឥណទានរបស់សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋបារាំង តាមរយៈទីភ្នាក់អភិវឌ្ឍន៍បារាំង (AFD) គម្រោងសាកល្បងភាពធន់នឹងបម្រែបម្រួលអាកាសធាតុ (PPCR) ជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលអូស្ត្រាលី និងជំនួយឥតសំណងរបស់មូលនិធិអភិវឌ្ឍន៍ណ័រឌិក។ គម្រោងជំហានទី២នេះ នឹងត្រូវអនុវត្តក្នុងខេត្តចំនួន១០ដូចជា៖ ត្បូងឃ្មុំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ។

ក្នុងរយៈ១ឆ្នាំនៃឆ្នាំ២០១៤ ក្រសួងអភិវឌ្ឍន៍ជនបទបានអនុវត្តគម្រោងសាងសង់ផ្លូវ ដែលជាហិរញ្ញប្បទាន រវាងធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលកម្ពុជា ហើយសម្រេចបានប្រវែង៥០៥,៧០គីឡូម៉ែត្រ និងនៅសល់តិចតួចកំពុងអនុវត្ត ដើម្បីបញ្ចប់ដោយចំណាយថវិកាអស់ប្រមាណជាង២៤លានដុល្លារសហរដ្ឋអាមេរិក។[52] របាយការណ៍វឌ្ឍនភាពការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក៏ដូចជារបាយការណ៍របស់នាយកដ្ឋានផ្លូវលំជនបទបានឲ្យដឹងថា ក្នុងរយៈពេល១១ខែ ឆ្នាំ២០១៥នេះ ដោយអនុវត្តគម្រោង

---

[51] Phann Ana, *CPP Official Alleges Embezzlement of Roads Budgets*, The Cambodia Daily, July 11, 2014.

[52] *របាយការណ៍ប្រចាំខែធ្នូ ឆ្នាំ២០១៤ របស់គម្រោងកែលម្អផ្លូវជនបទ* ក្រសួងអភិវឌ្ឍន៍ជនបទ រាជរដ្ឋាភិបាលកម្ពុជាទំព័រ១១។

ភ្នំពេញ ដើម្បីដំណើរឲ្យមានរថយន្តដឹកជញ្ជូនសាធារណៈ ដើម្បីកាត់បន្ថយការកកស្ទះខ្លាំង ដែលជាបញ្ហាដ៏ចំបងមួយនៅរាជធានីភ្នំពេញ។ គិតត្រឹមឆ្នាំ២០១៥ រថយន្តក្រុងសាធារណៈចំនួន៧៤គ្រឿង ត្រូវបានដាក់ពង្រាយដំណើរលើផ្លូវ០៣ខ្សែ ដើម្បីដឹកជញ្ជូនសាធារណជននៅតាមបណ្ដាមហាវិថីធំៗ។ ចំណែកចំនួនប្រជាពលរដ្ឋដែលប្រើប្រាស់សេវាសាធារណៈនេះ បើប្រៀបធៀបជាមួយពេលកន្លងមកមានការធ្លាក់ចុះ។ ប្រភពព័ត៌មានពីសាលារាជធានីភ្នំពេញបានឲ្យដឹងថា តួលេខអ្នកជិះប្រចាំថ្ងៃ គឺមានចំនួនធ្លាក់ចុះបន្តិចក្នុងរយៈពេល ប៉ុន្មានខែចុងក្រោយ ដែលមានជាមធ្យមប្រហែល៦ពាន់នាក់ ថយចុះជាងមុនបន្តិចដែលពីមុនមានខ្ទង់៧ពាន់នាក់ក្នុងមួយថ្ងៃ។ ការថយចុះអាចមកពីបញ្ហាការកកស្ទះខ្លាំងធ្វើឲ្យមានការយឺតយ៉ាវ ព្រោះមិនទាន់មានផ្លូវអាទិភាពសម្រាប់រថយន្តក្រុង ធ្វើឲ្យអ្នកដំណើរមិនសូវសប្បាយចិត្ត។[55]

បើទោះបីជាប្រជាពលរដ្ឋមិនពេញនិយម ក្នុងការប្រើប្រាស់សេវារថយន្តក្រុងសាធារណៈក៏ដោយ ក្នុងឆ្នាំ២០១៥នេះ សាលារាជធានីភ្នំពេញគ្រោងនឹងពង្រីកជើងធ្វើដំណើរនៃសាវាកម្មនេះ ដោយបាន និងកំពុងសហការជាមួយអង្គការJICA ដើម្បីរៀបចំនីតិវិធីស្នើសុំរថយន្តក្រុងថ្មីចំនួន១៥០គ្រឿងពីប្រទេសជប៉ុន និង១០០គ្រឿងពីប្រទេសចិន។[56]

សេចក្ដីសន្និដ្ឋាន រាជរដ្ឋាភិបាលសម្រេចបានការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ជាពិសេសសំរាប់រាជធានីភ្នំពេញ ព្រោះគេសង្កេតឃើញមានការពង្រាយរថយន្តដឹកជញ្ជូនសាធារណៈបន្ថែមទៀត តាមបណ្ដោយផ្លូវសំខាន់នៅក្នុងរាជធានីភ្នំពេញ។ ប៉ុន្តែគេសង្កេតឃើញថា ចំនួនប្រជាជនដែលកំពុងតែប្រើប្រាស់សេវាកម្មដឹកជញ្ជូនរបស់រដ្ឋនេះនៅមានកំរិតតិចតួចនៅឡើយ។

*១១. ដល់ឆ្នាំ២០១៨ ប្រជាជនចំនួន៨៥% ដែលរស់នៅរាជធានីខេត្ត និងប្រជាជនចំនួន៦០% ដែលរស់នៅតាមបណ្ដាឃុំ បានទទួលសេវាទឹកស្អាតដែលមានគុណភាពល្អ និងថ្លៃសមរម្យប្រើប្រាស់។*[57]

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់អង្គការ (UNICEF) ចេញផ្សាយនៅដើមឆ្នាំ២០១៤ បានឲ្យដឹងថា ប្រជាជនកម្ពុជាប្រមាណ៦,៣លាននាក់ គឺស្មើនឹង៤២ភាគរយនៃប្រជាជនសរុប១៥លាននាក់ កំពុងខ្វះខាតទឹកស្អាតសម្រាប់ប្រើប្រាស់ ហើយចំនួនប្រជាជន៣,៩លាននាក់ ស្មើនឹង២៦ភាគរយនៃចំនួន (៦,៣លាននាក់) ប្រជាជនអ្នកខ្វះទឹកស្អាតបរិភោគ និងប្រើប្រាស់ គឺជាប្រជាជនក្រីក្រ និងរស់នៅទីជនបទ។[58]

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទបាន និងកំពុងអនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី២ នៅក្នុងឃុំចំនួន៣២នៃខេត្តចំនួន៦ ដូចជា៖ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ។ ពាក់ព័ន្ធនឹងបញ្ហាទឹកស្អាត គម្រោងនេះនឹងធ្វើសកម្មភាពដូចជា៖ ជួសជុលធ្វើឲ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹក និងធ្វើឲ្យប្រសើរឡើង និងមាននិរន្តរភាពនូវផ្នែកផ្គត់ផ្គង់ទឹកស្អាត តាមរយៈការជួយគាំទ្រលើផ្នែកឯកជន និងការត្រួតពិនិត្យ។

របាយការណ៍វឌ្ឍភាពការងារប្រចាំខែវិច្ឆិកា២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទបានឲ្យដឹងថា មានការសាងសង់អណ្ដូងស្នប់ចំនួន២៤ និងអណ្ដូងលូចំនួន០៥ និងមានការជួសជុលអណ្ដូងស្នប់ចំនួន១៩២ និងអណ្ដូងលូចំនួន០៦ នៅរាជធានីភ្នំពេញ និងខេត្តមួយចំនួន។ ជាងនេះទៅទៀត គេឃើញមានការសាងសង់ស្រះ

---

[55] សេវារថយន្តក្រុងដំណើរការដល់ណាហើយ?**http://news.sabay.com.kh/article/431351**

[56] គី សុខលីម ,សាលារាជធានីភ្នំពេញស្នើសុំរថយន្តក្រុង១៥០គ្រឿងពីជប៉ុន និង១០០គ្រឿងពីចិន (ចុះផ្សាយនៅថ្ងៃ 01-11-2015, 4:00 pm) http://www.thmeythmey.com/index.php?page=detail&ctype=article&id=32543&lg=kh

[57] *Supra* note 10, at 30.

[58] Denise Shepherd-Johnson, *World Water Day: 6.3 million Cambodians lack access to safe water*, Press Release, UNICEF, (21 March 2014), at 1

សហគមន៍ និងរៀបចំក្រុមប្រើប្រាស់ទឹកស្អាតមួយចំនួននៅមូលដ្ឋានរបស់ប្រជាពលរដ្ឋ។

សេចក្តីសន្និដ្ឋាន រដ្ឋាភិបាលបានសម្រេចខ្លះនូវការសន្យាថា «ដល់ឆ្នាំ២០១៨ ប្រជាជនចំនួន៨៥ភាគរយ រស់នៅរាជធានី ខេត្ត និងប្រជាជនចំនួន៦០ភាគរយ ដែលរស់នៅតាមបណ្តាឃុំនឹងទទួលបានទឹកស្អាតដែលមានគុណភាពល្អ និងតំលៃសមរម្យសម្រាប់ប្រើប្រាស់» សម្រេចបានខ្លះ។

### *១២. ពីឆ្នាំ២០១៣ ដល់២០១៨ គឺពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិចំនួន៨០% នៃចំនួនភូមិទាំងអស់។*[59]

រហូតមកត្រឹមឆ្នាំ២០១៣ មានប្រជាជនប្រមាណត្រឹមតែ ២២,៤៧ភាគរយនៃប្រជាជនសរុបប៉ុណ្ណោះ ដែលបានប្រើប្រាស់ថាមពលអគ្គិសនី (៥៤ភាគរយនៅទីប្រជុំជន និង១៣ភាគរយនៅតំបន់ជនបទ។[60]) តួលេខនេះបានបង្ហាញថា ប្រជាជនកម្ពុជាភាគច្រើន គឺមិនទាន់ទទួលបានការផ្គត់ផ្គង់ថាមពលអគ្គិសនីគ្រប់គ្រាន់ និងជាប់លាប់នៅឡើយទេ។ គម្លាតនៃការអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធនៃការតភ្ជាប់បណ្តាញអគ្គិសនី រវាងទីក្រុង និងទីជនបទ គឺនៅមានគម្លាតឆ្ងាយដាច់ពីគ្នានៅឡើយ។

ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) បានប៉ាន់ប្រមាណថា កម្ពុជាមានសក្តានុពលខ្លាំងលើការអភិវឌ្ឍន៍វិស័យថាមពលវារីអគ្គិសនី ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ កម្ពុជានឹងមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ឬអាចគ្របដណ្តប់ភាគច្រើនលើផ្ទៃប្រទេស បន្ទាប់ពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីធំៗមួយចំនួន ត្រូវបានបញ្ចប់ និងដាក់ឲ្យដំណើរការជាស្ថាពរ។ កំណើនប្រជាជន និងការអភិវឌ្ឍន៍ឧស្សាហកម្មកាន់តែកើនឡើង ធ្វើឲ្យតម្រូវការនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីក៏កាន់តែកើនឡើងដែរ។ នាពេលបច្ចុប្បន្ននេះ ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅកម្ពុជានៅមានកម្រិត ក្រោមតម្រូវការរបស់អ្នកប្រើប្រាស់នៅឡើយ ចំណែកតំលៃវិញក៏ថ្លៃជាងគេ បើធៀបជាមួយប្រទេសនានាក្នុងតំបន់អាស៊ានទាំង១០ប្រទេស និងពិភពលោក។[61] ការផ្គត់ផ្គង់អគ្គិសនីសរុបនៅកម្ពុជាក្នុងឆ្នាំ២០១៣ មានចំនួន៤,៣ពាន់លានគីឡូវ៉ាត់ម៉ោង ក្នុងនោះនាំចូលពីប្រទេសវៀតណាម និងថៃមានទំហំ៦០ភាគរយនៃការផ្គត់ផ្គង់សរុប។[62] តាមការស្រាវជ្រាវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មកត្រឹមឆ្នាំ២០១៣នេះ កម្ពុជាអាចមានសក្តានុពលផលិតថាមពលអគ្គិសនី ដែលដើរដោយកំលាំងវារីអគ្គិសនីបាន រហូតដល់ទៅ ១០.០០០មេកាវ៉ាត់ ប៉ុន្តែបច្ចុប្បន្ននេះ កម្ពុជាអាចមានលទ្ធភាពទាញយកផលពីសក្តានុពលដ៏ធំនេះបានត្រឹមតែ ២២៨,៥៧មេកាវ៉ាត់ប៉ុណ្ណោះដើម្បីយកមកប្រើប្រាស់។ បើយោងតាមការសិក្សាស្រាវជ្រាវដដែលនេះ បានឲ្យដឹងដែរថា កម្ពុជានឹងមានកំណើនថាមពលអគ្គិសនី ដែលបានពីគម្រោងទំនប់វារីអគ្គិសនីចំនួន២៨.៩ភាគរយ ក្នុងរវាងឆ្នាំ២០១០ ដល់ឆ្នាំ២០៣៥។ ជាថ្មីម្តងទៀត លោកនាយករដ្ឋមន្ត្រីកម្ពុជានៅដើមឆ្នាំ២០១៤ នេះបានអះអាងបញ្ជាក់ថា នៅឆ្នាំ២០២០ កម្ពុជានឹងមានបណ្តាញអគ្គិសនីតភ្ជាប់ទៅគ្រប់ភូមិនៃប្រទេសកម្ពុជាទាំងមូល ហើយឆ្នាំ២០៣០ គ្រប់ផ្ទះទាំងអស់ទូទាំងប្រទេសនឹងមានថាមពលអគ្គិសនីប្រើប្រាស់។[63]

---

[59] *Supra* note 10, at 31.

[60] Cambodia Investment Guidebook, CDC, 2013, P. IV-2; http://www.cambodiainvestment.gov.kh/#fragment-3-tab, accessed on 25 November 2014.

[61] Karen Ellis, Jodie Keane, *et.al*., *Alberto Lemma and Lonn Pichdara, Low carbon competitiveness in Cambodia*, The Overseas Development Institute (ODI), (2013), at 9. See also Eddie Morton, *Energy reform needed in emerging markets*, The Phnom Penh Post, 11 December 2014, A1.

[62] Open Development Cambodia, "Hydro Power"; available link at http://www.opendevelopmentcambodia.net /briefing/hydropower/, cited on 09 October, 2014.

[63] *Hun Sen says all villages to have electricity by 2020*, The Khmer Herald, A1.

ឃើញថា គុណភាពអប់រំនៅកម្ពុជា គឺស្ថិតនៅក្នុងកំរិតទន់ខ្សោយខ្លាំង។ ដែលនេះជាហេតុផលមួយធ្វើឲ្យក្រសួងយកចិត្តទុកដាក់ រឹតបន្តឹងការប្រលងមធ្យមសិក្សាទុតិយភូមិដែលបាន និងកំពុងអនុវត្តក្នុងពេញ០២ឆ្នាំកន្លងមក។

ក្រៅពីគុណភាពអប់រំ ហេដ្ឋារចនាសម្ព័ន្ធអប់រំក៏នៅមានកំរិតនៅឡើយ ដែលនេះជាឧបសគ្គដ៏ចំបងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស។ របាយការណ៍របស់ក្រសួងអប់រំបានបង្ហាញថា កម្ពុជានៅមានសាលាជួបការលំបាកចំនួន៣១៦ និងថ្នាក់រៀននៅក្នុងវត្តអារាមចំនួន៦៣៦ ក្នុងឆ្នាំ២០១៥នេះ។ ក្រោយពីការចូលសមាហរណកម្មអន្តរជាតិឆ្នាំ១៩៩៣ កម្ពុជាចាប់ផ្តើមមានសន្តិភាពជាបណ្តើរៗ រហូតបញ្ចប់បានសង្គ្រាមស៊ីវិលទាំងស្រុងនៅឆ្នាំ១៩៩៨។ អគារសាលារៀនជាច្រើនពាន់ខ្នងត្រូវបានកសាងឡើង ដោយមានការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ប្រទេសដៃគូអភិវឌ្ឍន៍ ឬជាមិត្តសប្បុរសជនក្នុងប្រទេស និងក្រៅប្រទេស។ល។ ចំនួនអគារសាលារៀននៅកម្ពុជាបានកើនឡើងពីមួយឆ្នាំ ទៅមួយឆ្នាំឥតឈប់ឈរ។ ប៉ុន្តែទន្ទឹមគ្នានោះដែរ កង្វះអគារសាលារៀន។

រហូតមកដល់ឆ្នាំ២០១៥នេះ កម្ពុជាមានអគារសាលារៀនទូទាំងប្រទេសចំនួន១២.១៩៨ ឬស្មើនឹង ៨៣.២៣៨ ថ្នាក់រៀនមានសិស្សានុសិស្សចំនួន៣.០៣៦.០១៨នាក់។ សាលារៀនសម្រាប់ថ្នាក់មត្តេយ្យមានប្រមាណជា៣.៤៤៣សាលារៀន សាលាបឋមសិក្សាមានចំនួណ៧.០៥១សាលារៀន អនុវិទ្យាល័យ (ថ្នាក់ទី៧-៩) មានចំនួន១.២៤៩សាលារៀន (ទីប្រជុំជន១៣២ តំបន់ជនបទ១.១១៧) មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២)។[69]

កម្ពុជាមាន១.៦៣៣ ឃុំ/សង្កាត់ ចំណែកចំនួនសាលារៀនសម្រាប់ថ្នាក់អនុវិទ្យាល័យ រហូតមកដល់ឆ្នាំ ២០១៥នេះ ទើបតែសាងសង់បានចំនួន១.២៤៩សាលារៀនប៉ុណ្ណោះ បើប្រៀបធៀបនឹងឆ្នាំ២០១៤ មានការកើនឡើងសាលារៀនអនុវិទ្យាល័យចំនួន៤។ ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលបានសន្យាថា នឹងបន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ (ឃុំមួយអនុវិទ្យាល័យមួយ)។ ទោះជាយ៉ាងណាក៏ដោយ ការសន្យារបស់រាជរដ្ឋាភិបាល គឺសម្រាប់រយៈពេលមួយអាណត្តិនៃនីតិកាលទី៥ តែបើមើលពីកំណើនចំនួនសាលាអនុវិទ្យាល័យនៅឆ្នាំ ២០១៥ ធៀបនឹងឆ្នា២០១៤ រាជរដ្ឋាភិបាលប្រហែលជាពិបាកនឹងជំនះលើបេសកកម្មនេះបន្តិច។

សេចក្តីសន្និដ្ឋាន រាជរដ្ឋាភិបាលសម្រេចបានខ្លះនូវគោលយោបាយបន្តកសាងអនុវិទ្យាល័យ ឲ្យបានគ្រប់ឃុំ (*ឃុំមួយ អនុវិទ្យាល័យមួយ*)។

## *១៥. រៀបចំគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារស្របទៅនឹងការវិវឌ្ឍន៍នៃសង្គម-សេដ្ឋកិច្ច។*[70]

កាលពីឆ្នាំ២០១៤ តាមព័ត៌មានពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារក្នុងស្ថិតនៅក្នុងដំណើរការបង្កើត ហើយក្រសួងបានកំណត់ត្រឹមឆ្នាំចុង២០១៥ ដើម្បីឲ្យគោលនយោបាយនេះនឹងត្រូវបានបង្កើតឲ្យរួចរាល់។ ក្រសួងការងារបានទទួលគោលការណ៍ពី រាជរដ្ឋាភិបាល និងបានទទួលសេចក្តីសម្រេចពីទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបង្កើតគណៈកម្មការអន្តរក្រសួង ដែលមានសមាសភាពមកពីក្រសួង អង្គការ សមាគម តំណាងសហជីព និយោជកដែលពាក់ព័ន្ធក្នុងវិស័យការងារធ្វើការសិក្សាបង្កើតគោលនយោបាយនេះ។

នៅឆ្នាំ២០១៥នេះ គោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារត្រូវបានប្រជុំសម្រេចក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីថ្ងៃទី០៤ ខែកញ្ញា។ គោលនយោបាយនេះបង្កើត បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោល

---

69 *Education Statistics & Indicators 2014-2015*, Ministry of Education Youth and Sports, Cambodia, at 1and 5
70 *Supra* note 10, at 46.

នយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ គោលនយោបាយជាតិ ស្ដីពីមុខរបរ និងការងារត្រូវដាក់ឲ្យអនុវត្តជាផ្លូវការ។

សេចក្ដីសន្និដ្ឋានក្នុងការអនុវត្តន៍គោលនយោបាយក្នុងឆ្នាំទី២នេះ រាជរដ្ឋាភិបាលបានសម្រេចនូវការរៀបចំគោលនយោបាយជាតិ ស្ដីពីមុខរបរ និងការងារ ស្របទៅនឹងការវិវឌ្ឍន៍នៃសង្គម-សេដ្ឋកិច្ច។

### *១៦. ការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍ សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជនឲ្យទទួលបានរបបប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការដែរ ចាប់ពីឆ្នាំ ២០១៥។*[71]

រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តប្រព័ន្ធរបបសន្តិសុខសង្គម ក៏ប៉ុន្តែដំណើរការនេះនៅមានភាពស្មុគស្មាញ និងការផ្ដល់សេវានៅមានភាពមិនច្បាស់លាស់។ នៅក្នុងនីតិកាលទី៤ គេឃើញមានការបង្កើតប្រព័ន្ធរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ ប៉ុន្តែពុំទាន់ឃើញមានច្បាប់ច្បាស់លាស់នៅឡើយ បើទោះបីជាមានយន្តការអនុវត្តដោយឡែកតាមក្រសួងនីមួយៗក៏ដោយ។

ក្នុងច្បាប់ ស្ដីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ ស្ដីពីការងារ បានចែងពីរបបសន្តិសុខសង្គមចំនួនពីរប្រភេទ គឺរបបធានារ៉ាប់រងហានិភ័យការងារ និងរបបសោធននិវត្តន៍។ ដើម្បីអនុវត្តច្បាប់នេះ អនុក្រឹត្យ ស្ដីពីបេឡាជាតិរបបសន្តិសុខសង្គមលេខ១៦អនក្រ-បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ការងារធានារ៉ាប់រងហានិភ័យការងារក៏ត្រូវបានបង្កើត ហើយគេឃើញមានដំណើរការអនុវត្តន៍របបធានារ៉ាប់រងហានិភ័យការងារផងដែរ។ ក្រៅពីរបបទាំងពីរនេះ គេឃើញមានរបបសន្តិសុខសង្គមមួយទៀតដែលត្រូវបានបញ្ញត្តិក្នុងច្បាប់ ស្ដីពីការងារ គឺរបបថែទាំសុខភាព ហើយនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពនេះ តាមរយៈអនុក្រឹត្យលេខ០១ អ.ន.ក្រ.ប.ក។

រាជរដ្ឋាភិបាលនីតិកាលទី៥បានសន្យា ក្នុងគោលនយោបាយរបស់ខ្លួនថា នឹងដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជនឲ្យទទួលបានរបបប្រាក់សោធននិវត្តន៍ ដូចមន្ត្រីរាជការដែលចាប់ពីឆ្នាំ២០១៥។ រាជរដ្ឋាភិបាលមិនទាន់រៀបចំឲ្យមានដំណើរការរបបប្រាក់សោធននិវត្តន៍ សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន។

សេចក្ដីសន្និដ្ឋាន រាជរដ្ឋាភិបាលមិនសម្រេចនូវការសន្យា ការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជនឲ្យទទួលបានរបបប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការដែរ ចាប់ពីឆ្នាំ ២០១៥ នោះទេ។

## 2. ការផ្ដល់ពិន្ទុការបំពេញ/អនុវត្តន៍គោលនយោបាយ

ការផ្ដល់ពិន្ទុលើការបំពេញ ឬអនុវត្តន៍គោលនយោបាយមិនមានសូចនាករច្បាស់លាស់ ត្រូវបានយកមកប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតធ្វើការបោះឆ្នោតវាយតម្លៃ។ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅ ២៤ រាជធានីខេត្ត លើកលែងខេត្តកោះកុងដែលមានចំនួនសរុបប្រមាណ៧៩៧នាក់ បានផ្ដល់ពិន្ទុសម្រាប់រយៈពេលមួយឆ្នាំ (ចាប់ពីខែមករា ឆ្នាំ២០១៥ ដល់ខែធ្នូ ឆ្នាំ២០១៥)នៃលទ្ធផលនៃការបំពេញ ឬអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី២។

ការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន៣៣ចំណុច ដែលមិនមានសូចនាករច្បាស់លាស់ ត្រូវបានឲ្យប្រជាពលរដ្ឋផ្ដល់ពិន្ទុដោយប្រើប្រាស់ម៉ាស៊ីនផ្ដល់ពិន្ទុ តាមអញ្ញត្តិដូចខាងក្រោម៖

[71] *Ibid.*

| អញ្ញត្តិ | តម្លៃ | ភាគរយនៃការពេញចិត្ត |
|---|---|---|
| ១ | មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | ០-២០% |
| ២ | ពេញចិត្តខ្លះ | ២១%-៤០% |
| ៣ | ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | ៤១%-៦០% |
| ៤ | ពេញចិត្តច្រើន | ៦១%-៨០% |
| ៥ | ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | ៨១%-១០០% |

លទ្ធផលដែលទទួលបានពីការផ្តល់ពិន្ទុមានដូចខាងក្រោម៖

## ក. វិស័យទី១៖ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

| កម្រិតនៃការពេញចិត្ត | លើកទី១[72] (%) | លើកទី២[73] (%) |
|---|---|---|
| 1.មិនពេញចិត្តទាល់តែសោះឬពេញចិត្តតិចតួច | 11.82% | 14.80% |
| 2.ពេញចិត្តខ្លះ | 27.33% | 28.47% |
| 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 29.16% | 31.27% |
| 4.ពេញចិត្តច្រើន | 21.19% | 17.09% |
| 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 10.51% | 8.37% |

| កម្រិតនៃការពេញចិត្តជាមធ្យមនៃវិស័យទី១ (Mean)[74] | លើកទី១ | លើកទី២ |
|---|---|---|
| | 2.08 | 1.82 |

ឆ្លើយតបនឹងការពង្រឹងកិច្ចការពារអធិបតេយ្យជាតិ និងការពារសន្តិសុខជាតិ តាមរយៈគោលនយោបាយ «ភូមិ-ឃុំមានសុវត្ថិភាព» ការដោះស្រាយបញ្ហាជនអន្តោប្រវេសន៍របស់រាជរដ្ឋាភិបាល ប្រជាពលរដ្ឋមានការពេញចិត្តខ្លះ និងពេញចិត្តមធ្យមចំពោះការអនុវត្តន៍/បំពេញគោលនយោបាយនេះ។ បើគិតពីកម្រិតមធ្យមនៃការពេញចិត្តសំរាប់ការផ្តល់ពិន្ទុលើកទី១ ប្រជាពលរដ្ឋមានការពេញចិត្តខ្លះ (Mean[75] = ២.០៨) និងសំរាប់ផ្តល់ពិន្ទុលើកទី២ (Mean = ១.៨២)។

## ខ. វិស័យទី២៖ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ

| កម្រិតនៃការពេញចិត្ត | លើកទី១[76] (%) | លើកទី២[77] (%) |
|---|---|---|

[72] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន

[73] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន និងព័ត៌មានដែលទទួលបានពីវាគ្មិន (ក្រោយពេលពិភាក្សា)

[74] 1 ដល់ 1.5: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច, 1.6 ដល់ 2.5: ពេញចិត្តខ្លះ, 2.6 ដល់ 3.5: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល, 3.6 ដល់ 4.5: ពេញចិត្តច្រើន, 4.6 ដល់ 5: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង

[76] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន

[77] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន និងព័ត៌មានដែលទទួលបានពីវាគ្មិន (ក្រោយពេលពិភាក្សា)

| | | |
|---|---|---|
| 1.មិនពេញចិត្តទាល់តែសោះឬពេញចិត្តតិចតួច | 12.17% | 14.39% |
| 2.ពេញចិត្តខ្លះ | 31.06% | 31.58% |
| 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 28.05% | 30.14% |
| 4.ពេញចិត្តច្រើន | 21.43% | 18.78% |
| 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 7.28% | 5.09% |

| **កម្រិតនៃការពេញចិត្តជាមធ្យមនៃវិស័យទី២** (Mean)[78] | លើកទី១ | លើកទី២ |
|---|---|---|
| | 2.27 | 2.14 |

ទិន្នន័យខាងលើបង្ហាញថា មានប្រជាពលរដ្ឋភាគច្រើនជាងគេប្រមាណ៣១%ពេញចិត្តខ្លះ ចំពោះការបំពេញ/អនុវត្តន៍ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ។ ខណៈដែលភាគរយនៃការពេញចិត្តមធ្យម ឬពាក់កណ្តាលមានចំនួនច្រើនបន្ទាប់ គឺប្រមាណ២៩%។ បើមើលពីកម្រិតនៃការពេញចិត្តជាមធ្យមវិញ មានកម្រិតពេញចិត្តខ្លះតែប៉ុណ្ណោះ ពោលគឺ Mean=២.២៧ សម្រាប់ការផ្តល់ពិន្ទុលើកទី១ និង Mean=២,១៤ សម្រាប់ការផ្តល់ពិន្ទុលើកទី២។

## គ. វិស័យទី3៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ច

| **កម្រិតនៃការពេញចិត្ត** | **លើកទី១**[79] (%) | **លើកទី២**[80] (%) |
|---|---|---|
| 1.មិនពេញចិត្តទាល់តែសោះឬពេញចិត្តតិចតួច | 10.08% | 11.65% |
| 2.ពេញចិត្តខ្លះ | 28.54% | 34.41% |
| 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 37.41% | 32.96% |
| 4.ពេញចិត្តច្រើន | 18.91% | 16.57% |
| 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 5.06% | 4.41% |

| **កម្រិតនៃការពេញចិត្តជាមធ្យមនៃវិស័យទី៣** (Mean)[81] | លើកទី១ | លើកទី២ |
|---|---|---|
| | 2.44 | 2.29 |

[78] 1 ដល់ 1.5: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច, 1.6 ដល់ 2.5: ពេញចិត្តខ្លះ, 2.6 ដល់ 3.5: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល, 3.6 ដល់ 4.5: ពេញចិត្តច្រើន, 4.6 ដល់ 5: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង

[79] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន

[80] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន និងព័ត៌មានដែលទទួលបានពីវាគ្មិន (ក្រោយពេលពិភាក្សា)

[81] 1 ដល់ 1.5: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច, 1.6 ដល់ 2.5: ពេញចិត្តខ្លះ, 2.6 ដល់ 3.5: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល, 3.6 ដល់ 4.5: ពេញចិត្តច្រើន, 4.6 ដល់ 5: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង

ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ ដើម្បីអភិវឌ្ឍន៍វិស័យជាច្រើន ដូចជាកសិកម្ម ឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម ដីធ្លី សំណង់ រ៉ែ ឧស្ម័ន ថាមពល ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ទូរគមនាគមន៍ ទេសចរណ៍ បរិស្ថាន។ យោងតាមទិន្នន័យខាងលើ ប្រជាពលរដ្ឋភាគច្រើនពេញចិត្តមធ្យម ឬពាក់កណ្តាលដែលមានប្រមាណ៣៥%នៃប្រជាពលរដ្ឋ ដែលបានផ្តល់ពិន្ទុចំពោះការបំពេញគោលនយោបាយនៃការអភិវឌ្ឍន៍វិស័យទាំងនោះរបស់រាជរដ្ឋាភិបាល។ ប៉ុន្តែកម្រិតមធ្យមនៃការពេញចិត្តនៃប្រជាពលរដ្ឋ ដែលបានផ្តល់ពិន្ទុទាំងអស់វិញ គឺត្រឹមកម្រិតពេញចិត្តខ្លះតែប៉ុណ្ណោះ។ ការផ្តល់ពិន្ទុលើកទី១ Mean = ២.៤៤ និងការផ្តល់ពិន្ទុលើកទី២ Mean = ២.២៩។

## ឃ. វិស័យទី4៖ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច

| **កម្រិតនៃការពេញចិត្ត** | **លើកទី១**[82] (%) | **លើកទី២**[83] (%) |
|---|---|---|
| 1.មិនពេញចិត្តទាល់តែសោះឬពេញចិត្តតិចតួច | 8.99% | 10.88% |
| 2.ពេញចិត្តខ្លះ | 26.68% | 31.74% |
| 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 33.54% | 33.49% |
| 4.ពេញចិត្តច្រើន | 23.15% | 16.76% |
| 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 7.65% | 7.11% |

| **កម្រិតនៃការពេញចិត្តជាមធ្យមនៃវិស័យទី៤** (Mean)[84] | លើកទី១ | លើកទី២ |
|---|---|---|
| | 2.41 | 2.34 |

សម្រាប់វិស័យទី៤នេះវិញ ប្រជាពលរដ្ឋធ្វើការផ្តល់ពិន្ទុ ហាក់ដូចជាមិនខុសឆ្ងាយពីវិស័យទី៣នោះទេ។ ប្រជាពលរដ្ឋដែលពេញចិត្តមធ្យម ឬពាក់កណ្តាលមានចំនួនច្រើនជាងគេ។ ប៉ុន្តែមធ្យមភាគនៃការពេញចិត្តនៃប្រជាពលរដ្ឋដែលបានផ្តល់ពិន្ទុទាំងអស់នោះ គឺត្រឹមកម្រិតពេញចិត្តខ្លះ ដូចគ្នានឹងវិស័យទី៣ដែរ។ ការផ្តល់ពិន្ទុលើកទី១ Mean = ២,៤១ រីឯសម្រាប់ការផ្តល់ពិន្ទុលើកទី២ Mean = ២,៣៤។

## ង. គោលនយោបាយទាំង៤វិស័យ៖

ខាងក្រោមនេះ គឺជាលទ្ធផលមធ្យមនៃវិស័យទាំង៤៖

| **កម្រិតនៃការពេញចិត្ត** | **លើកទី១**[85] (%) | **លើកទី២**[86] (%) |
|---|---|---|

[82] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន

[83] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន និងព័ត៌មានដែលទទួលបានពីវាគ្មិន (ក្រោយពេលពិភាក្សា)

[84] 1 ដល់ 1.5: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច, 1.6 ដល់ 2.5: ពេញចិត្តខ្លះ;, 2.6 ដល់ 3.5: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល, 3.6 ដល់ 4.5: ពេញចិត្តច្រើន, 4.6 ដល់ 5: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង

[85] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន

[86] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន និងព័ត៌មានដែលទទួលបានពីវាគ្មិន (ក្រោយពេលពិភាក្សា)

| | | |
|---|---|---|
| 1.មិនពេញចិត្តទាល់តែសោះឬពេញចិត្តតិចតួច | 10.76% | 12.93% |
| 2.ពេញចិត្តខ្លះ | 28.40% | 31.55% |
| 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 32.04% | 31.96% |
| 4.ពេញចិត្តច្រើន | 21.17% | 17.30% |
| 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 7.62% | 6.25% |

| **កម្រិតនៃការពេញចិត្តជាមធ្យមនៃទាំង៤វិស័យ** (Mean)[87] | លើកទី១ | លើកទី២ |
|---|---|---|
| | 1.84 | 1.72 |

ប្រជាពលរដ្ឋប្រមាណជា៣២%នៃអ្នកផ្តល់ពិន្ទុ ពេញចិត្តមធ្យម ឬពាក់កណ្តាល ចំណែកឯ៣០%ពេញចិត្តខ្លះ ២០% ពេញចិត្តច្រើន និងប្រហែល៧% ពេញចិត្តទាំងស្រុង។ ផ្ទុយមកវិញប្រមាណ១២% មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច។ ចំណែកឯកម្រិតនៃការពេញចិត្តជាមធ្យមវិញ គឺស្ថិតនៅក្នុងកម្រិតពេញចិត្តខ្លះដែរ។ ការផ្តល់ពិន្ទុលើកទី១ Mean= ១,៨៤ ហើយការផ្តល់ពិន្ទុលើកទី២ Mean= ១,៧២។

## ទំនាក់ទំនងរវាងខេត្ត និងការផ្តល់ពិន្ទុ៖

ក្នុងចំណោម២៤រាជធានី/ខេត្ត ដែលប្រជាពលរដ្ឋកំពុងរស់នៅបានផ្តល់ពិន្ទុ មានខេត្តចំនួន០៥ ដូចជា៖ បន្ទាយមានជ័យ កំពង់ធំ កណ្តាល ស្វាយរៀង និងឧត្តរមានជ័យតែប៉ុណ្ណោះ ហាក់ដូចជាមិនមានប្រជាពលរដ្ឋមិនពេញចិត្តទាល់តែសោះ ឬពេញតិចតួច។ លទ្ធផលនៃការផ្តល់ពិន្ទុលើកទី១បានបង្ហាញថា មិនមានប្រជាពលរដ្ឋណាម្នាក់ ក្នុងចំណោមខេត្តទាំងនោះបានផ្តល់ពិន្ទុអញ្ញត្តិទី១ គឺមិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួចនោះទេ។ ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនតូចក្នុងខេត្តចំនួន០៣នៃខេត្តទាំង០៥នោះ បានផ្តល់ពិន្ទុក្នុងអញ្ញត្តិនេះទៅវិញក្នុងការផ្តល់ពិន្ទុលើកទី២។

## ការប្រៀបធៀបលទ្ធផលឆ្នាំ២០១៤ និង ២០១៥ នៅរាជធានីភ្នំពេញ

ក្នុងចំណោម២៤រាជធានីខេត្ត យើងអាចធ្វើការប្រៀបធៀបលទ្ធផលនៃការផ្តល់ពិន្ទុឆ្នាំ២០១៤ ទៅនឹងឆ្នាំ ២០១៥ នៃរាជធានីភ្នំពេញដែលមានវិធីសាស្ត្ររៀបចំឲ្យប្រជាពលរដ្ឋផ្តល់ពិន្ទុដូចគ្នា។

| **ឆ្នាំ** | **ការផ្តល់ពិន្ទុលើកទី១ (គិតជា%)** | | | | | **ការផ្តល់ពិន្ទុលើកទី២ (គិតជា%)** | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង |

[87] 1 ដល់ 1.5: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច, 1.6 ដល់ 2.5: ពេញចិត្តខ្លះ, 2.6 ដល់ 3.5: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល, 3.6 ដល់ 4.5: ពេញចិត្តច្រើន, 4.6 ដល់ 5: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| **២០១៥** | 45.42 | 28.23 | 16.20 | 5.87 | 4.27 | 55.90 | 25.75 | 10.96 | 3.18 | 4.24 |
| **២០១៤** | 48.7 | 27.3 | 11.3 | 5.3 | 7.3 | 63.1 | 23.9 | 8.2 | 1.5 | 3.3 |

**ការប្រៀបធៀបលទ្ធផលជាមធ្យមនៃការពេញចិត្តនៅរាជធានីភ្នំពេញចំពោះការអនុវត្តន៍/បំពេញគោលនយោបាយ របស់រាជរដ្ឋាភិបាលឆ្នាំ២០១៤ និងឆ្នាំ២០១៥**

| **ឆ្នាំ** | **មិនពេញចិត្ត**[88] | **ពេញចិត្តខ្លះ**[89] | **ពេញចិត្ត**[90] |
|---|---|---|---|
| ២០១៥ | 50.66% | 40.57% | 8.78% |
| ២០១៤ | 55.9% | 35.35% | 8.70% |

ក្នុងឆ្នាំ២០១៥ ចំនួនប្រជាពលរដ្ឋមិនចិត្តនឹងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ធ្លាក់ចុះពី ៥៥% នៅឆ្នាំ២០១៤ មកត្រឹម៥០% ផ្ទុយមកវិញចំនួនប្រជាពលរដ្ឋពេញចិត្តខ្លះកើនឡើងពី៣៥% ទៅ៤០%។ ដូចនេះ ប្រជាពលរដ្ឋដែលផ្តល់ពិន្ទុនៅរាជធានីភ្នំពេញចំនួន៥% បានប្រែលប្រួលពីមិនពេញចិត្ត ទៅពេញចិត្តខ្លះ ខណៈដែលចំនួនប្រជាពលរដ្ឋពេញចិត្តនឹងការអនុវត្តន៍គោលនយោបាយទាំងនោះ មិនមានការប្រែប្រួលនោះទេ នេះបើប្រៀបធៀបការផ្តល់ពិន្ទុលើកឆ្នាំ២០១៤ និងឆ្នាំ២០១៥។

## ច. លទ្ធផលជាមធ្យមនៃការពេញចិត្តចំពោះការអនុវត្តន៍/បំពេញគោលនយោបាយ របស់រាជរដ្ឋាភិបាល៖

ទិន្នន័យខាងក្រោមបង្ហាញពីកំរិតនៃការពេញចិត្ត ពេញចិត្តខ្លះ និងមិនពេញចិត្តចំពោះវិស័យនីមួយៗនៃការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំទី២។ លទ្ធផលនេះ ជាតម្លៃមធ្យមនៃការផ្តល់ពិន្ទុលើកទី១ និងទី២នៃការផ្តល់ពិន្ទុនៅ២៤រាជធានី/ខេត្ត។ តម្លៃនៃការ**ពេញចិត្ត**ក្នុងតារាងខាងក្រោម គឺជាការបូកបញ្ចូលតម្លៃនៃការផ្តល់ពិន្ទុអញ្ញតទី៤ (ពេញចិត្តច្រើន) និងទី៥(ពេញចិត្តស្ទើរទាំងស្រុង ឬទាំងស្រុង) ហើយតម្លៃនៃការ**ពេញចិត្តខ្លះ** គឺជាការបូកបញ្ចូលតម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី២ (ពេញចិត្តខ្លះ) និងទី៣(ពេញចិត្តមធ្យម ឬពាក់កណ្តាល)។ ចំណែកឯតម្លៃនៃការ**មិនពេញចិត្ត** គឺជាតម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី១(មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច)។

| ល.រ | **វិស័យនៃគោលនយោបាយ** | **មិនពេញចិត្ត**[91] | **ពេញចិត្តខ្លះ**[92] | **ពេញចិត្ត**[93] |
|---|---|---|---|---|
| ០១ | ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | 13.31% | 58.11% | 28.58% |
| ០២ | ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ | 13.28% | 60.42% | 26.29% |

[88] តម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី១(មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច)

[89] ផលបូកតម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី ២(ពេញចិត្តខ្លះ) និងទី៣(ពេញចិត្តមធ្យម ឬពាក់កណ្តាល)

[90] ផលបូកបញ្ចូល តម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី៤(ពេញចិត្តច្រើន) និងទី៥(ពេញចិត្តស្ទើរទាំងស្រុង ឬទាំងស្រុង)

[91] តម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី១(មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច)

[92] ផលបូកតម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី ២(ពេញចិត្តខ្លះ) និងទី៣(ពេញចិត្តមធ្យម ឬពាក់កណ្តាល)

[93] ផលបូកបញ្ចូល តម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី៤(ពេញចិត្តច្រើន) និងទី៥(ពេញចិត្តស្ទើរទាំងស្រុង ឬទាំងស្រុង)

| | | | | |
|---|---|---|---|---|
| ០៣ | ការអភិវឌ្ឍន៍សេដ្ឋកិច្ច | 10.86% | 66.66% | 22.48% |
| ០៤ | ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច | 9.93% | 62.73% | 27.33% |
| ០៥ | គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥ (ទាំងបួនវិស័យ) | 11.84% | 61.98% | 26.17% |

ទិន្នន័យក្នុងតារាងខាងលើបង្ហាញថា វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ មានប្រជាពលរដ្ឋចំនួន២៨% ពេញចិត្ត៥៨% ពេញចិត្តខ្លះ និង១៣% មិនពេញចិត្ត។ ចំណែកឯវិស័យពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ ត្រូវបានផ្តល់ពិន្ទុដោយប្រជាពលរដ្ឋចំនួន២៦%ពេញចិត្ត ៦០%ពេញចិត្តខ្លះ និង១៣%មិនពេញចិត្ត។ វិស័យការអភិវឌ្ឍន៍សេដ្ឋកិច្ចវិញ ក៏ត្រូវបានប្រជាពលរដ្ឋចំនួន២២%ពេញចិត្ត ៦៦%ពេញចិត្តខ្លះ និង១០%មិនពេញចិត្ត។ ជាមួយគ្នានោះដែរ វិស័យការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ចត្រូវបានប្រជាពលរដ្ឋចំនួន២៧%ពេញចិត្ត ៦២%ពេញចិត្តខ្លះ និង៩%មិនពេញចិត្ត។

ខាងក្រោមនេះជាទិន្នន័យនៃការពន្យល់បន្ថែម៖

| **កម្រិតនៃការពេញចិត្ត** | **លទ្ធផលមធ្យមនៃការផ្តល់ពិន្ទុលើកទី១ និងទី២** (%) | | | | |
|---|---|---|---|---|---|
| | វិស័យទី១ | វិស័យទី២ | វិស័យទី៣ | វិស័យទី៤ | វិស័យទាំង៤ |
| 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 13.31% | 13.28% | 10.86% | 9.93% | 11.84% |
| 2.ពេញចិត្តខ្លះ | 27.90% | 31.32% | 31.48% | 29.21% | 29.98% |
| 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 30.21% | 29.09% | 35.18% | 33.51% | 32.00% |
| 4.ពេញចិត្តច្រើន | 19.14% | 20.11% | 17.74% | 19.95% | 19.24% |
| 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 9.44% | 6.19% | 4.74% | 7.38% | 6.94% |

បើមើលពីថវិកាដែលគ្រោងនឹងចំណាយឆ្នាំ២០១៥ ចំនួន៣.៧៥៨លានដុល្លារសហរដ្ឋអាមេរិក ដែលបានកើនឡើងប្រមាណជា៩,៥% ធៀបនឹងឆ្នាំ២០១៤ រាជរដ្ឋាភិបាលគ្រោងចំណាយថវិកាលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចប្រមាណ២៨%នៃថវិកាជាតិ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ថវិកាដែលគ្រោងចំណាយលើវិស័យសេដ្ឋកិច្ចកើនឡើងច្រើន គឺ៩%នៅឆ្នាំ២០១៤ ដល់២៨%នៅឆ្នាំ២០១៥។ ចំណែកវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ រាជរដ្ឋាភិបាលគ្រោងចំណាយ១៦% និងវិស័យរដ្ឋបាលទូទៅចំនួន១១%នៃថវិកាជាតិសរុបដែលរួមបញ្ចូលទាំងថវិកាមិនទាន់បែងចែង។

បើពិនិត្យជារួម សម្រាប់ឆ្នាំទី២រាជរដ្ឋាភិបាលទី៥ ដែលរដ្ឋសភាបានអនុម័តថវិកាចំនួន១៥.០៣៥.២២៩លានរៀល (ប្រហែល៣.៧៥៨លានដុល្លារសហរដ្ឋអាមេរិក) ដើម្បីអនុវត្តគោលនយោបាយរបស់ខ្លួន មានប្រជាពលរដ្ឋចំនួនប្រមាណ២៦%ពេញចិត្ត ប្រមាណ៦២%ពេញចិត្តខ្លះ និងប្រមាណ១២%មិនពេញចិត្ត ចំពោះការ

បំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥។

សម្រាប់ឆ្នាំ២០១៥នេះ រាជរដ្ឋាភិបាលផ្តល់អាទិភាពចំណាយខ្ពស់ទៅលើវិស័យចំនួនពីរ គឺវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច បើប្រៀបធៀបជាមួយវិស័យផ្សេងទៀត។ ថវិកាចំណាយលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចភាគច្រើន ត្រូវបានយកទៅបែងចែកទៅក្រសួងពាក់ព័ន្ធដូចជា៖ ក្រសួងរ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍ និងក្រសួងសិប្បកម្ម ឧស្សាហកម្ម ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងសង្គមកិច្ច អតីតយុវជន និងនីតិសម្បទា ក្រសួងធម្មការ និងសាសនា ក្រសួងកិច្ចការនារី និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាដើម។

ចំណែកឯវិស័យផ្សេងមួយទៀត ដែលរាជរដ្ឋាភិបាលបានគ្រោងចំណាយថវិកាជាតិមានចំនួន១៦,២៤% ច្រើនលំដាប់ទី២ គឺវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ ថវិកាត្រូវបានផ្តល់ទៅក្រសួងការពារជាតិ ក្រសួងមហាផ្ទៃផ្នែកសន្តិសុខសាធារណៈ និងក្រសួងយុត្តិធម៌ផងដែរ។ លទ្ធផលនៃការពេញចិត្តរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តន៍គោលនយបាយការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គឺមិនល្អប្រសើរឡើយ បើធៀបនឹងការចំណាយថវិកាលើវិស័យនេះ ពីព្រោះចំនួនប្រជាពលរដ្ឋដែលផ្តល់ពិន្ទុមិនពេញចិត្តលើវិស័យនេះ ច្រើនជាងវិស័យការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពំពើពុករលួយ ដែលហាក់ដូចត្រូវបានចំណាយថវិកាតិចជាងវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈប្រមាណ៥%។

## VI. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥ ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានសម្រេចការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ (៣៧,៥%)នៃ១៦គោលនយោបាយ ដែលមានសូចនាករច្បាស់លាស់រួមមាន ដូចជា៖ កំណើនកំណើនសេដ្ឋកិច្ច៧%ក្នុងមួយឆ្នាំ ការកាត់បន្ថយភាពក្រីក្រក្នុងអត្រា០១%ក្នុងមួយឆ្នាំ ការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង គោលដៅនៃចំនួនទេសចរណ៍ពីក្រៅប្រទេស និងការបង្កើតគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ។

ចំណែកឯគោលនយោបាយចំនួន០៧ រាជរដ្ឋាភិបាលអនុវត្ត ឬ/និងសម្រេចបានខ្លះ។ គោលនយោបាយទាំងនោះមានដូចជា ការរក្សាផ្ទៃនេសាទទឹកសាប ការចុះបញ្ជីដីធ្លី ការកសាងគោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅស្ថាន ប្រជាជនទទួលសេវាទឹកស្អាត ពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ ការបន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ ការនាំអង្ករចេញឲ្យបាន០១លានតោននៅឆ្នាំ២០១៥។ ប៉ុន្តែគោលនយោបាយចំនួន០៣ រាជរដ្ឋាភិបាលបានអនុវត្ត តែមិនអាចសម្រេចបាន ឬបានតិចតួចតាមការសន្យារបស់ខ្លួន។ គោលនយោបាយទាំងនោះមានដូចជា គោលនយោបាយការរក្សាផ្ទៃដី ដែលគ្របដណ្តប់ដោយព្រៃឈើ ការកែលម្អផ្លូវលំជនបទជាជំហានៗ និងការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន។

បើប្រៀធៀបជាមួយការបំពេញ/អនុវត្តន៍គោលនយោបាយក្នុងឆ្នាំទី១ រាជរដ្ឋាភិបាលសម្រេចបានចំនួន៦ចំណុចនៃ១៦ចំណុចដូចគ្នា។ នៅក្នុងឆ្នាំទី១ រាជរដ្ឋាភិបាលបានសម្រេចគោលនយោបាយកែលម្អផ្លូវលំជនបទ ប៉ុន្តែនៅក្នុងឆ្នាំទី២នេះ ការអនុវត្តន៍គោលនយោបាយនេះមិនបានសម្រេច ឬបានតិចតួច ខណៈដែលគោលនយោបាយការរៀបចំគោលនយោបាយជាតិ ស្តីពីមុខរបប និងការងារត្រូវបានរាជរដ្ឋាភិបាលអនុវត្តបានសម្រេច។

ចំណែកការផ្តល់ពិន្ទុលើ លទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ មិនមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល ដោយប្រជាពលរដ្ឋនៅ២៤រាជធានី/ខេត្ត លើវិស័យទាំង០៤រួមមាន៖ វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ វិស័យការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ វិស័យការអភិវឌ្ឍន៍សេដ្ឋកិច្ច និងវិស័យការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច បើធៀបការផ្តល់ពិន្ទុលើកទី១ កំរិតពេញចិត្តជាមធ្យម នៅក្នុងការផ្តល់ពិន្ទុកលើកទី២ធ្លាក់ចុះ។ ក្រោយពីទទួលបានព័ត៌មានពីវាគ្មិននូវការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ប្រជាពលរដ្ឋប្រែប្រួលការវាយតម្លៃរបស់ខ្លួនកាន់តែអវិជ្ជមាន លើការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ឆ្នាំទី២។

គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥ ដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និងចំណាយថវិកាជាតិប្រមាណ៣.៧៥៨លានដុល្លារសហរដ្ឋអាមេរិក ដើម្បីបំពេញ/អនុវត្តន៍ក្នុងឆ្នាំទី២នៃនីតិកាលទី៥ កន្លងមកនេះ មានប្រជាពលរដ្ឋនៅ២៤ខេត្ត/រាជធានី ដែលចូលរួមផ្តល់ពិន្ទុចំនួនប្រមាណ២៦%ពេញចិត្ត ប្រមាណ៦២%ពេញចិត្តខ្លះ និងប្រមាណ១២%មិនពេញចិត្ត ចំពោះការបំពេញ/អនុវត្តន៍គោលនយបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥។ ដោយឡែក ប្រជាពលរដ្ឋដែលផ្តល់ពិន្ទុនៅរាជធានីភ្នំពេញចំនួន៥% បានប្រែប្រួលពីមិនពេញចិត្ត ទៅពេញចិត្ត ខណៈដែលចំនួនប្រជាពលរដ្ឋពេញចិត្តនឹងការអនុវត្តន៍គោលនយោបាយទាំងនោះ មិនមានការប្រែប្រួលនោះទេ នេះបើប្រៀបធៀបការផ្តល់ពិន្ទុលើកឆ្នាំ២០១៤ និងឆ្នាំ២០១៥។

## ឧបសម្ព័ន្ធ

- **វិធីសាស្ត្រ និងទំហំនៃរបាយការណ៍**

របាយការណ៍ ស្តីពីការឃ្លាំមើល និងការផ្តល់ពិន្ទុលើលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី២មានចំនួនពីរផ្នែក ដែលកើតចេញពីការវិភាគលើទិន្នន័យ និងព័ត៌មាន និងការផ្តល់ពិន្ទុ។ ផ្នែកទី១នៃរបាយការណ៍នេះ ផ្អែកលើព័ត៌មាន ឬទិន្នន័យដែលមានស្រាប់មកពីប្រព័ន្ធផ្សព្វផ្សាយរបាយការណ៍បឋមរបស់អង្គការជាតិ និងអន្តរជាតិ សារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងស្ថាប័នជាតិ និងអន្តរជាតិផ្សេងៗដែលពាក់ព័ន្ធនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៥។ គោលនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី០៥ ដែលមានសូចនាករច្បាស់លាស់ត្រូវបានវិភាគ និងវាយតម្លៃ។

សម្រាប់មួយផ្នែកផ្សេងទៀតនៃរបាយការណ៍នេះ គឺការរកឃើញកើតចេញពីការឃើញនៃការផ្តល់ពិន្ទុលើការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។ វេទិកាម្ចាស់ឆ្នោតចំនួន២៤ ត្រូវបានរៀបចំឡើងនៅក្នុងខេត្ត/រាជធានីទាំង២៤ មានប្រជាពលរដ្ឋចូលរួមចំនួនប្រមាណ៧៩៧នាក់ ដើម្បីឲ្យប្រជាពលរដ្ឋផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ ដែលមិនមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល។ ការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន៣៣ចំណុច ដែលមិនមានសូចនាករច្បាស់លាស់ ត្រូវបានឲ្យប្រជាពលរដ្ឋផ្តល់ពិន្ទុ ដោយប្រើប្រាស់ម៉ាស៊ីនផ្តល់ពិន្ទុតាមអញ្ញត្តិដូចខាងក្រោម៖

| **អញ្ញត្តិ** | **តម្លៃ** | **ភាគរយនៃការពេញចិត្ត** |
|---|---|---|
| ១ | មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 0-២0% |
| ២ | ពេញចិត្តខ្លះ | ២១%-៤0% |
| ៣ | ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | ៤១%-៦0% |

| | | |
|---|---|---|
| ៤ | ពេញចិត្តច្រើន | ៦១%-៨០% |
| ៥ | ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | ៨១%-១០០% |

ប្រជាពលរដ្ឋបានធ្វើការផ្តល់ពិន្ទុចំនួនពីរលើក ចំពោះការលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ។ ការផ្តល់ពិន្ទុលើកទី១ ផ្អែកលើព័ត៌មាន ឬចំណេះដឹងរបស់ប្រជាពលរដ្ឋផ្ទាល់ ចំណែកឯការផ្តល់ពិន្ទុលើកទី២ ផ្អែកលើព័ត៌មាន ឬចំណេះដឹងរបស់ប្រជាពលរដ្ឋ រួមទាំងព័ត៌មានដែលបានផ្តល់ជូនដោយវាគ្មិនរួមមាន៖ តំណាងរាស្ត្រ តំណាងអង្គការសង្គមស៊ីវិល និងអ្នកជំនាញឯករាជ្យដែលធ្វើការពាក់ព័ន្ធនឹងការតាមដានការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។

- **លក្ខណៈគោលនយោបាយ និងគោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥ (សង្ខេប)**

សម្រាប់នីតិកាលទី៥នេះ រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា ដែលបានបង្កើតឡើងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ បានដាក់ចេញ និងប្រកាសគោលនយោបាយរបស់ខ្លួន ដោយបានបែងចែងជា០៤វិស័យធំៗ រួមមាន៖

1. ការការពារជាតិសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
2. ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ
3. ការអភិវឌ្ឍន៍សេដ្ឋកិច្ច
4. ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច។

ក្នុងវិស័យទាំងបួន(០៤)នោះ គេឃើញមានចំណុចតូចៗជាច្រើន ដែលរាជរដ្ឋាភិបាលបានសន្យាថា នឹងសម្រេចឲ្យបាន ឬបន្តអនុវត្តក្នុងនីតិកាលទី៥នេះ ប៉ុន្តែចំណុចការសន្យាទាំងនោះ មិនត្រូវបានកំណត់ជាចំនួនជាក់លាក់នោះទេ ផ្ទុយពីកម្មវិធីនយោបាលរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ ដែលគេសង្កេតឃើញថា ប្រជាពលរដ្ឋ ជាពិសេសម្ចាស់ឆ្នោតងាយស្រួលក្នុងស្វែងយល់ និងដឹងពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រោះកម្មវិធីនយោបាយនោះបានកំណត់ពីចំនួនគោលនយោបាយច្បាស់លាស់។

ក្នុងកម្មវិធីនយោរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ដែលមានបួន (០៤) វិស័យ គេឃើញមានគោលនយោបាយច្រើនចំណុច ដែលរាជរដ្ឋាភិបាលអាណត្តិទី៥នេះបានសន្យាក្នុងការអនុវត្តន៍ ប៉ុន្តែភាគច្រើននៃគោលនយោបាយទាំងនោះ គ្មានសូចនាករច្បាស់លាស់នោះទេ ពោលគឺគោលនយោបាយទាំងនោះ មិនបានបង្ហាញពីសកម្មភាពការអនុវត្តន៍អ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់នោះទេ។ គោលនយោបាយនីតិកាលទី៥នេះ មិនមានបង្ហាញចំណុចច្បាស់លាស់នោះទេ ខុសពីគោលនយោបាយក្នុងនីតិកាលទី៤ ដែលខុមហ្វ្រែលរកឃើញថា គោលនយោបាយនោះ បានបង្ហាញចំណុចច្បាស់លាស់ ធ្វើឲ្យមានភាពងាយស្រួលក្នុងការវាស់វែង និងផ្តល់ពិន្ទុ។ មានតែគោលនយោបាយ១៦ចំណុចតែប៉ុណ្ណោះ មានសូចនាករច្បាស់លាស់នៅក្នុងវិស័យទី០៣ និងទី០៤តែប៉ុណ្ណោះ។ សម្រាប់គោលនយោបាយដែលគ្មានសូចនាករច្បាស់លាស់៣៣ចំណុច ខុមហ្វ្រែលបានធ្វើការប្រមូលទិន្នន័យ និងព័ត៌មានទាំងនោះ ដើម្បីឲ្យប្រជាពលរដ្ឋជាម្ចាស់ឆ្នោតបោះឆ្នោតផ្តល់ពិន្ទុ។ ខាងក្រោមនេះជាគោលនយោបាយសង្ខេបរបស់រាជរដ្ឋាភិបាលតាមវិស័យនីមួយៗ៖

## ការការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

នៅក្នុងវិស័យការការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការគោលនយោបាយសំខាន់ៗដូចខាងក្រោម៖

### ១.ការការពាជាតិ

- ពង្រឹងកិច្ចការពារអធិបតេយ្យជាតិនៃព្រះរាជាណាចក្រកម្ពុជា លើដែនដីគោក ដែនកោះ ផ្ទៃក្នុងសមុទ្រ តំបន់តភ្ជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ ខ្ពង់រាបបាតសមុទ្រ និងដែនអាកាសដោយយកចិត្តទុកដាក់លើការកសាងផែនការយុទ្ធសាស្រ្តការពារជាតិ ពង្រឹងទីតាំងឈរជើងរបស់កងឯកភាពជួរមុខ កសាងទីតាំងបង្អែក ប្រព័ន្ធការពារ ប្រព័ន្ធទំនាក់ទំនងបញ្ជា ប្រព័ន្ធគាំទ្រផ្លូវគមនាគមន៍។ល។ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់កិច្ចការពារជាតិ។
- ពង្រឹងការតស៊ូតាមផ្លូវច្បាប់នៅតុលាការអន្តរជាតិ ដើម្បីការពារអធិបតេយ្យរបស់កម្ពុជា នៅតំបន់ប្រាសាទព្រះវិហារ លើកទឹកចិត្តប្រជាពលរដ្ឋតាំងទីលំនៅ កសាងភូមិស្ថានតាមព្រំដែន ដោយផ្សារភ្ជាប់នឹងការរឹតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដើម្បីកសាងព្រំដែនជាតំបន់សន្តិភាព សន្តិសុខ សហប្រតិបត្តិការ និងអភិវឌ្ឍន៍ពិតប្រាកដ។
- បន្តការអនុវត្តន៍កងយោធពលខេមរភូមិន្ទឲ្យស្របទៅនឹងការរីកចម្រើនប្រទេសជាតិ និងពិភពលោក ជាកងកម្លាំងដែលមានឧត្តមគតិស្មោះត្រង់ដាច់ខាតចំពោះជាតិមាតុភូមិ គោរពស្រឡាញ់ប្រជាជន មានឆន្ទៈប្រយុទ្ធប្តូរផ្តាច់ និងសមត្ថភាពគ្រប់គ្រាន់នៅក្នុងការការពាឯករាជ្យ សន្តិភាព អធិបតេយ្យ បូរណភាពទឹកដី និងសមិទ្ធផលនៃសង្គមជាតិបានរឹងមាំ ហើយចូលរួមសកម្មក្នុងដំណើការអភិវឌ្ឍន៍ប្រទេសជាតិ។
- បន្តអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យការពារជាតិ តាមរយៈបង្កើនគុណភាពហ្វឹកហ្វឺននៅតាមសាលាហ្វឹកហ្វឺន ពង្រឹងសមត្ថភាពសាស្ត្រាចារ្យ កសាងជួរនាយទាហានវ័យក្មេងដែលជ្រើសរើសចេញពីសិស្សនិស្សិត និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្ត ដើម្បីពង្រឹងការបណ្តុះបណ្តាលយោធិនអាជីព។
- បន្តពង្រឹងខ្សែរយៈចាត់តាំងនៅក្នុងជួរកងទ័ពនៅគ្រប់ថ្នាក់ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងកម្លាំង និងបន្តលើកកម្ពស់សុខមាលភាពកងទ័ព ធានាការផ្តល់ភស្តុភារ ហិរញ្ញវត្ថុ និងសម្ភារៈបច្ចេកទេសគ្រប់ប្រភេទដល់កងទ័ពឲ្យបានល្អប្រសើរ ជាពិសេសចំពោះបណ្តាកងឯកភាពឈរជើងនៅខ្សែត្រៀមជួរមុខ និងកងការពារដែនកោះ។
- ពង្រឹង ពង្រីកទំនាក់ទំនង និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទលើគ្រប់ផ្នែក និងបន្តចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពពិភពលោក ក្នុងក្របខ័ណ្ឌកងរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ។

### ២. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

- ការពារសន្តិសុខជាតិ ប្រឆាំងដាច់ខាតរាល់អំពើដែលនាំទៅដល់ការបង្កអស្ថិរភាពនយោបាយ ការបង្កជម្លោះប្រដាប់អាវុធជាតិ ឬជាមួយប្រទេសជិតខាង និងមិនអនុញ្ញាតឲ្យប្រើប្រាស់ទឹកដីកម្ពុជាដើម្បីប្រឆាំង

នឹងប្រទេសជិតខាង បង្ការដាច់ខាតមិនឲ្យកើតមានការគំរាម បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអាយុជីវិត ឬមហន្តរាយដែលបង្កឡើងដោយអំពើភេរវកម្ម។

- បន្តពង្រឹងវិធានការគ្រប់គ្រងសង្គម ដោយគួបផ្សំនឹងការបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសក្នុងតំបន់ និងពិភពលោកដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបមិនឲ្យមានក្រុមសង្គមងងឹតកើតមាននៅកម្ពុជា ព្រមទាំងការយកចិត្តទុកដាក់ស្រាវជ្រាវ ស៊ើបអង្កេត មិនទុកឲ្យមានខ្សែរយៈបណ្ដាញឧក្រិដ្ឋជនឆ្លងដែនធ្វើសកម្មភាពបាន ឬប្រើប្រាស់កម្ពុជាជាភូមិសាស្ត្រគេចខ្លួនពីសំណាញ់ច្បាប់នៃប្រទេសក្រៅ។
- លើកកម្ពស់ចលនាមហាជនចូលរួមការពារសន្តិសុខ សុវត្ថិភាពនៅក្នុងមូលដ្ឋានឲ្យបានក្លៀវក្លា ដើម្បីពង្រឹងខឿនសន្តិសុខជាតិឲ្យកាន់តែរឹងមាំ តាមរយៈការបន្តជម្រុញចលនានៃការអនុវត្តន៍ គោលនយោបាយ «ភូមិ-ឃុំមានសុវត្ថិភាព» ឲ្យកាន់តែមាននិរន្តរភាព និងសកម្មនៅគ្រប់មូលដ្ឋានទូទាំងប្រទេស ព្រមទាំងពង្រឹងវិធានការទបស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ដើម្បីបង្កភាពកក់ក្ដៅក្នុងការរស់នៅ និងប្រកបមុខរបររបស់ប្រជាជន។
- បន្តផ្ដោតការយកចិត្តទុកដាក់ លើការរៀបចំសណ្ដាប់ធ្នាប់សាធារណៈឲ្យបានល្អប្រសើរ ស្របតាមស្ថានភាពប្រទេសជាតិ ដែលកំពុងមានការរីកចម្រើន ដោយយកចិត្តទុកដាក់គ្រប់គ្រងកត្តាជាមូលដ្ឋាននានាក្នុងការធានាសណ្ដាប់ធ្នាប់ និងសុវត្ថិភាពសង្គម។
- បន្តពង្រឹងការគ្រប់គ្រងជនបរទេសគ្រប់ប្រភេទនៅកម្ពុជា មិនទុកឲ្យមានមុខសញ្ញាគ្រោះថ្នាក់ ឬមុខសញ្ញាហាមឃាត់នានាអាចជ្រៀតចូលបាន បន្តជម្រុញការដោះស្រាយបញ្ហាជនអន្តោប្រវេសន៍ និងគ្រប់គ្រងអន្តោប្រវេសន៍ឲ្យមានប្រសិទ្ធភាព ព្រមទាំងដោះស្រាយអំពើល្មើសច្បាប់របស់ជនបរទេសយ៉ាងម៉ឺងម៉ាត់តាមច្បាប់ជាតិ និងអន្តរជាតិ។
- បន្តលើកកម្ពស់ សមត្ថភាពបំពេញភារកិច្ចរបស់កងកម្លាំងនគរបាលជាតិឲ្យកាន់តែមានវិជ្ជាជីវៈ ប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវ សីលធម៌ គុណធម៌ និងក្លាយជាស្ថាប័នបម្រើប្រយោជន៍ដ៏ស្មោះត្រង់ និងជាបង្អែកជាទីទុកចិត្តកក់ក្ដៅរបស់សង្គមជាតិ។

## ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹង ផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ

៣. **ក្នុងការពង្រឹងរដ្ឋបាលសាធារណៈ** វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ រាជរដ្ឋាភិបាលនឹងផ្ដោតការយកចិត្តទុកដាក់លើវិធានការដូចតទៅ៖

- បន្តអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ សំដៅឲ្យរដ្ឋបាលសាធារណៈ កាន់តែមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងជំនឿទុកចិត្ត ហើយលើកកម្ពស់វប្បធម៌សាធារណៈ ឆន្ទៈម្ចាស់ការ ភក្ដីភាព និងមនសិការវិជ្ជាជីវៈរបស់មន្ត្រីរាជការដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈ ទៅជាអ្នកផ្ដល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព និងដែលបម្រើប្រជាជនបានកាន់តែល្អប្រសើរឡើង។
- បន្តផ្ដោតលើការអនុវត្តន៍យុទ្ធសាស្ត្រទាំង៣នៃកម្មវិធីជាតិកែទម្រង់រដ្ឋបាល គឺ៖ (១). ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ (២). ការអភិវឌ្ឍន៍សមត្ថភាព ការកែលម្អការគ្រប់គ្រង និង

ការអភិវឌ្ឍន៍ធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងគុណផលការងារ និង (៣). ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់បន្ថែមផ្សេងៗដើម្បីពង្រឹងប្រសិទ្ធភាពការងារ ព្រមទាំងការពង្រឹងក្របខ័ណ្ឌ និងការពង្រាយមន្ត្រីរាជការស៊ីវិល។

**៤. ការអនុវត្តន៍ឲ្យកាន់តែស៊ីជម្រៅនូវការកែទម្រង់វិមជ្ឈការ** និងវិសហមជ្ឈការ តាមរយៈការពង្រឹងរដ្ឋបាល ថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ គ្រប់ស្ថាប័ន និងប្រព័ន្ធគ្រប់គ្រង បន្តអភិវឌ្ឍន៍ធនធានមនុស្ស ការផ្ទេរមុខងារ និងធនធាន ព្រមទាំងប្រព័ន្ធថវិការ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ការកសាងសមត្ថភាព សំដៅធានាឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញការងារ ដោយមានការចូលរួម គណនេយ្យភាព តម្លាភាព និងការឆ្លើយតបក្នុងការផ្តល់សេវាសាធារណៈ សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន និងការចូលរួមកាត់បន្ថយភាពក្រីក្រ ដើម្បីរួមចំណែកអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។

**៥. បន្តផ្តោតការយកចិត្តទុកដាក់អនុវត្តឲ្យកាន់តែស៊ីជម្រៅនូវការកែទម្រង់**

ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សំដៅជម្រុញការរៀបចំក្របខ័ណ្ឌច្បាប់ឲ្យមានប្រសិទ្ធភាព និងកាន់តែទទួលបានការជឿទុកចិត្ត ព្រមទាំងពង្រឹងសមត្ថភាពមិនលម្អៀងនៃស្ថាប័នតុលាការ ដែលជាកត្តាដ៏សំខាន់នៃដំណើរការពង្រឹងនីតិរដ្ឋ ការបែងចែកអំណាចដាច់ពីគ្នា ការគោរពសិទ្ធិបុគ្គល និងការធានាភាពយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋទូទៅ។ ដើម្បីសម្រេចទិសដៅនេះ បណ្តាសកម្មភាពសំខាន់នឹងត្រូវបានជម្រុញយ៉ាងសកម្មមានជាអាទិ៍៖ (១). សម្រាប់ការកែទម្រង់ច្បាប់ គឺជម្រុញការកសាងច្បាប់ថ្មីៗតាមការចាំបាច់នៃការគ្រប់គ្រងរដ្ឋ និងស្របតាមដំណើរការបង្កើតសហគមន៍អាស៊ានឆ្នាំ២០១៥ ការពង្រឹងការអនុវត្តន៍ច្បាប់នានាជាធរមាន ឲ្យកាន់តែមានប្រសិទ្ធភាព ការបង្កើនការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រប់ថ្នាក់ និងប្រជាជនឲ្យបានទូលំទូលាយ ក្នុងវិស័យច្បាប់ និង (២). សម្រាប់ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ គឺជម្រុញការកសាងច្បាប់ពាក់ព័ន្ធនឹងស្ថាប័នតុលាការមានជាអាទិ៍៖ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈ ចៅក្រម និងព្រះរាជអាជ្ញា និងវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

- បន្តជម្រុញស្ថាប័នតុលាការ និងអយ្យការ តាមរយៈការបន្តខិតខំបង្កើនសមត្ថភាពរបស់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ព្រមទាំងការបង្កើតរដ្ឋបាលតុលាការ តាមសាលាជម្រះក្តីក្តីគ្រប់ជាន់ថ្នាក់ដើម្បីឲ្យមានការដោះស្រាយរឿងក្តី តាមនីតិវិធីជាធរមានបានកាន់តែឆាប់រហ័ស និងប្រកបដោយយុត្តិធម៌។
- បន្តពង្រឹងក្រមសីលធម៌ មនសិការ វិជ្ជាជីវៈ និងវិន័យ តាមរយៈការបណ្តុះបណ្តាលបឋម និងការបណ្តុះ បណ្តាលនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ រួមទាំងការចុះធ្វើអធិការកិច្ចនៅតាមសាលាជម្រះក្ដីរបស់អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យនៃឧត្តមអង្គចៅក្រម។
- បន្តជម្រុញការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីកាត់បន្ថយចំនួនសំណុំរឿង ដែលមិនចាំបាច់នៅក្នុងតុលាការ និងកាត់បន្ថយភាពស្មុគ្រស្មាញនៅក្នុងសង្គម បន្តជម្រុញការកសាងអគារ និងបំពាក់សំភារៈសម្រាប់សាលាជម្រះក្តីឲ្យមានស្តង់ដារ ដើម្បីផ្តល់លទ្ធភាពទទួលបានយុត្តិធម៌ សម្រាប់ប្រជាជនគ្រប់រូប។

## ៦. បន្តប្រយុទ្ធប្រឆាំងអំពើពុករលួយ

តាមរយៈការពង្រឹង និងការបង្កើនប្រសិទ្ធភាពនៃការអនុវត្តន៍វិធានការលើកស្ទួយទាំង៣ គឺការអប់រំដើម្បីឲ្យម្នាក់ៗ ទាំងអ្នកដើមចម និងអ្នកទទួលផលមិនប្រព្រឹត្តអំពើពុករលួយ ការបង្ការទប់ស្កាត់ ដើម្បីម្នាក់ៗមិនអាចប្រព្រឹត្តអំពើពុករលួយ និងការបង្រ្កាបបទល្មើសបញ្ជូនទៅតុលា ការដើម្បីឲ្យម្នាក់ៗមិនហ៊ានប្រព្រឹត្តអំពើពុករលួយ។

- ពង្រឹងអភិបាលកិច្ចល្អ និងនីតិរដ្ឋ ព្រមទាំងរក្សាភាពស្អាតស្អំ និងយុត្តិធម៌របស់មន្រ្តីដើម្បីធានាបាននូវការលើកកម្ពស់ប្រសិទ្ធភាពនៃសេវាគ្រប់បែបយ៉ាង ដែលជាកត្តាចាំបាច់ក្នុងការអប់រំខ្លួន សង្គមជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។
- បន្តអនុវត្តឲ្យបានសកម្ម និងមានលទ្ធផលខ្ពស់ ក្នុងការលុបបំបាត់ការយកកម្រៃសេវាខុសច្បាប់នៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្រសួងស្ថាប័ន មន្ទីរ និងការិយាល័យនានា គឺមិនមានការទារលុយតាមកន្លែងធ្វើការ តាមផ្សារ តាមដងផ្លូវ តាមដងទន្លេ ឬច្រកព្រំដែនដើម្បីបំបាត់ឱកាស និងរារាំងអំពុករលួយ។

## ការអភិវឌ្ឍន៍សេដ្ឋកិច្ច

ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាមានវិធានការការពារគោលនយោបាយសំខាន់ៗដូចតទៅៈ

## ៧. ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

- បន្តរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ក្នុងបរិការណ៍អតិផរណាមានកម្រិតទាប និងអាចគ្រប់គ្រប់បាន ហើយអត្រាប្តូរប្រាក់មានស្ថិរភាពដើម្បីធានាបរិស្ថាន អនុគ្រោះសម្រាប់ការអភិវឌ្ឍន៍ ការកាត់បន្ថយភាពក្រីក្រ និងការធ្វើសមាហរណកម្មក្នុងតំបន់ និងពិភពលោក។
- ខិតខំសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧%ក្នុងមួយឆ្នាំ ដើម្បីធ្វើឲ្យប្រទេសកម្ពុជា អាចចេញផុតពីប្រទេសមានចំណូលទាប ឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិត យ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយជាមានចំណូលកម្រិតមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ជាមួយនេះ គោលដៅអភិវឌ្ឍន៍សហស្សវត្សឆ្នាំ២០១៥របស់កម្ពុជា និងគោលដៅកាត់បន្ថយអត្រានៃភាពក្រីក្រជាង១%ក្នុងមួយឆ្នាំ ក៏ត្រូវសម្រេចឲ្យបាន ក្នុងនោះរួមទាំង ការខិតខំរួមចំណែកធ្វើឲ្យសម្រេចបាននូវគោលដៅសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥។ ទន្ទឹមនេះ ការរីកចម្រើនខាងសេដ្ឋកិច្ចត្រូវតែធានានូវកាលានុវត្តភាព ការចូលរួម និងការទទួលផលដោយសមធម៌ សម្រាប់ប្រជាជនគ្រប់ស្រទាប់។
- បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសមស្រប គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏ប្រយ័ត្នប្រយែងប្រកបដោយប្រសិទ្ធភាព។
- បន្តការខិតខំធ្វើពិពធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច ដោយឈរលើមូលដ្ឋានភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា និងការផ្សារភ្ជាប់សេដ្ឋកិច្ចកម្ពុជាជាមួយបណ្តាផលិតផលក្នុងតំបន់ ក្នុងនោះយកចិត្តទុកដាក់ជាពិសេសលើការបន្តអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម កម្មន្តសាល និងកសិ-ឧស្សាហកម្ម ព្រមទាំងការអនុវត្តន៍ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យទេសចរណ៍ឆ្នាំ២០១២- ឆ្នាំ២០២០។

- បន្តជម្រុញការអនុវត្តន៍កម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាននូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយ ដែលមានលក្ខណៈស្តង់ដារអន្តរជាតិ សំដៅធ្វើឲ្យប្រព័ន្ធនេះក្លាយជាឧបករណ៍អភិវឌ្ឍន៍មួយដ៏មានប្រសិទ្ធភាព ក្នុងការជម្រុញកំណើនសេដ្ឋកិច្ច ធានាសមធម៌ យុត្តិធម៌សង្គម ធានាទ្រទ្រង់ប្រតិបត្តិការរដ្ឋ និងការផ្តល់សេវាសាធារណៈ ព្រមទាំងរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ។

## ៨. បន្តខិតខំជម្រុញការប្រមូលថវិកាជាតិ

ទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធឲ្យមានកំណើនជារៀងរាល់ឆ្នាំ។ ខាងផ្នែកចំណាយ គឺបន្តផ្តល់អាទិភាពលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបង្កើនសមត្ថភាព និងការលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធដោយផ្សារភ្ជាប់ចំណាយសំរាប់វិស័យនីមួយៗ ទៅនឹងគណនេយ្យភាពនៃសមិទ្ធកម្មនៅក្នុងវិស័យនោះ។ ទន្ទឹមនេះការគ្រប់គ្រងការប្រមូលចំណូល និងការចាត់ចែងចំណាយ ត្រូវផ្តោតការយកចិត្តទុកដាក់លើប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព គួបផ្សំជាមួយនឹងការបន្តយកចិត្តទុកដាក់ខ្ពស់ជានិច្ច ក្នុងការគ្រប់គ្រងបំណុលសាធារណៈឲ្យស្ថិតក្នុងលទ្ធភាពទ្រទ្រង់នៃសេដ្ឋកិច្ចជាតិ។

- បន្តខិតខំបង្កើនអតិរេកចរន្ត ដើម្បីធានាដល់តម្រូវការវិនិយោគសាធារណៈ និងសេវាបំណុល ព្រមទាំងបង្កលក្ខណៈដល់ការសន្សំទុនបម្រុងរបស់រដ្ឋ។

## ៩. បន្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

សំដៅកសាងប្រព័ន្ធហិរញ្ញវត្ថុមួយចំនួនដ៏រឹងមាំ មានការគ្រប់គ្រង និងការត្រួតពិនិត្យសមស្របមានលក្ខណៈប្រកួតប្រជែង និងសមាហរណកម្ម ព្រមទាំងមានតម្លាភាព និងប្រសិទ្ធភាព ជាពិសេសផ្អែកលើគោលការណ៍ទីផ្សារដែលបម្រើឲ្យការគៀងគរ និងបែងចែកធនធានប្រកបដោយប្រសិទ្ធភាព តាមរយៈការបន្តជម្រុញការអនុវត្តន៍យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ មិនមែនធនាគារសំដៅគាំទ្រដល់ពិពិធកម្មសេដ្ឋកិច្ច នវានុវត្តន៍ និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា ជាពិសេសវិស័យកសិ-ឧស្សាហកម្ម និងកម្មន្តសាល ក៏ដូចលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូច មធ្យម និងសម្រាប់ប្រជាជនទូទៅ ព្រមទាំងជម្រុញការធ្វើសមាហរណកម្មហិរញ្ញវត្ថុជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន។

- បន្តអនុវត្តគោលនយោបាយរូបិយវត្ថុ ប្រកបដោយភាពទទនភ្លន់ និងប្រុងប្រយ័ត្នដែលរួមចំណែកដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្កើនបរិស្ថានអំណោយផលដល់ការអភិវឌ្ឍន៍។
- បន្តរក្សារបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដើម្បីរក្សាស្ថិរភាពប្រាក់រៀល ពង្រឹងជំនឿទុកចិត្តរបស់សាធារណជន និងវិនិយោគមកលើប្រាក់រៀល ជំរុញការប្រើប្រាស់ប្រាក់រៀលលើមូលដ្ឋានស្ថិរភាពតម្លៃប្រាក់រៀល និងកាត់បន្ថយដុល្លារូបនីយកម្ម។
- បន្តពង្រឹងប្រព័ន្ធធនាគារឲ្យកាន់តែមានប្រសិទ្ធភាព សមាហរណកម្ម និងការប្រកួតប្រជែង តាមរយៈការបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ ការគ្រប់គ្រងហានិភ័យ សន្ទនីយភាព ហានិភ័យឥណទាន និងហានិភ័យទីផ្សារដោយអនុលោមតាមស្តង់ដារអន្តរជាតិ។
- បន្តពង្រឹងប្រព័ន្ធមីក្រូហិរញ្ញវត្ថុឲ្យកាន់តែមានភាពរឹងមាំ មានប្រសិទ្ធភាព និងបម្រើផលប្រយោជន៍នៃស្រទាប់ប្រជាជនក្រីក្រ ជាមួយនឹងតម្លៃសេវាហិរញ្ញវត្ថុសមស្របដែលអាចទទួលយកបាន។

- បន្តជម្រុញការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារដូចជា៖ វិស័យធានារ៉ាប់រង វិស័យសោធន៍ វិស័យមូលបត្រ និងវិស័យអចលនទ្រព្យជាដើម។

## ១០. ភាពជាដៃគូក្នុងការអភិវឌ្ឍន៍

- បន្តពង្រឹងភាពជាដៃគូជាមួយសហគមន៍ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល ដោយឈរលើគោលការណ៍ជាមូលដ្ឋានដែលមានចរិតសកល និងធានាភាពជាម្ចាស់របស់រដ្ឋ ក្នុងការដឹកនាំការអភិវឌ្ឍន៍ប្រទេសជាតិ។
- ពង្រឹង និងពង្រីកសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានាដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ហើយធ្វើប្រតិបត្តិការដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ និងនីតិរដ្ឋ ដើម្បីចូលរួមក្នុងដំណើរការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ការលើកកម្ពស់លិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ព្រមទាំងចូលរួមតាមដានការអនុវត្តន៍គោលនយោបាយផងដែរ។
- បន្តពង្រឹងយន្តការវេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា វេទិការាជរដ្ឋាភិបាល និងវិស័យឯកជន និងវេទិការាជរដ្ឋាភិបាលជាមួយអង្គការមិនមែនរដ្ឋាភិបាល ហើយជម្រុញឲ្យវេទិកាទាំងនេះ ក្លាយជាវេទិកានៃការអភិវឌ្ឍន៍កម្ពុជា ដែលជាយន្តការសម្រាប់ឲ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ចូលរួមពិភាក្សារាល់បញ្ហាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន។

## ១១.កសិកម្ម

- បន្តអភិវឌ្ឍន៍វិស័យកសិកម្មឲ្យក្លាយជាផ្នែកនាំមុខមួយ ដែលមានប្រៀបខ្លាំងពិតប្រាកដ ដើម្បីធ្វើជាមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ធានាសន្តិសុខស្បៀង បង្កើនការងារ និងប្រាក់ចំណូលសម្រាប់ប្រជាជន ពិសេសប្រជាជននៅជនបទ ហើយរួមចំណែកដល់ការការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព។ ដើម្បីសម្រេចគោលដៅនេះ ការអនុវត្តន៍នូវបណ្តាកម្មវិធីសំខាន់ៗមួយចំនួនត្រូវផ្តោតការយកចិត្តទុកដាក់ ក្នុងនោះរួមមានការបណ្តុះបណ្តាលបច្ចេកវិទ្យាក្នុងវិស័យកសិកម្ម ការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ទាំងការដាំដុះ និងការចញ្ចឹម ការជម្រុញការចូលទីផ្សារអន្តរជាតិនៃផលិតផលកសិកម្មរបស់កម្ពុជា ការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានជលផល និងការការពារ និងគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព។
- បន្តខិតខំសម្រេចនូវគោលនយោបាយ ជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករឲ្យបាន១លានតោននៅឆ្នាំ២០១៥ សំដៅប្រែក្លាយកម្ពុជាទៅជាប្រទេសផលិតស្បៀងនាំមុខមួយនៅលើពិភពលោក។
- រក្សាផ្ទៃនេសាទទឹកសាប សម្រាប់ប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព និងជម្រុញការអភិវឌ្ឍន៍វារីវប្បកម្ម រួមនិងការបន្តពង្រឹង និងពង្រឹងសហគមន៍នេសាទ។
- រក្សាដីដែលគ្របដណ្តប់ដោយព្រៃឈើ ដោយត្រូវបង្កើនការការពារធនធានព្រៃឈើ ពិសេសការពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីព្រៃឈើ ការទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ ជម្រុញការដាំដើមឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើ នៅលើមូលដ្ឋានធានាចីរភាព និងប្រសិទ្ធភាពគ្រប់គ្រង។
- បន្តផ្តោតការយកចិត្តទុកដាក់ ជម្រុញការអភិវឌ្ឍន៍ដំណាំកៅស៊ូឲ្យរីកចម្រើនទាំងបរិមាណ និងគុណភាព

ឲ្យក្លាយទៅជាវិស័យដ៏មានសក្តានុពល និងភាពប្រកួតប្រជែង តាមរយៈការពង្រីកការដាំដុះកៅស៊ូប្រកប ដោយទិន្នផលខ្ពស់ ដោយបន្តអនុវត្តយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍កៅស៊ូធម្មជាតិ នៅឆ្នាំ២០១១-២០២០ សំដៅធ្វើឲ្យផ្ទៃដីដាំកៅស៊ូកើនឡើងដល់៣០ម៉ឺនហិកតា និងមានបរិមាណផលិតផលពី២៥ម៉ឺន តោននៅឆ្នាំ២០២០។ ទន្ទឹមនេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិនឹងផ្តោតលើការធានាគុណភាព និងផលិតភាពនៃការដាំដុះកៅស៊ូ ការសិក្សាលទ្ធភាពប្រើប្រាស់សក្តានុពលដីទំនេរ ដែលអាចដាំកៅស៊ូ បាន ការជំរុញការដាំដុះកៅស៊ូគ្រួសារ ការជំរុញចម្ការកៅស៊ូឧស្សាហកម្មដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍន៍ ចម្ការកៅស៊ូគ្រួសារ និងការជម្រុញតម្លៃឲ្យបានខ្ពស់។

- បញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច។ ជាមួយគ្នានេះ ដីសម្បទានសេដ្ឋកិច្ចនឹងត្រូវបានធ្វើសនិ្ទធិ ហើយ ការគ្រប់គ្រងប្រភេទដីនេះនឹងត្រូវបានពង្រឹងឲ្យបានត្រឹមត្រូវ តាមច្បាប់លិខិតបទដ្ឋាន និងកិច្ចសន្យា ជា ពិសេស តាមរយៈការបង្កើនយន្តការចុះពិនិត្យផ្ទៀងផ្ទាត់ជាប្រចាំ នូវសកម្មភាពវិនិយោគរបស់ក្រុមហ៊ុន ទទួលដីសម្បទាននានា ដែលចុះកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល ដើម្បីធានាដល់កិច្ចដំណើរការនៃ សកម្មភាពវិនិយោគផង និងទប់ស្កាត់នូវភាពអសកម្មផ្សេងៗ ដែលអាចកើតមានទាក់ទងនឹងដីសម្បទាន ផង។

## ដីធ្លី និងសំណង់

### ១២. បន្តអនុវត្តការកែទម្រង់ដីធ្លី

ដែលផ្តោតលើការងាររដ្ឋបាលដីធ្លី ការរៀបចំដែនដី និងនគរូបនីយកម្ម ការបែងចែកដីធ្លី និងការអភិវឌ្ឍន៍ វិស័យសំណង់ដើម្បីការពារសិទ្ធិលើដីធ្លីរបស់ប្រជាជន ព្រមទាំងការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ និង ដីរដ្ឋប្រកបដោយតម្លាភាព សមធម៌ ចីរភាព និងប្រសិទ្ធភាព។

- បន្តអនុវត្តគោលនយោបាយ មិនយកពន្ធលើដីធ្លីបង្កបង្កើនផលរបស់កសិករជាលក្ខណៈគ្រួសារ។
- បន្តជម្រុញការចុះបញ្ជី និងការផ្តល់កម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋ និងដីឯកជន និងដីសហគមន៍ ដើម្បីធានាសុវត្ថិ ភាពនៃការកាន់កាប់ដីធ្លី ដោយជម្រុញល្បឿននៃការចុះបញ្ជីដីធ្លី សំដៅឈានទៅរកសម្រេចឲ្យបាន ១០០% នូវការចុះបញ្ជីដីធ្លី តាមផែនការនៃបទបញ្ជាលេខ០១របស់រាជរដ្ឋាភិបាលជិត២លានហិកតា នៅ រវាងឆ្នាំ២០១៤ ក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍ «នយោបាយចាស់-សកម្មភាពថ្មីលើវិស័យដីធ្លី» និងសម្រេច ឲ្យបាន៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដី ដែលត្រូវចុះបញ្ជីសរុប៦ ទៅ៧លានក្បាលដីដីនៅទូ ទាំងប្រទេស។
- បន្តខិតខំកាត់បន្ថយ និងឈានទៅលុបបំបាត់ឲ្យបាន ភាពអនាធិបតេយ្យរំលោភកាន់កាប់ដីគ្រប់ប្រភេទ ដោយខុសច្បាប់ ទប់ស្កាត់ការប្រមូលដីទុកមិនប្រើប្រាស់ ឬមិនធ្វើអាជីវកម្ម ដោះស្រាយទំនាស់ដីធ្លីប្រកប ដោយតម្លាភាព និងយុត្តិធម៌ ដោយពង្រឹងការប្រតិបត្តិឲ្យបានត្រឹមត្រូវតាមក្របខណ្ឌគតិយុត្តជាធរមាន ព្រមទាំងឆ្លើយតបទៅនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៃការងារដីធ្លី។
- ជំរុញការកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកសាងយុទ្ធសាស្ត្រជាតិនៃការអភិវឌ្ឍន៍ទីក្រុង ទី ប្រជុំជន និងតំបន់ឆ្នេរ។

- បន្តធានាការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយតម្លាភាព និងប្រសិទ្ធភាពដើម្បីរក្សានិរន្តរភាពបរិស្ថាន និងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ប្រកបដោយសមធម៌ ទាំងនៅទីប្រជុំជន និងជនបទ ព្រមទាំងទប់ស្កាត់វិវាទនៃការប្រើប្រាស់ដី ដោយពង្រឹងការអនុវត្តន៍តាមច្បាប់ ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម ច្បាប់សំណង់ ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងអភិបាលកិច្ចល្អ។
- កសាងគោលនយោបាយជាតិ ស្តីពីលំនៅដ្ឋាន ដើម្បីដោះស្រាយលំនៅដ្ឋានជូនប្រជាជនក្រីក្រសំរាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខមាលភាព និងផាសុកភាពថ្លៃថ្នូរ។
- បន្តបែងចែក និងប្រើប្រាស់ដីរដ្ឋសម្រាប់គោលបំណងឯកជន និងសាធារណៈប្រកបដោយតម្លាភាព និងសមធម៌ ឆ្លើយតបទៅនឹងតម្រូវការដីរបស់ប្រជាជនទូទៅ ជាពិសេសប្រជាជនក្រីក្រ យុទ្ធជនពិការ គ្រួសារយុទ្ធជនពលី អតីតៈកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលគ្មានដី ខ្វះដី ហើយត្រូវការដីពិតប្រាកដតាមរយៈកម្មវិធីសម្បទានសង្គមកិច្ច និងការធ្វើប្រទានកម្មដោយធានាឲ្យបាននូវសមធម៌ ស្ថិរភាពសង្គម សន្តិសុខស្បៀង និងការសម្រួលដល់ការវិនិយោគ។
- បន្តល្បឿនផ្តល់ដីសម្បទានសង្គមកិច្ច នៅលើមូលដ្ឋាននៃសន្និធិរដ្ឋក្នុងការអនុវត្តន៍ «នយោបាយចាស់-សកម្មភាពថ្មីលើវិស័យដីធ្លី» សម្រាប់គោលដៅនេះ។
- ទប់ស្កាត់ការកើតឡើងមានទៀតនូវភាពមិនប្រក្រតីនៃការទន្ទ្រានកាន់កាប់ដីរដ្ឋ។
- បន្តជម្រុញការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងអនុវត្តការបែងចែកដីដែលបានបោសសំអាតរួចជូនប្រជជនដែលខ្វះខាតដីប្រកបដោយសមធម៌។

## ១៣. បន្តពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍន៍វិស័យសំណង់

ដែលជាសរសរស្តម្ភមួយនៃកំណើនសេដ្ឋកិច្ច និងកំពុងមានការរីកចម្រើនយ៉ាងខ្លាំង ដោយផ្តោតលើការជំរុញវិនិយោគក្នុងវិស័យសំណង់ ការកសាងច្បាប់ ការកំណត់ស្តង់ដារសំណង់ និងពន្លឿនរយៈពេលចេញលិខិតអនុញ្ញាតសាងសង់ជូនប្រជាជន។

## ឧស្សាហកម្ម សិប្បកម្ម និងធនធានរ៉ែ

## ១៤. បន្តអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

កម្មន្តសាល សិប្បកម្មប្រកបដោយចីរភាព ដែលមានលក្ខណៈចម្រុះសម្បូរបែប មានការទទួលខុសត្រូវខាងបរិស្ថាន និងសង្គមខ្ពស់ ហើយពង្រីកបាននូវអន្តរកម្មសេដ្ឋកិច្ច រវាងផ្នែកកែឆ្នៃកម្មន្តសាលជាមួយវិស័យកសិកម្ម ពាណិជ្ជកម្ម និងសេវាកម្មដើម្បីជម្រុញសមាហរណកម្មសេដ្ឋកិច្ច ខ្សែសង្វាក់តម្លៃ និងភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក។ ឆ្លងតាមការជម្រុញការអភិវឌ្ឍន៍ឧស្សាហកម្មសេដ្ឋកិច្ច នឹងត្រូវបានអនុវត្តជាជំហានៗ ដែលនឹងនាំកម្ពុជាឈានទៅដល់ដំណាក់កាលថ្មីនៃពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច តាមរយៈការប្រើប្រាស់បណ្តាលក្ខខណ្ឌអំណោយផល និងឧត្តមភាពប្រៀបធៀបរបស់កម្ពុជាប្រកបដោយប្រសិទ្ធភាព។

- បន្តផ្តោតការខិតខំថែមទៀត លើការពង្រឹងភាពអំណោយផលិតផលនៃបរិស្ថានវិនិយោគ ការជម្រុញការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ការលើកកម្ពស់ផលិតភាព និងសហគ្រិនភាពរបស់សហគ្រាសធុនតូច និងមធ្យម ការពង្រីកលទ្ធភាពទទួលបានបច្ចេកវិជ្ជាជឿនលឿន ការបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈ

ព្រមទាំងការលើកកម្ពស់ការងារស្តង់ដារូបនីយកម្ម ការវាយតម្លៃភាពអនុលោម និងមាត្រាសាស្ត្រ។ ទិសដៅជាសារវន្តនៃគោលនយោបាយនៃការអភិវឌ្ឍន៍ឧស្សាហកម្មនៅពេលខាងមុខនេះ គឺជាការច្បាមយកតម្លៃបន្ថែមឲ្យបានកាន់តែច្រើននៅក្នុងវិស័យសំខាន់ៗ ដែលមានសម្រាប់រួមមាន៖ វិស័យកសិសិកម្ម។

## ១៥. អភិវឌ្ឍន៍ធនធានរ៉ែ ប្រេងកាត និងឧស្ម័ន

ដើម្បីប្រែក្លាយធនធាននេះឲ្យទៅជាប្រភពថ្មីមួយទៀតនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។

- លើកទឹកចិត្តឲ្យវិស័យឯកជនវិនិយោគ លើការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មធនធានទាំងនោះតាមច្បាប់ជាធរមាន ដោយយកចិត្តទុកដាក់សំខាន់លើសុវត្ថិភាព សុខមាលភាព ព្រមទាំងការការពារបរិស្ថាន និងសង្គម បន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានាដែលទាក់ទងនឹងធនធានរ៉ែ ប្រេងកាត និងឧស្ម័នដើម្បីធានាការអភិវឌ្ឍន៍ធនធាននេះប្រកបដោយប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។ ទន្ទឹមនេះ ចំណូលដែលបានមកពីធនធានរ៉ែ ប្រេងកាត និងឧស្ម័នត្រូវបានគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយផ្សារភ្ជាប់ជាមួយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

## ១៦. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

- បន្តបង្កើនការស្តារ ការសាងសង់ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនប្រកបដោយគុណភាពសម្រាប់បម្រើឲ្យការដឹកជញ្ជូនពហុរូបភាព គឺទាំងការដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងការដឹកជញ្ជូនផ្លូវអាកាស ដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស តភ្ជាប់ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីធានាការធ្វើដំណើរគ្រប់ច្រកល្ហក និងការផ្តល់សេវាដឹកជញ្ជូនបានគ្រប់គ្រាន់ គ្រប់រដូវកាលប្រកបដោយផាសុកភាព សណ្តាប់ធ្នាប់ ប្រសិទ្ធភាព និងមានតម្លៃទាប។
- បន្តផ្តល់អាទិភាពខ្ពស់ដល់ការស្តារ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់គ្រប់ប្រភេទ ទាំងផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវជនបទ។ ក្នុងនោះខិតខំកែលម្អផ្លូវលំជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងឲ្យបានពី៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំ តាមស្តង់ដារឯកភាពជាតិមួយ។
- បន្តពង្រឹងរាលវិធានការដំម៉ឹងម៉ាត់ ដើម្បីធានាការគ្រប់គ្រងការងារថែទាំផ្លូវថ្នល់ឲ្យមានប្រសិទ្ធភាព ទន្ទឹមនឹងការបន្តស្តារ និងការអភិវឌ្ឍន៍ផ្លូវ។
- បន្តលើកទឹកចិត្តជម្រុញការចូលរួមពីវិស័យឯកជន ក្នុងការវិនិយោគលើការអភិវឌ្ឍន៍ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសេវាដឹកជញ្ជូន។
- លើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ឲ្យមានលក្ខណៈសម្បត្តិខាងបច្ចេកទេសគ្រប់គ្រាន់ ដើម្បីធ្វើចរាចរណ៍នៅលើផ្លូវសាធារណៈ។
- ផ្សព្វផ្សាយអប់រំដល់ប្រជាជនទូទៅ ឲ្យបានយល់ដឹងច្បាស់អំពីច្បាប់ចរាចរណ៍ ហើយចូលរួមអនុវត្តយ៉ាងសកម្ម ដើម្បីធានាសុវត្ថិភាពចរាចរណ៍ និងការគោរពថែរក្សាទ្រព្យសម្បត្តិសាធារណៈ។
- រៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ជាពិសេស រាជធានីភ្នំពេញសម្រាប់រយៈពេលមធ្យម និងរយៈ

ពេលវែង ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធ កសាងមធ្យោបាយដឹកជញ្ជូន ដើម្បីរួមជាប្រយោជន៍សំរាប់ដោះស្រាយបញ្ហាកកស្ទះ និងពង្រឹងសណ្ដាប់ធ្នាប់ចរាចរណ៍ទីក្រុង ដែលកាន់តែមានភាពលំបាកស្មុគ្រស្មាញឡើងពីមួយថ្ងៃ ទៅមួយថ្ងៃ ដោយសារកំណើនប្រជាជន និងកំណើនយ៉ាងលឿននៃបរិមាណយានយន្តគ្រប់ប្រភេទ។

- បន្តស្ដារឡើងវិញនូវបណ្ដាញផ្លូវដែកនៅកម្ពុជាដែលមានស្រាប់ គឺបញ្ញាញពាយ័ព្យទិស និរតីទិសដើម្បីពង្រឹងវិសាលភាពនៃការដឹកជញ្ជូនទំនិញ អ្នកដំណើរ និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ព្រមទាំងធ្វើសមាហរណកម្មផ្លូវដែកកម្ពុជា ទៅជាបប្រព័ន្ធផ្លូវដែកតំបន់អាស៊ាន និងមហាអនុតំបន់មេគង្គ។
- ពង្រឹងយន្តការគ្រប់គ្រង និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនទាំងពីរជាលក្ខណៈតំបន់ និងអន្តរជាតិប្រកបដោយប្រសិទ្ធភាព មានការប្រកួតប្រជែងដោយស្មើភាព ធានាបរិស្ថានទន្លេ និងសមុទ្របានល្អ ព្រមទាំងធ្វើឲ្យកាន់តែប្រសើរនូវតួនាទីរបស់កំពង់ផែ ក្នុងការសម្របសម្រួលពាណិជ្ជកម្មចរាចរណ៍ទំនិញ និងទេសចរណ៍។
- បន្តស្ដារ និងអភិវឌ្ឍន៍អាកាសយាន្តដ្ឋានជាតិ អន្តរជាតិ និងប្រព័ន្ធនាំផ្លូវអាកាសនៃព្រះរាជាណាចក្រកម្ពុជា លើកកម្ពស់ការពង្រឹងសុវត្ថិភាព សន្តិសុខអាកាសចរណ៍ និងការពារបរិស្ថាន ដើម្បីបង្កើនផលប្រយោជន៍ខាងសេដ្ឋកិច្ច ជម្រុញវិស័យពាណិជ្ជកម្ម ទេសចរណ៍ និងធ្វើឲ្យមានសង្គមតិភាពជាមួយគោលនយោបាយដឹកជញ្ជូនផ្លូវអាកាស ថ្នាក់ដឹកនាំតំបន់ អនុតំបន់ និងអន្តរជាតិ។

## ១៧. ធនធានទឹក

- បន្តលើកកម្ពស់ការគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព មាននិរន្តរភាព និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី ដើម្បីផ្ដល់លទ្ធភាពដល់ជនគ្រប់រូប ក្នុងការប្រើប្រាស់ទឹកដែលមានអនាម័យ សុវត្ថិភាព និងតម្លៃសមស្របសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃបានគ្រប់គ្រាន់ ធានាការគ្រប់គ្រង និងបែងចែកទឹកឲ្យមានសមភាព សម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម ឧស្សាហកម្ម សេវា និងសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត ធានាការគ្រប់គ្រងបរិមាណ និងគុណភាពទឹកទាំងទឹកលើដី ទាំងទឹកក្រោមដី ហើយកាត់បន្ថយឲ្យបានជាអតិបរមា នូវគ្រោះគំរាមដល់អាយុជីវិត និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋពីគ្រោះមហន្តរាយដែលបង្កឡើងដោយទឹក។
- ពង្រឹងការគ្រប់គ្រងធនធានទឹក ដោយជម្រុញឲ្យមានការគោរពកិច្ចព្រមព្រៀងអន្តរប្រទេស លើការគ្រប់គ្រងទឹកទន្លេមេគង្គ និងចាត់ទុកទឹកជាទ្រព្យសម្បត្តិសាធារណៈដែលត្រូវគោរព និងការពារ។
- បន្តផ្ដល់អាទិភាពលើការស្ដារ កសាង ថែទាំ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដែលត្រូវតែមានប្រសិទ្ធសេដ្ឋកិច្ច ហើយត្រូវធានាបាននូវផលនៃការវិនិយោគ ក្នុងនោះរួមមាន៖ អាងស្ដុកទឹក ប្រឡាយទឹកសំណង់ទ្វារទឹក លូទឹក ប្រឡាយនាំដីល្បាប់ ប្រព័ន្ធដោះទឹក ទំនប់ការពារ ទឹកជំនន់ ការការពារទឹកប្រៃ និងស្ថានីយ៍បូមទឹកដើម្បីបង្កើនផល ពង្រីកវារីវប្បកម្ម កាត់បន្ថយមហន្តរាយដែលបណ្ដាលមកពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ព្រមទាំងសម្រួលដល់ការធ្វើដំណើររបស់ប្រជាជន។
- ពង្រឹងការអនុវត្តន៍ច្បាប់ ស្ដីពីការគ្រប់គ្រងធនធានទឹក ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធដើម្បីទប់ស្កាត់រាល់សកម្មភាព ឬគម្រោងសាងសង់នានាដែលអាចធ្វើឲ្យប៉ះពាល់មកលើធនធានទឹក ក៏ដូចជាប្រព័ន្ធអេកូឡូស៊ី រាំងស្កាត់ និងមានវិធានការម៉ឹងម៉ាត់ចំពោះ

សកម្មភាពចាក់លុបបំពេញដី, ការជីកថ្មី ឬការរំលោភលើផ្លូវទឹកទន្លេ, ស្ទឹង, បឹងបួរ, ព្រែក ឬតំបន់ទំនាបសមុទ្រ និងទីលិចទឹកជាប្រចាំដែលគ្មានច្បាប់អនុញ្ញាត ហើយអាចធ្វើឲ្យប៉ះពាល់មកលើធនធានទឹក ក៏ដូចជាប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន។

- បន្តធ្វើសមាហរណកម្មកម្ពុជាជាមួយសហគមន៍អន្តរជាតិ ក្នុងវិស័យទឹក ដើម្បីជម្រុញកិច្ចសហប្រតិបត្តិការ និងការយោគយល់ជាអន្តរជាតិក្នុងវិស័យនេះ សហការពេញទំហឹងជាមួយបណ្តាប្រទេសជិតខាង ដែលមានព្រំប្រទល់ជាប់នឹងកម្ពុជា ព្រមទាំងជាមួយប្រទេសក្នុងតំបន់ ដើម្បីសម្រេចគោលបំណងនៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍន៍អាងទន្លេមេគង្គប្រកបដោយចីរភាព។

## ១៨. ទឹកស្អាត

- ជម្រុញការអភិវឌ្ឍន៍ និងវិចារណកម្មការគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត សម្រាប់ប្រើប្រាស់ក្នុងជីវភាពរបស់ប្រជាជន និងផលិតកម្ម សេវាប្រកបដោយគុណភាព ប្រសិទ្ធភាព និងថ្លៃសមរម្យដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាព ជាពិសេសកាត់បន្ថយកង្វះទឹកស្អាតប្រើប្រាស់សម្រាប់ប្រជាជន ដែលរស់នៅក្នុងតំបន់ទីប្រជុំជន ជាយក្រុង និងជនបទ។ ទន្ទឹមនេះ គោលដៅក្នុងការផ្គត់ផ្គង់ទឹកស្អាត គឺដល់ឆ្នាំ ២០១៨ ប្រជាជនចំនួន៨៥%ដែលរស់នៅរាជធានី ខេត្ត និងប្រជាជនចំនួន៦០% ដែលរស់នៅតាមបណ្តាឃុំបានទទួលសេវាទឹកស្អាត ដែលមានគុណភាពល្អ និងថ្លៃសមរម្យប្រើប្រាស់ តាមរយៈការពង្រីកសមត្ថភាពផលិត និងការផ្គត់ផ្គង់ទឹកស្អាតនៅរាជធានី ខេត្ត និងពង្រីកការចូលរួមរបស់វិស័យឯកជនក្នុងការវិនិយោគលើវិស័យផ្គត់ផ្គង់ទឹកស្អាត។

## ១៩. ថាមពល

- បន្តអភិវឌ្ឍន៍វិស័យថាមពល ដើម្បីធានាការផ្គត់ផ្គង់ថាមពលដែលមានស្ថិរភាព ការជឿទុកចិត និងថ្លៃសមរម្យសម្រាប់បម្រើជីវភាពរស់នៅរបស់ប្រជាជន ការផ្តល់សេវានានាដល់សង្គម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិដោយផ្តោតលើទិសដៅធំ២ គឺបន្តសាងសង់ស្ថានីយផលិតអគ្គិសនីក្នុងស្រុក និងធ្វើសមាហរណកម្មប្រព័ន្ធថាមពលកម្ពុជា ទៅក្នុងថាមពលរបស់តំបន់អាស៊ាន និងមហាអនុតំបន់ទន្លេមេគង្គ សំដៅបង្កើតប្រភពថាមពលឲ្យបានគ្រប់គ្រាន់ និងមានស្ថិរភាពសម្រាប់កម្ពុជា។
- បន្តអភិវឌ្ឍន៍បណ្តាញបញ្ជូនអនុស្ថានីយ បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយអគ្គិសនីឲ្យបានឆាប់បានគ្របដណ្តប់ទូទាំងប្រទេស ដើម្បីបញ្ជូនថាមពលដែលមានស្ថិរភាព និងថ្លៃសមរម្យទៅផ្គត់ផ្គង់ដល់លំនៅស្ថានប្រជាជន និងទីតាំងបម្រើសកម្មភាពសង្គម និងសេដ្ឋកិច្ច។
- បន្តជម្រុញការធ្វើពិពិធកម្មថាមពល ក្នុងនោះរួមមាន ការបង្កើតប្រភពថាមពលស្អាត និងប្រភពថាមពលកកើតឡើងវិញ ការពង្រឹងសន្តិសុខថាមពល ការខិតខំកាត់បន្ថយឲ្យបានជាអតិបរមានូវផលប៉ះពាល់លើបរិស្ថានធម្មជាតិ និងសង្គមក្នុងដំណើរការផលិតថាមពល។
- បន្តអនុវត្តតួនាទីនាំមុខរបស់រដ្ឋ ក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី ជាមួយគ្នានេះ គាំទ្រ និងលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនក្នុងការវិនិយោគ និងធ្វើអាជីវកម្មផ្តល់សេវាអគ្គិសនីដែលគោរពតាមការកំណត់នៃច្បាប់ បទបញ្ញត្តិ ស្តង់ដារ និងនីតិវិធីជាធរមាន ពិសេសការអនុវត្តន៍ថ្លៃលក់អគ្គិសនីឲ្យបានត្រឹមត្រូវតាមច្បាប់អគ្គិសនី ដើម្បីការពារផលប្រយោជន៍ និងភាពយុត្តិធម៌ទាំងសំរាប់អ្នកផលិត អ្នកបញ្ជូន អ្នកចែកចាយ និងអ្នកប្រើប្រាស់។

- ជម្រុញដំណើរការអគ្គិសនីភាវូបនីយកម្មជនបទ តាមរយៈគោលដៅនៃវិស័យថាមពលពីឆ្នាំ២០១៣ ដល់ឆ្នាំ ២០១៨ គឺពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្ដាញជាតិ ឲ្យដល់ភូមិចំនួន៨០%នៃចំនួនភូមិទាំងអស់ និង ដោះស្រាយការផ្គត់ផ្គង់អគ្គិសនីដោយវិធីផ្សេងៗទៀត ឲ្យបាន១០%នៃចំនួនភូមិទាំងអស់ លើគោលដៅ ១០០%នៃភូមិនៅឆ្នាំ២០២០ ហើយរហូតដល់ឆ្នាំ២០៣០ មាន៧០%នៃគ្រួសារទាំងអស់មានអគ្គិសនី ដែលមានគុណភាពដូចអគ្គិសនីពីបណ្ដាញជាតិប្រើប្រាស់។
- ខិតខំរកលទ្ធភាពជួយប្រជាជនក្រីក្រនៅតំបន់ជនបទ អាចប្រើប្រាស់អគ្គិសនីពីបណ្ដាញផ្គត់ផ្គង់ ទាំងលទ្ធ ភាពភ្ជាប់ចរន្តពីបណ្ដាញ ទាំងថ្លៃអគ្គិសនី។

## ២០. បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍

- បន្តអភិវឌ្ឍន៍ប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ឲ្យមាន លក្ខណៈទំនើប មានគុណភាពខ្ពស់ ស្របតាមស្តង់ដារអន្តរជាតិ មានថ្លៃសមរម្យ និងមានសេវាគ្រប ដណ្ដប់នៅទូទាំងប្រទេស ដែលប្រជាជនទូទៅអាចប្រើប្រាស់ និងទទួលបានផលប្រយោជន៍គ្រប់ៗគ្នាពី សេវាកម្មនេះ។
- បន្តលើកទឹកចិត្តវិនិយោគឯកជន ធ្វើទំនើបបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ជំរុញការប្រកួតប្រជែង ដោយយុត្តិធម៌ក្នុងទីផ្សារសេវាប្រៃសណីយ៍ និងទូរគមនាគមន៍ ដោយផ្អែកលើច្បាប់ និងលិខិតបទដ្ឋាននា នា ទប់ស្កាត់ការធ្វើអាជីវកម្មផ្ដាច់មុខក្នុងវិស័យប្រៃសណីយ៍ និងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគម ន៍ ដោយចាត់ទុកវិស័យទាំងពីរជាទំនិញ និងសេវាសាធារណៈផង និងជាទ្រព្យសម្បត្តិសាធារណៈផង។
- បន្តពង្រីកការកសាងហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង បណ្ដាញខ្សែកាបអុបទិចប្រកបដោយសុវត្ថិភាព និងជឿ ទុកចិត្តឲ្យបានដល់គ្រប់ខេត្ត ដើម្បីពង្រីកវិសាលភាព និងរក្សាចីរភាពនៃសេវាបច្ចេកវិទ្យាព័ត៌មាន និងគម នាគមន៍។
- បន្តអភិវឌ្ឍន៍ប្រព័ន្ធរដ្ឋបាលគ្រប់គ្រងអេឡិចត្រូនិច ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងជំរុញការ បណ្ដុះបណ្ដាលមន្ត្រីរាជការ សិស្ស និស្សិតលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ បង្កើនវិសាល ភាព និងគុណភាពនៃបណ្ដាញផ្សព្វផ្សាយ ទាំងការផ្សាយក្នុងប្រទេស និងក្រៅប្រទេស។

## ២១. ការអភិវឌ្ឍន៍ជនបទ

- បន្តខិតខំធ្វើឲ្យកាន់តែប្រសើរឡើង នូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជនបទ តាមរយៈការបន្តកសាងផ្លូវជនបទ ការរៀបចំឲ្យមានដំណើរការនៃប្រព័ន្ធគ្រប់គ្រង និងថែទាំផ្លូវជនបទ ដោយមានការចូលរួមរបស់សហ គមន៍មូលដ្ឋាន ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ជាពិសេសការកែលម្អផ្លូវជនបទជា ជំហានៗ ពីផ្លូវក្រាលក្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង។
- បន្តខិតខំសម្រេចគោលដៅឆ្នាំ២០១៨ ដើម្បីឲ្យប្រជាជននៅជនបទចំនួន៦០% បានទទួលសេវាផ្គត់ផ្គង់ ទឹកស្អាត ហើយនៅឆ្នាំ២០២៥ ប្រជាជនគ្រប់រូបដែលរស់នៅក្នុងសហគមន៍ជនបទ ត្រូវមានសេវាផ្គត់ផ្គង់ ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយចីរភាព។
- បន្តអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ដើម្បីកែលម្អ លើកកម្ពស់ជីវភាពប្រជាជននៅជនបទ និងកាត់បន្ថយការធ្វើ ចំណាកស្រុកស្វែងរកការងារ តាមរយៈការជំរុញវិស័យឥណទានជនបទ ដើម្បីផ្ដល់សេវាប្រាក់កម្ចីដែល

មានអត្រាការប្រាក់សមរម្យជូនប្រជាជននៅជនបទ ការបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញមូលដ្ឋាន ការជំរុញការអភិវឌ្ឍន៍សិប្បកម្ម សហគ្រាស និងមុខជំនាញខ្នាតគ្រួសារ ខ្នាតតូច និងមធ្យម ដោយយកចិត្តទុកដាក់ផ្តល់បច្ចេកទេសជំនាញ និងការយល់ដឹងអំពីការបង្កើតមុខរបរ ព្រមទាំងការខិតខំពង្រីកទីផ្សារសម្រាប់ផលិតផលជនបទ។

- បន្តអភិវឌ្ឍន៍តំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ឲ្យមានការរីកចម្រើនខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ធានាសិទ្ធិពេញលេញរបស់បងប្អូនជនជាតិដើមភាគតិច ក្នុងការចូលរួមធ្វើសេចក្តីសំរេចនានា ដើម្បីកសាងគោលនយោបាយជាតិ ធានាសិទ្ធិទទួលបាននូវការការពារដោយច្បាប់ និងវិធានការសង្គមនានា ដែលឆ្លើយតបទៅនឹងតម្រូវការចាំបាច់សំរាប់ការរស់នៅប្រកបដោយភាពថ្លៃថ្នូរ ព្រមទាំងការគោរពចំពោះទំនៀមទម្លាប់ ប្រពៃណីល្អ និងភាសារបស់បងប្អូនជនជាតិ។

## ២២. ពាណិជ្ជកម្ម

- បន្តជំរុញការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម តាមរយៈការធ្វើពិពិធកម្មទីផ្សារនាំចេញ និងការបង្កើនល្បឿនសមាហរណកម្មទៅក្នុងក្របខណ្ឌពាណិជ្ជកម្មសេរីសំខាន់ៗក្នុងតំបន់ និងពិភពលោក ជាពិសេសបណ្តាប្រទេសក្នុងសមាគមអាស៊ាន ស្របតាមទិសដៅធ្វើឲ្យសំរេចសហគមន៍អាស៊ានឆ្នាំ២០១៥ និងបណ្តាប្រទេសជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ ឆ្លងតាមការអនុវត្តន៍ទិសដៅនេះ កម្ពុជានឹងទទួលបានអត្ថប្រយោជន៍សំរាប់ការជំរុញកំណើនសេដ្ឋកិច្ច និងផ្តល់ឱកាសដល់កម្ពុជា ក្នុងការរួមចំណែកកសាងគោលនយោបាយសេដ្ឋកិច្ចតំបន់ និងពិភពលោក ដើម្បីឲ្យការធ្វើពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោក មានលក្ខណៈយុត្តិធម៌ សមធម៌ និងតម្លាភាព។
- បន្តពង្រីកទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ដើម្បីផ្សារភ្ជាប់ទីផ្សារក្នុងប្រទេស ជាមួយនឹងទីផ្សារក្រៅប្រទេស លើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាពផលិត និងផ្គត់ផ្គង់ ជំរុញការវិនិយោគ និងការនាំចេញទំនិញ ដោយផ្តោតលើការបង្កើនគុណភាពផលិតផលក្នុងស្រុក ព្រមទាំងការបង្កើតបន្ថែមមុខរបរ និងមុខទំនិញថ្មីៗសំរាប់នៃចេញសំដៅរក្សាលំនឹងនៃជញ្ជីងពាណិជ្ជកម្ម បញ្ចៀសវិបត្តិទីផ្សារ ដោះស្រាយការងារ និងបង្កើនចំណូលរបស់ប្រជាជន។
- ផ្តោតការយកចិត្តទុកដាក់ជាប្រចាំ លើការរក្សាស្ថិរភាពថ្លៃទំនិញនៅលើទីផ្សារ បន្តធ្វើកិច្ចអន្តរាគមន៍លើទីផ្សារ ពិសេសចំពោះបណ្តាមុខទំនិញជាយុទ្ធសាស្ត្រ ដូចជា ស្រូវ អង្ករ ប្រេងឥន្ធនៈ អគ្គិសនី ទឹក និងបណ្តាមុខទំនិញផ្សេងៗទៀត ដែលត្រូវការប្រើប្រាស់ចាំបាច់សំរាប់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ដោយចាត់វិធានការរាំងខ្ទប់បាតុភាពស្តុកទំនិញលក់តម្លើងថ្លៃ ឬការលក់បំប៉ោងថ្លៃ ដែលនាំឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន។
- បង្កលក្ខណៈងាយស្រួលឲ្យផលិតផល និងទំនិញធ្វើចរាចរបានដោយសេរីនៅគ្រប់ទីកន្លែង ដោយឈរលើគោលការណ៍ប្រកួតប្រជែងដោយស្មើភាព តាមថ្លៃទីផ្សារ ពិសេសយកចិត្តទុកដាក់ការពារថ្លៃទំនិញកសិផលរបស់ប្រជាកសិករ និងជំនះបាតុភាពដែលនាំឲ្យកកស្ទះទំនិញកសិផល ការបន្ថោកបង្អាប់ថ្លៃកសិផល និងការរាំងស្ទះការដឹងជញ្ជូន។
- ខិតខំរក្សាទីផ្សារដែលមានស្រាប់ និងបន្តចរចាបើកច្រកទីផ្សារជាមួយប្រទេសជាដៃគូពាណិជ្ជកម្មនានា ដើម្បីជំរុញឲ្យទំនិញ និងសេវារបស់កម្ពុជាដណ្តើមបានទីផ្សារកាន់តែទូលំទូលាយថែមទៀត។

- បន្តចូលរួមយ៉ាងសកម្ម ជាមួយបណ្តាប្រទេសនៃសមាគមអាស៊ាន ក្នុងការបង្កើតតំបន់ពាណិជ្ជកម្មសេរី ជាមួយបណ្តាប្រទេសធំៗ ក្នុងពិភពលោក ដើម្បីពង្រីកទីផ្សារឲ្យបានជាអតិបរមា។
- ខិតខំពង្រឹង និងពង្រីកលក្ខណៈសម្បត្តិនានា សំដៅពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា នៅក្នុងទីផ្សារក្រៅប្រទេស។
- ការពារ និងលើកតម្កើងកម្មសិទ្ធិបញ្ញាដែលជាប្រភេទកម្មសិទ្ធិ ឬទ្រព្យសម្បត្តិមួយដ៏មានតម្លៃដូចជា៖ តម្លៃទ្រព្យសម្បត្តិខាងបញ្ញាដែលទាក់ទងទៅនឹងស្នាដៃតក្កកម្ម ការរកឃើញថ្មីនៃវិទ្យាសាស្ត្រ ការអភិវឌ្ឍន៍បច្ចេកវិទ្យា គំនូសឧស្សាហកម្ម ម៉ាក និងពាណិជ្ជកម្មជាដើម។
- បន្តលើកស្ទួយផលិតផលសម្គាល់ភូមិសាស្ត្រ ផលិតផលដែលបង្ហាញនូវមរតកវប្បធម៌ ប្រពៃណីដែលជាស្នាដៃរបស់ផលិតករខ្មែរ។
- ពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ទប់ស្កាត់សកម្មភាពប្រកួតប្រជែងមិនស្មោះត្រង់ រាំងស្កាត់ការផលិត និងការចែកចាយផលិតផលក្លែងក្លាយ និងផលិតផលគ្មានគុណភាព ឬខូចគុណភាព ដើម្បីការពារផលប្រយោជន៍របស់ធុរជន វិនិយោគិន លើកទឹកចិត្តពាណិជ្ជករ ផលិតករឲ្យធ្វើប្រតិបត្តិការពាណិជ្ជកម្មដោយស្មើភាព និងការពារផលប្រយោជន៍របស់ប្រជាជន ដែលជាអ្នកប្រើប្រាស់ផលិតផលទំនិញ ឬសេវាពិសេសទប់ស្កាត់ការនាំចូលទំនិញប្រើប្រាស់រួចដែលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន។
- បន្តជំរុញចលនា «ភូមិមួយ-ផលិតផលមួយ» ដោយឈរលើគោលលការណ៍បីយ៉ាង គឺជំរុញឲ្យប្រជាជនផលិតស្របតាមលក្ខខណ្ឌភូមិសាស្ត្រ និងលក្ខខណ្ឌទីផ្សារក្នុងប្រទេស និងក្រៅប្រទេស ផលិតឲ្យបានច្រើន ផលិតមានគុណភាពល្អ លក់ឲ្យដាច់ហើយបានថ្លៃខ្ពស់ និងប្រើប្រាស់គំនិតច្នៃប្រឌិត ទេពកោសល្យ ភាពប៉ិនប្រសប់របស់ប្រជាជនតាមមូលដ្ឋាន ដែលនឹងជួយបង្កើតមុខរបរបន្ថែម រួមចំណែកបង្កើនចំណូលលើកកម្ពស់កម្រិតជីវភាពរស់នៅ។

## ២៣. ការអភិវឌ្ឍន៍វិស័យឯកជន និងការទាក់ទាញការវិនិយោគ

- បន្តទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងជំរុញការវិនិយោគក្នុងស្រុក ជាពិសេសតាមរយៈការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម និងការជំរុញសហគ្រិនភាពដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍន៍ ធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើតការងារ។
- បន្តកសាងអភិបាលកិច្ចសាជីវកម្មល្អ ដែលជាប្រការចាំបាច់សម្រាប់ការប្រកួតប្រជែងផង សំរាប់ភាពរឹងមាំ និងភាពរីកដុះដាលនៃវិស័យឯកជនខ្លួនឯងផង ព្រមទាំងសំរាប់ពង្រឹងវប្បធម៌គណនេយ្យភាព ចំពោះសង្គមផង ពិសេសក្នុងការបំពេញកាតព្វកិច្ចពន្ធ និងអាករ។
- បន្តការខិតខំធ្វើឲ្យបរិស្ថានវិនិយោគ និងធុរកិច្ចនៅកម្ពុជាកាន់តែមានភាពអំណោយផល និងល្អប្រសើរ ព្រមទាំងធ្វើឲ្យកម្ពុជាក្លាយជាគោលដៅវិនិយោគមួយដែលមានភាពកាន់តែទាក់ទាញ នៅក្នុងតំបន់ដែលនឹងបង្កើនបាននូវភាពប្រកួតប្រជែង និងផលិតភាពកាន់តែខ្ពស់សំរាប់កម្ពុជា។
- បន្តពង្រឹងអភិក្រមបើកចំហសំរាប់ការអភិវឌ្ឍន៍វិស័យឯកជន និងការទាក់ទាញវិនិយោគ សំដៅពង្រីកច្រកចូលទៅកាន់ទីផ្សារតំបន់ និងអន្តរជាតិ។

- រៀបចំឲ្យកាន់តែប្រសើរឡើងនូវរបបវិនិយោគឯកជន ដើម្បីផ្តល់ការលើកទឹកចិត្តសមស្រប និងចំគោលដៅ ដែលឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍន៍រយៈពេលវែង។
- ធានាបរិស្ថានវិនិយោគ និងធុរកិច្ចប្រកបដោយភាពអំណោយផលសំរាប់ទទួលការវិនិយោគ ទាំងក្នុងប្រទេស និងពីក្រៅប្រទេស តាមរយៈការបន្តដាក់ចេញនូវបណ្តាវិធានការសំខាន់ៗ សំដៅផ្តោតលើការធានាស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការធានាស្ថិរភាព និងភាពគត់មត់នៃបរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការសម្រួលពាណិជ្ជកម្ម និងការសម្រួលធុរកិច្ចមានជាអាទិ៍៖ ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តន៍យន្តការ «ច្រកចេញ-ចូលតែមួយ» ការលុបបំបាត់ចំណាយក្រៅផ្លូវការជាដើម។
- បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអនុវត្តន៍វិធានការនានា សំដៅកាត់បន្ថយថ្លៃដឹកជញ្ជូន និងថ្លៃអគ្គិសនី ព្រមទាំងបន្តជំរុញការរៀបចំកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។

## ២៤. ទេសចរណ៍

- បន្តអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិប្រកបដោយគុណភាព និងចីរភាពដោយប្រកាន់ខ្ជាប់នូវទស្សនៈ «ការអភិវឌ្ឍន៍បម្រើឲ្យការអភិរក្ស និងការអភិរក្សបម្រើការអភិវឌ្ឍន៍» ដើម្បីចូលរួមទ្រទ្រង់កំណើនសេដ្ឋកិច្ច លើកស្ទួយជីវភាពរបស់ប្រជាជន និងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតងជានិន្នាការរួមនៃពិភពលោក។ ក្នុងដំណាក់កាលនេះ ចាំបាច់ត្រូវតែមានការអនុវត្តន៍ទន្ទឹមគ្នានូវការខិតខំបង្កើតសមត្ថភាពប្រកួតប្រជែង និងការធានាចីរភាព ដែលកើតចេញពីការអភិវឌ្ឍន៍វិស័យទេសចរណ៍ ព្រមជាមួយនេះ ក៏ត្រូវយកឲ្យបានផងនូវកាលានុវត្តភាពថ្មីនៃការអភិវឌ្ឍន៍ទេសចរណ៍ក្នុងតំបន់ និងពិភពលោក។
- ខិតខំសម្រេចគោលដៅទទួលទេសចរណ៍ ពីក្រៅប្រទេសនៅឆ្នាំ២០១៥ ប្រមាណ៤,៥លាននាក់ ឆ្នាំ២០១៨ កើនដល់៦,១លាននាក់ រួមជាមួយទេសចរណ៍ក្នុងស្រុកប្រមាណ១០,៥លាននាក់ ដែលអាចបង្កើតការងារដោយផ្ទាល់ជិត៧សែននាក់។
- បន្ទាប់ពីអភិវឌ្ឍន៍ អភិរក្ស ការពារ និងកែលម្អឲ្យសម្រេចបាននូវទីកន្លែងដែលមានសម្បត្តិវប្បធម៌ និងធនធានធម្មជាតិ ដែលជាគោលដៅទេសចរណ៍របស់ជាតិ ក្នុងនោះត្រូវយកចិត្តទុកដាក់ការគ្រប់គ្រង និងអភិវឌ្ឍន៍គោលដៅទេសចរណ៍សំខាន់ៗរបស់ជាតិ ប្រកបដោយស្មារតីទទួលខុសត្រូវ និងប្រុងប្រយ័ត្នខ្ពស់ ព្រមទាំងខិតខំជម្រុញការវិនិយោគ ក្នុងវិស័យទេសចរណ៍ និងបង្កើតផលិតផលទេសចរណ៍ថ្មីៗប្រកបដោយគុណភាពថែមទៀត។
- បន្តខិតខំថែរក្សាឲ្យបានល្អនូវរាល់គុណតម្លៃនៃសម្បត្តិមរតក និងធនធានរបស់ជាតិ ដើម្បីទ្រទ្រង់សកម្មភាពទេសចរណ៍យូរអង្វែង សំរាប់មនុស្សជំនាន់ក្រោយៗទៀត។
- ផ្តោតការយកចិត្តទុកដាក់លើតម្លៃរបស់ប្រជាជនមូលដ្ឋាន សហគមន៍នីមួយៗ និងជម្រុញឲ្យមានការការចែករំលែកបទពិសោធន៍ល្អៗ ប្រកបដោយគុណភាពដល់ភ្ញៀវទេសចរណ៍ និងប្រជាជនជាមូលដ្ឋាន ព្រមទាំងផ្តល់សេវាប្រកបដោយគុណភាព ដើម្បីបង្កើនកម្រិតនៃការពេញចិត្តរបស់ភ្ញៀវទេសចរណ៍ ក្នុងការទស្សនាកម្សាន្ត និងទាក់ទាញឲ្យមានការផ្សព្វផ្សាយបន្ត ព្រមទាំងការវិលត្រឡប់មកទស្សនាជាថ្មីទៀត។

- បន្តជំរុញឲ្យបណ្តាលភាគីពាក់ព័ន្ធទទួលផលប្រយោជន៍ ពីវិស័យទេសចរណ៍ ប្រកបដោយសមធម៌ ពោលគឺ បង្កើនអត្ថប្រយោជន៍សេដ្ឋកិច្ចជាអតិបរមា កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃវិស័យទេសចរណ៍មកលើសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន និងកាត់បន្ថយការធ្លុះធ្លាយក្នុងវិស័យទេសចរណ៍ឲ្យកាន់ តែតិចគឺត្រឹម១៥% នៅរយៈពេល៥ឆ្នាំខាងមុខ។
- ចូលរួមអនុវត្តទិសដៅនៃការអភិវឌ្ឍន៍បៃតង តាមរយៈការបន្តជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត ទីក្រុងបៃតង រមណីយដ្ឋានស្អាត រមណីយដ្ឋានបៃតង និងការចាប់យកទស្សនាទានថ្មីៗនៃភាពបៃតង និងភាពស្អាត ដោយបំផុសចលនា និងសកម្មភាពប្រើប្រាស់បច្ចេកវិជ្ជាបៃតង ដូចជាការប្រើអគ្គិសនីពីថាមពលកើតឡើងវិញ ការបង្កើនអនាម័យ ការដាំដើមឈើជាដើម។
- ខិតខំរកទីផ្សារទេសចរណ៍ដែលមានស្រាប់ និងពង្រឹងទីផ្សារថ្មីៗទៀត ពិសេសទីផ្សារក្នុងតំបន់ បង្កើនការផ្សព្វផ្សាយទេសចរណ៍តាមគ្រប់រូបភាព ជំរុញការតភ្ជាប់ និងសម្រួលការធ្វើដំណើរទេសចរណ៍ក្នុងតំបន់ ព្រមទាំងពង្រឹងការធានាសន្តិសុខ សុវត្ថិភាពដល់ទេសចរណ៍ និងអ្នកដំណើរនៅគ្រប់ទីកន្លែង។
- បង្កើនការចូលរួមពីគ្រប់ភាគី ដែលពាក់ព័ន្ធទាំងអស់ទាំងរដ្ឋ ឯកជន ប្រជាជន និងដៃគូអភិវឌ្ឍន៍ក្នុងការជំរុញវិស័យទេសចរណ៍កម្ពុជា។
- បន្តយកទុកដាក់ពង្រឹង និងពង្រីកបណ្តាលសហគមន៍ទេសចរណ៍មូលដ្ឋាន ដើម្បីលើកទឹកចិត្តប្រជាជនឲ្យចូលរួមអភិវឌ្ឍន៍វិស័យយទេសចរណ៍ ការពារបរិស្ថាន ការពាររធនធានវប្បធម៌ និងធម្មជាតិ។

## ២៥. បរិស្ថាន

- បន្តការថែរក្សា ការពារជីវៈចម្រុះ និងប្រព័ន្ធអេកូឡូសី ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ទាំងនៅដែនគោក ទាំងនៅដែនសមុទ្រ ដើម្បីជាប្រយោជន៍ដល់ប្រជាជនទូទៅ ទាំងពេលបច្ចុប្បន្ន ទាំងពេលអនាគត និងដើម្បីឆ្លើយតបចំពោះការអភិវឌ្ឍន៍ឧស្សាហកម្ម ដែលបញ្ចេញធាតុពុលកាន់តែច្រើន និងការប្រែប្រួលអាកាសធាតុជាសកល នៅពេលបច្ចុប្បន្ន ព្រមទាំងដើម្បីធានាដល់ការលូតលាស់នៃសង្គមសេដ្ឋកិច្ច និងការលើកកម្ពស់សុខមាភាពសាធារណៈ។
- បន្តបង្កើនកិច្ចការពារគុណភាពបរិស្ថាន និងអភិរក្សធនធានធម្មជាតិឲ្យមានចីរភាព ក្នុងប្រព័ន្ធអេកូឡូសីតាមរយៈការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតង ដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ជាពិសេសការចូលរួមរបស់សហគមន៍នៅមូលដ្ឋាន និងតាមរយៈការបង្រឹងស្ថាប័ន និងក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន។
- បន្តធ្វើសមាហរណកម្មបរិស្ថាន ទៅក្នុងផែនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ព្រមទាំងពង្រឹង និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យបរិស្ថាន ទាំងក្នុងក្របខ័ណ្ឌតំបន់និងអន្តរជាតិ។
- បន្តពង្រឹងច្បាប់ ស្តីពីបរិស្ថាន សំដៅថែរក្សាតំបន់ការពារធម្មជាតិ ទប់ស្កាត់រាល់សកម្មភាពបំផ្លាញគុណភាពបរិស្ថាន និងបញ្ចៀសគ្រោះមហន្តរាយនានា។
- យកចិត្តទុកដាក់វាយតម្លៃឲ្យបានហ្មត់ចត់នូវប៉ះពាល់បរិស្ថាន ក្នុងការអនុវត្តន៍គំរោងអភិវឌ្ឍន៍នានា ដើម្បីធានាការប្រើប្រាស់ធនធានធម្មជាតិ សម្រាប់ការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព។

- ពង្រឹងការគ្រប់គ្រងដីសម្បទានក្នុងតំបន់ប្រើប្រាស់ ប្រកបដោយចីរភាព សំរាប់គំរោងវិនិយោគអភិវឌ្ឍន៍ សំដៅការពារ ទប់ស្កាត់ការរុករានយកដីព្រៃនៃតំបន់ស្នូល និងតំបន់អភិរក្ស ហើយមួយផ្នែកទៀតជួយផ្តល់បច្ចេកទេសដល់ប្រជាសហគមន៍ដែលរស់នៅក្បែរនោះ។
- ជំរុញការអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ ដែលជួយដល់ការថែរក្សាបរិស្ថាន និងធនធានធម្មជាតិ។
- បង្កើនការត្រួតពិនិត្យ និងកាត់បន្ថយការបំពុលបរិស្ថាន ដែលរួមមានការគ្រប់គ្រងសំណល់រឹងសារធាតុប្របកដោយគ្រោះថ្នាក់ ការត្រួតពិនិត្យ និងបង្កើនគុណភាពខ្យល់ ការត្រួតពិនិត្យ និងស្កាត់ការបំពុលទឹក និងដី ព្រមទាំងការបំពុលសោតារម្មណ៍ និងចក្ខុអារម្មណ៍។

## ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច

- នៅក្នុងកិច្ចការអភិវឌ្ឍវិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច អប់រំ និងកីឡារាជរដ្ឋាភិបាលមានវិធានការគោលនយោបាយសំខាន់ៗ ដូចតទៅៈ

## អប់រំ និងកីឡា

## ២៦. បន្តកសាងនិងអភិវឌ្ឍធនធានមនុស្ស

លើគ្រប់ផ្នែកប្រកបដោយគុណភាព និងមានគុណធម៌ល្អប្រពៃ ដែលឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចដើម្បីកសាងកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើន ជឿនលឿន ដែលផ្អែកលើមូលដ្ឋានចំណេះដឹងលើគ្រប់វិស័យ រួមទាំងខាងវិទ្យាសាស្ត្រ បច្ចេកទេស និងចំណេះធ្វើហើយដើរស្របជាមួយនឹងការរីកចម្រើននៃបណ្តាលប្រទេសនៅក្នុងតំបន់និងពិភពលោក។

- បន្តលើកកម្ពស់គោលការណ៍ «អប់រំសម្រាប់ទាំងអស់គ្នា» តាមរយៈការធានានូវលទ្ធភាពបានសេវាអប់រំប្រកបដោយសមធម៌ ដែលផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និងយុវជនកម្ពុជាទាំងអស់បានទទួលការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ និងការអប់រំក្រៅប្រព័ន្ធ។ ការអនុវត្តន៍គោលការណ៍នេះ ត្រូវផ្សារភ្ជាប់នឹងការអប់រំមនសិការស្នេហាជាតិ ការអប់រំអំពីប្រវត្តិសាស្ត្រ ការអប់រំវប្បធម៌ សន្តិភាព ការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការគោរពគោលការណ៍សេរីភាពប្រជាធិបតេយ្យ និងយុត្តិធម៌សង្គម ការប្រឆាំងនឹងអំពើហិង្សា ការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន និងការរើងអើងគ្រប់រូបភាព។
- បន្តជំរុញការកសាងសាលារៀនឲ្យដល់ភូមិ,កាត់បន្ថយការចំណាយរបស់មាតាបិតាសិស្ស,បង្កើនថវិការចំណាយសម្រាប់គ្រឹះស្ថានសិក្សា,បង្រាយគ្រូបង្រៀនឲ្យដល់គ្រប់ទីកន្លែង,ពង្រឹងអន្តេវាកសិដ្ឋាន,បំផុសចលនាជាតិនិងពង្រីកការចូលរួមពីវិស័យឯកជនព្រមទាំងដៃគូរអភិវឌ្ឍន៍នានាដើម្បីអភិវឌ្ឍវិស័យអប់រំ។
- បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំដែរនៅមិនទាន់មានអនុវិទ្យាល័យនិងខិតខំឲ្យមានអនុវិទ្យាល័យច្រើនជាងមួយនៅក្នុងឃុំធំៗដែរមានសិស្សច្រើនស្របតាមភូមិសាស្ត្រ។
- បង្កើនគុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់កម្រិតសិក្សានិងការបណ្តុះបណ្តាលបច្ចេកទេសនិងមុខចំណេញទាំងក្នុងគ្រឹះស្ថានរដ្ឋទាំងគ្រឹះស្ថានឯកជន ឲ្យស្របតាមកម្រិតស្តង់ដារអន្តរជាតិ និងតម្រូវការអភិវឌ្ឍន៍របស់ប្រទេស តាមរយៈការពង្រឹងការងារបណ្តុះបណ្តាល និងរិត្រឹតការគ្រូបង្រៀន ការកែលំល្អកម្មវិធីសិក្សា ការធ្វើអធិការកិច្ច និងពង្រឹងសមត្ថភាពគ្រប់គ្រង ការលើកទឹកចិត្តគ្រូបង្រៀនក្នុងការបង្កើនសមត្ថភាពគ្រូបង្រៀន ការពង្រឹងគុណភាពក្នុងការប្រឡងបញ្ចប់កម្រិតសិក្សានីមួយៗ ការសិក្សា

ភាសាបរទេសដែលចាំបាច់ ការកែលម្អលក្ខខ័ណ្ឌនៃការសិក្សា ការបង្កើនបណ្ណាល័យ មន្ទីរពិសោធន៍ និងការបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សាជាដើម។

- បន្តអភិវឌ្ឍន៍ស្ថាន និងកសាងសមត្ថភាពរបស់មន្ត្រីអប់រំដោយបន្តការកសាងច្បាប់ និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធវិស័យអប់រំ ពង្រឹងរចនាសម្ព័ន្ធការងារ និងបណ្តុះបណ្តាលជំនាញដល់មន្ត្រីអប់រំសំដៅអភិបាលកិច្ចល្អនៅគ្រប់ថ្នាក់។

## ២៧. បន្តអភិវឌ្ឍវិស័យកីឡា

រួមទាំងកីឡាជនពិការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យមានការរីកចម្រើន ស្របជាមួយនឹងការរីកចម្រើននៃវិស័យកីឡា ក្នុងតំបន់ដោយពង្រឹងការអនុវត្តន៍គោលនយោបាយជាតិអភិវឌ្ឍវិស័យអប់រំកាយ និងកីឡាឲ្យមានប្រសិទ្ធភាពខ្ពស់សំដៅ រួមចំណែកដល់ការលើកកម្ពស់សុខភាពប្រជាជន ពង្រឹងសាមគ្គីភាព និងត្រៀមលក្ខណៈសម្បត្តិឲ្យបានល្អដើម្បីចូលរួម និងទទួលរៀបចំព្រឹត្តិការណ៍កីឡាធំៗជាលក្ខណៈអន្តរជាតិនានានៅពេលខាងមុខដូចជា អាស៊ានហ្គេម ជាដើម។

## ២៨. សុខាភិបាល

- បន្តយកចិត្តទុកដាក់អភិវឌ្ឍន៍វិស័យអប់រំសុខាភិបាល សំដៅធ្វើឲ្យកាន់តែប្រសើរឡើងនូវសុខភាពប្រជាជនដែលជាមូលដ្ឋានគន្លឹះមួយនៃការអភិវឌ្ឍន៍ធនធានមនុស្ស និងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច តាមរយៈការផ្តល់សេវាសុខភិបាលប្រកបដោយប្រសិទ្ធភាព គុណភាព សមធម៌ និងមានចីរភាពដល់ប្រជាជនទូទៅ ពិសេសប្រជាជនក្រីក្រងាយរងគ្រោះ និងប្រជាជនរស់នៅជនបទ។

- ការខិតខំកាតបន្ថយឲ្យបានជាអតិបរមានូវការស្លាប់របស់មាតាទារក និងកុមារ កាត់បន្ថយការឈឺ និងស្លាប់ដោយសារជម្ងឺឆ្លងនឹងជម្ងឺមិនឆ្លងរ៉ាំរ៉ៃ ព្រមទាំងការពង្រឹង និងពង្រីកនូវប្រព័ន្ធសុខាភិបាលឲ្យកាន់តែប្រសើរឡើង។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបន្តផ្តោតការយកចិត្តទុកដាក់ជំរុញអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់លើបណ្តាកម្មវិធីសំខាន់ៗ រួមមាន៖ (១).កម្មវិធីសុខភាពបន្តពូជ សុខភាពមាតាទារកនិងកុមារ អាហាររូបត្ថម្ភ និងការអប់រំសុខភាព ក្នុងខិតខំបង្កើនអត្រាគ្រប់ដណ្តប់នៃការផ្តល់លើថ្នាំបង្ការគ្រប់មុខ និងវ៉ាក់សាំងដល់កុមារ រួមទាំងការបញ្ចូលវ៉ាក់សាំងថ្មី និងការទប់ស្កាត់មិនឲ្យកើតមានតទៅទៀតនៅជម្ងឺកញ្ជ្រឹល និងជម្ងឺតេតាណុសលើទារក (២). កម្មវិធិប្រយុទ្ធនិងជម្ងឺឆ្លង ជាពិសេសជម្ងឺអេដស៍របេង គ្រុនចាញ់ គ្រុនឈាម និងជម្ងឺមិនឆ្លងរ៉ាំរ៉ៃ ក្នុងនោះខិតខំលុបបំបាត់ជម្ងឺគ្រុនចាញ់ឲ្យបានទាំងស្រុងនៅត្រឹមឆ្នាំ២០២៥ ព្រមទាំងយកចិត្តទុកដាក់ព្យាបាលអ្នកប្រើប្រាស់សារធាតុញៀននិង (៣). កម្មវិធីពង្រឹង និងពង្រីកប្រព័ន្ធសុខាភិបាលនៅគ្រប់ថ្នាក់ប្រកបដោយវិជ្ជាជីវៈ។

- បន្តបង្រីកវិសាលភាពនៃសុខាភិបាលសារធាណៈឲ្យកាន់តែខិតជិតប្រជាជន ដោយបន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៃវិស័យនេះ ដូចជាការសង់អគារមន្ទីរពេទ្យបង្អែក មណ្ឌលសុខាភាព ប៉ុស្តិ៍សុខភាព និងបង្កើតបន្ទប់រង់ចាំឲ្យបានច្រើនថែមទៀត ពង្រីកសកម្មភាពចុះផ្តល់សេវាសុខភាពតាមភូមិឃុំ ពង្រឹងយន្តការលើកលែងការបង់ថ្លៃសេវាពិនិត្យ និងព្យាបាលជម្ងឺសម្រាប់ប្រជាជនក្រីក្រ តាមរយៈការពង្រីកមូលនិធិសមធម៌ ការបង់ថ្លៃជួល ប្រព័ន្ធធានារ៉ាប់រងសុខភាពតាមសហគមន៍ និងរបបសន្តិសុខសង្គម។

- ពង្រឹងការផ្គត់ផ្គង់ឱសថឲ្យបានដល់គោលដៅ តាមរបបកំណត់ក្នុងថវិកាប្រចាំឆ្នាំ ព្រមទាំងបង្កើនការវិនិយោគលើឧបករណ៍បរិក្ខារពេទ្យ និងបច្ចេកវិជ្ជាទំនើបនៅមន្ទីរបង្អែកថ្នាក់ជាតិ និងខេត្ត។

- ពង្រឹងសមត្ថភាពជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីបុគ្គលិកសុខាភិបាលគ្រប់ជាន់ថ្នាក់ ដើម្បីផ្តល់សេវាជូនប្រជាជនប្រកបដោយភាពថ្លៃថ្នូរ រាក់ទាក់ យកចិត្តទុកដាក់ និងព្យាបាលអ្នកជម្ងឺគ្រប់រូបដោយគ្មានការរើសអើង។
- បន្តពង្រឹងការគ្រប់គ្រងវិស័យឯកជន ដើម្បីឈានទៅដល់ការលុបបំបាត់ឱសថក្លែងក្លាយ សេវាឯកជនខុសច្បាប់ និងធានាការប្រកបអាជីវៈកម្មសេវាឱសថ និងសេវាសុខភាពឲ្យប្រព្រឹត្តទៅក្រោមលក្ខខណ្ឌច្បាប់។
- បន្តលើកកម្ពស់ការចូលរួមរបស់សហគមន៍ និងភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនដើម្បីបង្កើនការវិនិយោគក្នុងវិស័យសុខាភិបាល ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស ការផ្តល់សេវាសុខភាព និងការងារស្រាវជ្រាវជាដើម ព្រមទាំងរួមចំណែកពង្រឹងអន្តរាគមន៍សុខភាពសាធារណៈ។

## ២៩. ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បន្តអភិវឌ្ឍន៍ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលតម្រង់ទិសលើការធ្វើឲ្យប្រជាជនមានការងារធ្វើមានមុខរបរសមរម្យ ត្រឹមត្រូវ និងថ្លៃថ្នូរ ការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់និយោជក និងកម្មករ និយោជិត ព្រមទាំងការកសាង និងលើកកម្ពស់សមត្ថភាពបច្ចេកទេស និងវិជ្ជាជីវៈឲ្យរីកចម្រើនស្របតាមបទដ្ឋានអន្តរជាតិ។
- បន្តលើកកម្ពស់លក្ខខណ្ឌការងារឲ្យបានកាន់តែប្រសើរឡើង ដោយពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីការងារ បទដ្ឋានគតិយុត្តនានា និងអនុសញ្ញាអន្តរជាតិខាងការងារ។
- បន្តពង្រឹងការអនុវត្តន៍សេរីភាពសហជីព និងអង្គការវិជ្ជាជីវៈ ប្រឆាំងការរើសអើងសហជីព និងអង្គការវិជ្ជាជីវៈ ជំរុញការកសាងច្បាប់ ស្តីពីសហជីព និងច្បាប់ស្តីពីការបង្កើតតុលាការងារ។
- ពង្រីកសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ រវាងកម្មករ និយោជិត និងនិយោជក ព្រមទាំងពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារនៅតាមសហគ្រាស និងគ្រឹះស្ថាននានាឲ្យបានល្អប្រសើរ។
- បន្តការជំរុញតំឡើងប្រាក់ឈ្នួល ការផ្តល់ប្រាក់ឧបត្ថម្ភ និងប្រាក់អត្ថប្រយោជន៍នានាដល់កម្មករ និយោជិត។
- ខិតខំធ្វើឲ្យមានតុល្យភាពរវាងតម្រូវការ និងការផ្គត់ផ្គង់នៅក្នុងទីផ្សារពលកម្ម។
- យកចិត្តទុកដាក់ទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្រោមអាយុកំណត់នៅតាមសហគ្រាស។
- រៀបចំគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ ស្របទៅនឹងការវិវឌ្ឍន៍នៃសង្គម សេដ្ឋកិច្ច។
- ពង្រឹងប្រព័ន្ធផ្សព្វផ្សាយ និងយន្តការសេវារកការងារធ្វើ ស្របច្បាប់សម្រាប់ពលកម្មកម្ពុជា ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។ ទន្ទឹមនេះ យកចិត្តទុកដាក់រក្សាតុល្យភាពកម្លាំងពលកម្មសម្រាប់ទីផ្សារការងារក្នុងស្រុក។
- បង្កើនការការពារពលករខ្មែរ ដែលត្រូវបានបញ្ជូនទៅធ្វើការនៅបរទេស ទន្ទឹមនឹងការគ្រប់គ្រងកម្លាំងពលករបរទេស ដែលធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ជាតិ និងគោលការណ៍ សមាហរណកម្មរបស់សមាគមអាស៊ាន។

- ជំរុញការអនុវត្តន៍ច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមច្បាប់ ស្តីពីការងារ ក្នុងនោះរួមមាន ការបន្តពង្រឹង និងពង្រីករបបធានារ៉ាប់រងហានិភ័យការងារឲ្យបានគ្របដណ្តប់ទូទាំងប្រទេស ការដាក់ឲ្យដំណើរការ របបធានារ៉ាប់រងហានិភ័យការងារឲ្យបានគ្របដណ្តប់ទូទាំងប្រទេស ការដាក់ឲ្យដំដំណើរការរបបសោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជនឲ្យទទួលបានរបបប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការដែរ ចាប់ពីឆ្នាំ២០១៥។
- បន្តអភិវឌ្ឍន៍ធនធានមនុស្សលើផ្នែកបច្ចេកទេស ឲ្យឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ដោយជំរុញការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយគុណភាពប្រសិទ្ធភាព និងស្របតាមតម្រូវទីផ្សារការងារ។
- ពង្រីកបណ្តាលក្ខខណ្ឌអនុគ្រោះប្រជាជន ជាពិសេសស្រទាប់យុវវ័យឱ្យបានទទួលការបណ្តុះបណ្តាលជំនាញរយៈពេលខ្លី ឬមធ្យមប្រកបដោយសមធម៌តាមគ្រប់រូបភាព ដើម្បីមានលទ្ធភាពបង្កើតមុខរបរដោយខ្លួនឯង ឬរកការងារធ្វើនៅតាមរោងចក្រ សហគ្រាស ការដ្ឋាននានា ឬទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស។
- ផ្តោតការយកចិត្តទុកដាក់លើការសំរបសំរួលឲ្យស៊ីចង្វាក់គ្នា រវាងវិស័យអប់រំ និងវិស័យបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
- ជំរុញការកសាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឲ្យមាននៅគ្រប់ខេត្ត ដែលអាចផ្តល់ការបណ្តុះបណ្តាលនៅតាមសហគមន៍ ព្រមទាំងរួមចំណែកដល់ទិសដៅ «ភូមិមួយ/ផលិតផលមួយ»។
- ពង្រីកលទ្ធភាពបង្កើតអន្តេវាសិកដ្ឋាននៅតាមគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេលទេស និងវិជ្ជាជីវៈ សម្រាប់សិស្ស និស្សិត សិក្ខាកាមដែលមានលំនៅឆ្ងាយៗស្នាក់នៅ។
- លើកទឹកចិត្តការចូលរួមនៃវិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការពង្រីកកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសសមស្របឲ្យកាន់តែមានវិសាលភាព ឆ្លើយតមទៅនឹងតម្រូវការសង្គម។

## ៣០. វប្បធម៌ ជំនឿ សាសនា

- បន្តការលើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ធម្មជាតិ ដើម្បីថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិទាំងរូបិយ និងឲ្យស្ថិតស្ថេរគង់វង្សយូរអង្វែង បង្កើតផលិតផលវប្បធម៌ឲ្យបានកាន់តែច្រើន ហើយចូលរួមសកម្មភាពក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកែលម្អជីវភាពប្រជាជន ស្របតាមអត្ថន័យវប្បធម៌ជាសេដ្ឋកិច្ច។
- បន្តផ្តោតលើសកម្មភាពសំខាន់ៗជាអាទិភាព គឺការថែរក្សា និងអភិវឌ្ឍន៍តំបន់បេតិកភណ្ឌ ឲ្យមាននិរន្តរភាព ការថែទាំ និងការអភិរក្សប្រាសាទបុរាណនានា ការជំរុញឲ្យកម្ពុជាក្លាយជាមជ្ឈមណ្ឌលមួយនៃការផ្សព្វផ្សាយសិល្បៈ ទស្សនីភាព ការផ្សព្វផ្សាយផលិតផលសូនរូប និងសិល្បៈសិប្បកម្ម ការពង្រីកសកម្មភាពវប្បធម៌លើគ្រប់ជំនាញ និងការខិតខំពង្រីកទីផ្សារវប្បធម៌ឲ្យកាន់តែលូតលាស់ ទាំងក្នុងប្រទេស និងក្រៅប្រទេសដែលនឹងជំរុញថែមទៀតដល់ផលិតផលវប្បធម៌ខ្មែរ។

- បង្កើនការងារអប់រំ ពិសេសការអប់រំស្រទាប់យុវជន និងកុមារឲ្យយល់ដឹងច្បាប់អំពីតម្លៃដ៏វិសេសវិសាល នៃវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរដែលជាអត្តសញ្ញាណរបស់ជាតិ ហើយចូលរួមថែរក្សា លើកតំកើង អភិវឌ្ឍន៍វប្បធម៌ជាតិ និងកាត់បន្ថយឥទ្ធិពលវប្បធម៌វិជ្ជមានពីបរទេស។
- បង្កើនការផ្លាស់ប្តូរសកម្មភាពវប្បធម៌សិល្បៈ ជាមួយបណ្តាប្រទេសជាតិដើម្បីសន្តិភាព សុខដុមនីយកម្ម និងការអភិវឌ្ឍន៍។
- ថែរក្សា និងអភិវឌ្ឍន៍វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អ និងភាសារបស់បងប្អូនជនជាតិដើមភាគតិច។
- បន្តគោរពសេរីភាពខាងជំនឿ និងសាសនាលើកស្ទួយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ជាពិសេសការបន្តពង្រឹងពុទ្ធិកសិក្សានៅគ្រប់កម្រិត ការបោះផ្សាយគម្ពីរដីកា ក្បួនច្បាប់នានា និងកិច្ចប្រតិបត្តិធម្មវិន័យ ទន្ទឹមនេះ គាំទ្រសកម្មភាពនៃសាសនាផ្សេងៗទៀតក្នុងសង្គម។
- ពង្រឹងសុខដុមនីយកម្ម រវាងសាសនិកនៃគ្រប់សាសនា ប្រឆាំងការរើសអើង បែងចែកក្នុងចំណោមប្រជាជន ដែលបណ្តាលមកពីភាពខុសគ្នាខាងសាសនា សំដៅប្រែក្លាយសក្តានុពលរបស់សាសនាទាំងអស់ទៅជាកម្លាំង ជំរុញការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ពង្រឹងសន្តិភាព ថែរក្សាប្រពៃណីជាតិ និងលើកកម្ពស់តម្លៃសីលធម៌។
- រាំងស្កាត់ការយកសាសនាទៅធ្វើអាជីវកម្ម និងបង្កជាវិបត្តិសាសនា។

## ៣១. សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បន្តអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឲ្យកាន់តែមានវិសាលភាពទូលំទូលាយ រួមចំណែកធ្វើឲ្យ សុខុមាលភាពរបស់ប្រជាជនមានស្ថានភាពកាន់តែប្រសើរឡើង ដោយមានសេវាសង្គមកិច្ចគ្រប់គ្រាន់សម្រាប់ជួយជនរងគ្រោះ និងជនងាយរងគ្រោះគ្រប់ប្រភេទ មានប្រព័ន្ធសន្តិសុខសង្គមរឹងមាំ និងទូលំទូលាយសម្រាប់ធានារ៉ាប់រងចំពោះហានិភ័យសង្គមជាយថាហេតុ ហើយធ្វើឲ្យសេវាសង្គមកិច្ចកាន់តែនៅកៀកប្រជាជន ព្រមទាំងមានការចូលរួមដ៏សកម្មពីប្រជាជន។
- ជំរុញការបង្កើនអន្តរាគមន៍សង្គមកិច្ច ដើម្បីជួយប្រជាជនក្រីក្រងាយរងគ្រោះ និងជួយជនរងគ្រោះមហន្តរាយផ្សេងៗ តាមរយៈការលើកកម្ពស់សន្តិសុខស្បៀង បន្តពង្រឹង និងពង្រីកកម្មវិធីសង្គ្រោះបន្ទាន់សម្រាប់ប្រជាជនក្រីក្រងាយរងគ្រោះ ទប់ស្កាត់ទុរគតភាព និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។
- ពង្រឹងកម្មវិធីដោះស្រាយបញ្ហាជនអនាថា ជំរុញការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស យកចិត្តទុកដាក់ងអភិវឌ្ឍន៍សហគមន៍ប្រជាជនក្រីក្រឲ្យបានទទួលកាលានុវត្តភាពសម្រាប់កែលម្អជីវភាព។
- ខិតខំបង្កើតប្រព័ន្ធសន្តិសុខសង្គមឲ្យបានទូលំទូលាយ គ្របដណ្តប់គ្រប់ស្រទាប់ប្រជាជន និងគ្រប់មជ្ឈដ្ឋាន ធ្វើជាស្នូលនៃសំណាញសុវត្ថិភាពសង្គម និងជំរុញការអនុម័តច្បាប់ ស្តីពីរបបសន្តិសុខសង្គមសំរាប់ប្រជាជនកម្ពុជា។
- លើកកម្ពស់ការអនុវត្តន៍ការងារយុវនីតិសម្បទា និងការអនុវត្តន៍កម្មវិធីយុត្តិធម៌អនីតិជន តាមរយៈការពង្រឹង និងការព្យាបាលស្តារនីតិសម្បទាសម្រាប់ជួយជនរងគ្រោះ ដែលប្រើប្រាស់សារធាតុញៀនតាម

មណ្ឌល ព្រមជាមួយនោះ លើកទឹកចិត្តការព្យាបាល និងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀននៅតាមសហគមន៍។

- បន្តអនុវត្តគោលនយោបាយជាតិ ចំពោះជនពិការ ជំរុញកិច្ចការពារលើកកម្ពស់សុខុមាលភាពជនពិការតាមអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ និងការអនុវត្តន៍ច្បាប់ ស្តីពីកិច្ចការពារលើកកំពស់សិទ្ធិជនពិការ ផ្តល់សេវាស្តារលទ្ធភាពពលកម្ម ដោយមិនបង់ថ្លៃសម្រាប់ជនពិការក្រីក្រ ពង្រីកសេវាសហគមន៍ អនុវត្តគោលនយោបាយឧបត្ថម្ភជនពិការក្រីក្រតាមសហគមន៍ និងបង្កើនការចូលរួមរបស់ជនពិការក្នុងគ្រប់សកម្មភាព។
- បន្តអនុវត្តគោលនយោបាយជាតិសម្រាប់មនុស្សចាស់ ដោយយកចិត្តទុកដាក់ជំរុញការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍មនុស្សចាស់តាមសហគមន៍ និងកម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារឲ្យកាន់តែប្រសើរ ពង្រឹងសកម្មភាពសហគមន៍មនុស្សចាស់នៅតាមឃុំ-សង្កាត់ លើកទឹកចិត្តចំពោះការបង្កើតកម្មវិធីមនុស្សធម៌នានា ដើម្បីជួយដល់ជនចាស់ជរា ជំរុញការរៀបចំ និងដំណើរការសេវាជនចាស់ជរាដើម្បីបណ្តុះបណ្តាលភ្នាក់ងារផ្តល់សេវាថែទាំចាស់ជរា។
- បន្តអនុវត្តគោលនយោបាយជាតិ ចំពោះអតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិលឲ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការអនុវត្តន៍គោលនយោបាយរដ្ឋ ទទួលបន្ទុកបង់ប្រាក់វិភាគទាន៦%នៃប្រាក់បៀវត្សជួសមន្ត្រីរាជការស៊ីវិលសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល និងរដ្ឋ បង់ប្រាក់វិភាគទានតាមការកំណត់ជួសកងកម្លាំងប្រដាប់អាវុធសម្រាប់ទ្រទ្រង់បេឡាជាតិអតីតយុទ្ធជន។
- ពង្រឹងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិសម្រាប់អតីតយុទ្ធជន និងមូលនិធិជនពិការ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានលក្ខណៈហិរញ្ញវត្ថុ មិនមែនធនាគារជាគ្រឹះស្ថានសោធន៍សម្រាប់ផ្តល់សេវាសន្តិសុខសង្គមផង និងអនុវត្តយុទ្ធសាស្ត្រជាតិនៃហិរញ្ញវត្ថុផង។
- បន្តអនុវត្តគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ច កសាងលំនៅដ្ឋានជូនកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលមានតម្រូវការពិតប្រាកដ ព្រមទាំងបង្កើតគំរោងជាច្រើនថែមទៀត ដើម្បីកែលម្អជីវភាពយោធិន និងអតីតយុទ្ធជន។
- ពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងសប្បុរសជនដើម្បីពង្រីកស្មារតីសាមគ្គីធម៌នៅក្នុងសង្គម កៀងគរប្រភពធនធានថវិកា សម្ភារៈបច្ចេកទេសសំរាប់បំរើឲ្យសំណូមពរនៃការងារសង្គមកិច្ច និងការជួយដល់ជនក្រីក្រងាយរងគ្រោះ។

## ៣២. ស្ត្រី និងកុមារ

- បន្តពង្រឹងស្ថានភាព និងតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងសង្គម លើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ លុបបំបាត់រាល់ទស្សនៈមើលស្រាលតួនាទីរបស់ស្ត្រី សំដៅទៅលើកកម្ពស់ការចូលរួមរបស់ស្ត្រីឲ្យកាន់ទូលំទូលាយ និងខ្លាំងក្លាថែមទៀតនៅក្នុងការកសាងការពារមាតុភូមិ។
- បន្តលើកកម្ពស់សមធម៌យេនឌ័រ ជំរុញភាពអង់អាចរបស់ស្ត្រីក្នុងសេដ្ឋកិច្ច ដោយជំរុញការបណ្តុះបណ្តាលបំពាក់បំប៉នជំនាញបច្ចេកទេស និងផ្តល់កាលានុភាពដល់ស្ត្រី ក្នុងការពង្រឹងមុខរបរ បង្កើន

ចំណូល និងកសាងសហគ្រិនភាព បង្កើនឱកាសរៀនសូត្រសម្រាប់ស្ត្រី និងក្មេងស្រី ពិសេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។

- ពង្រឹងលទ្ធភាព ក្នុងការទទួលបានសេវាសុខាភិបាលប្រកបដោយគុណភាពសម្រាប់ស្ត្រី និងស្រី ជាពិសេសនៅតំបន់ជនបទ។
- ជំរុញកម្មវិធីអប់រំសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ សំដៅពង្រីកវប្បធម៌អហឹង្សា ការកសាងគ្រួសារ និងសហគមន៍ប្រកបដោយសុភមង្គល។
- ពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពីការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ពិសេសការអនុវត្តន៍ផែនការជាតិ ស្តីពីការទប់ស្កាត់អំពើហឹង្សាលើស្ត្រីដើម្បីលុបបំបាត់នូវឥរិយាបថអំពើហឹង្សាលើស្ត្រី។
- បន្តបង្កើនសមាមាត្រការចូលរួមរបស់ស្ត្រីឲ្យបានកាន់តែច្រើនឡើង ក្នុងស្ថាប័នជាតិគ្រប់ជាន់ថ្នាក់ ដើម្បីឲ្យស្ត្រីបានចូលកាន់តែសកម្មក្នុងការធ្វើសេចក្តីសម្រេចនានា ក៏ដូចជាក្នុងការកសាងផែនការអភិវឌ្ឍន៍ និងអភិបាលកិច្ចទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- បន្តផ្តល់អាទិភាពលើការអភិវឌ្ឍន៍សុខុមាលភាពកុមារឲ្យកាន់តែប្រសើរ ដោយជំរុញការផ្សព្វផ្សាយ និងអនុវត្តយ៉ាងហ្មត់ចត់នូវអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធកុមារ ពិសេសជានាឲ្យកុមារបានទទួលពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺ«សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍន៍ សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួមរបស់កុមារ។
- បន្តខិតខំសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា ដែលពាក់ព័ន្ធនឹងកុមារ តាមរយៈការពង្រឹងការអនុវត្តន៍នយោបាយថែទាំជំនួសចំពោះកុមារ ការថែទាំកុមារតាមគ្រួសារ និងសហគមន៍ ការបង្កើនការគ្រប់គ្រង និងគុណនៃការថែទាំកុមារនៅតាមមណ្ឌល ទាំងមណ្ឌលរដ្ឋ និងមណ្ឌលនៃអង្គការមិនមែនរដ្ឋាភិបាល ការអនុវត្តន៍មឹងម៉ាត់នូវអនុសញ្ញាអន្តរជាតិ និងច្បាប់ជាធរមានដើម្បីរកគ្រួសារល្អសម្រាប់កុមារនៅក្នុងប្រទេស និងអន្តរប្រទេស រាំងស្កាត់ការធ្វើអាជីវកម្មតាមគ្រប់រូបភាព។

## ៣៤. យុវជន

- បន្តជំរុញការអភិវឌ្ឍន៍យុវជនឲ្យមានការរីកចម្រើនគ្រប់ផ្នែក ទាំងខាងចំណេះដឹង ចំណេះធ្វើ សុខភាពកាយសម្បទាន និងមានសីលធម៌រស់នៅថ្លៃថ្នូរ ចៀសផុតពីអំពើអបាយមុខ និងអំពើហឹង្សា ហើយប្តេជ្ញាឈ្នះក្នុងការបំពេញរាល់ភារកិច្ចរបស់ខ្លួន តាមរយៈ(១).ការបន្តការលើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ចំណេះដឹងវិទ្យាសាស្ត្រ បច្ចេកទេស និងកម្មវិធីបំណិនជីវិតដល់យុវជន ពិសេសយុវជនមិនសូវមានលទ្ធភាព យុវជនងាយរងគ្រោះ និងយុវជនពិការឲ្យមានសមត្ថភាព និងកាលានុវត្តភាព និងក្នុងការបង្កើតមុខរបរ ឬស្វែងរកការងារធ្វើក្នុងទីផ្សារពលកម្ម ដែលកំពុងតែមានការរីកចម្រើន (២). ការបង្កើនការអប់រំ ការថែទាំ និងផ្តល់សេវាសុខភាពប្រកបដោយគុណភាព និងសមធម៌ដល់យុវជន ពង្រឹងសកម្មភាពសិល្បៈ កីឡា ការកម្សាន្តសម្រាប់យុវជនសំដៅពង្រឹងកាយសម្បទាន សុខភាព និងសាមគ្គីភាពក្នុងជួរយុវជន យុវនារី (៣). ការបន្តការពារសន្តិសុខ សុវត្ថិភាព និងយុត្តិធម៌សម្រាប់យុវជន យកចិត្តទុកដាក់បញ្ចូលតំរូវការរបស់យុវជន ទៅក្នុងផែនការអភិវឌ្ឍន៍គ្រប់កម្រិត ពង្រឹងការបណ្តុះបណ្តាល ភាពជាអ្នកដឹកនាំ និងជំរុញការអនុវត្តន៍ជាជំហានៗនូវទិសដៅយុវភាវូបនីយកម្ម ក្នុងផ្តល់ការទទួល

ខុសត្រូវនៅគ្រប់លំដាប់ថ្នាក់យុវជន ដើម្បីឲ្យយុវជនកាន់តែពង្រីកនៅឱកាស និងសមត្ថភាពរបស់ខ្លួនក្នុងការអភិវឌ្ឍន៍ប្រទេស។ (៤). ការលើកទឹកចិត្ត ពង្រឹងចលនាស្មគ្រ័ចិត្តរបស់យុវជនចូលរួមក្នុងសកម្មភាពកសាងយុត្តិធម៌ក្នុងសង្គម ការទប់ស្កាត់បាតុភាពអសកម្មតាមសហគមន៍ និងសកម្មផ្សេងៗទៀត ដើម្បីបម្រើផលប្រយោជន៍ប្រជាជននៅតាមមូលដ្ឋាន ក៏ដូចផលប្រយោជន៍សាធារណៈ (៥). ការជំរុញចលនាកាយរិទ្ធនៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដើម្បីរួមចំណែកបង្កលក្ខណៈឲ្យសមាជិកកាយរិទ្ធគ្រប់រូបក្លាយជាពលរដ្ឋ ដែលមានការរីកចម្រើនពេញលេញ ទាំងកាយសម្បទា ចំណេះដឹង និងបញ្ញាស្មារតី មានការទទួលខុសត្រូវចំពោះខ្លួនឯង ចំពោះគ្រួសារ និងសង្គម ហើយចូលរួមក្នុងសកម្មភាពនានាដែលផ្តល់ប្រយោជន៍ដល់សហគមន៍ សង្គមជាតិ និងអន្តរជាតិ (៦). ការជំរុញចលនាយុវជនកាកបាទក្រហម ដើម្បីពង្រឹង និងពង្រីកស្មារតីមនុស្សធម៌ឲ្យបានទូលំទូលាយក្នុងមហាជន តាមគោលការណ៍របស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិ ព្រមទាំងចូលរួមក្នុងសកម្មភាពនានា ដូចជាការអប់រំយុវជន អប់រំបញ្ញាសុខភាព អំពីសុវត្ថិភាព ចរាចរណ៍ និងការរក្សាអនាម័យនៅតាមមូលដ្ឋានជាដើម។

# ទម្រង់សំនួរផ្តល់ពិន្ទុលើលទ្ធផល នៃការបំពេញ/អនុវត្តន៍គោលនយោបាយមិនមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល

## វេទិកាម្ចាស់ឆ្នោត

## ស្តីពី

## ការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ

## របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា (ឆ្នាំទី២)

## ទម្រង់សំណួរសម្រាប់ការផ្តល់

សូមធ្វើការវាយតម្លៃដោយដាក់ពិន្ទុពីលេខ១ ដល់៥ លើចំណុចនីមួយៗ

១= មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច (០-២០%) ២= ពេញចិត្តខ្លះ (២១%-៤០%),

៣= ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល (៤១%-៦០%) ៤= ពេញចិត្តច្រើន (៦១%-៨០%),

៥= ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង (៨១%-១០០%)

## កម្រងសំណួរផ្តល់ពិន្ទុលើអនុវត្តន៍

## កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៥

## មិនមានសូចនាករច្បាស់លាស់ និងគោលនយោបាយសង្ខេបរួម

| | |
|---|---|
| **វិស័យ៖ ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** | |
| ១ | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាល លើការពង្រឹងកិច្ចការពារអធិបតេយ្យជាតិ និងការចាត់ចែងកងកំលាំងប្រដាប់អាវុធក្នុងកំរិតណា?<br>**១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០% |
| | <u>**គោលនយោបាយសង្ខេបរួម៖**</u><br>ពង្រឹងកិច្ចការពារអធិបតេយ្យជាតិ នៃព្រះរាជាណាចក្រកម្ពុជាលើដែនដីគោក ដែនកោះ ផ្ទៃក្នុងសមុទ្រ តំបន់តភ្ជាប់, តំបន់សេដ្ឋកិច្ចផ្តាច់មុខ, ខ្ពង់រាបបាតសមុទ្រ និងដែនអាកាស។ |
| ២. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយ រក្សាសន្តិសុខជាតិ និងសង្គម និងការដោះស្រាយបញ្ហាអន្តោប្រវេសន៍ខុសច្បាប់របស់រដ្ឋាភិបាលក្នុងកំរិតណា?<br>**១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០% |
| | <u>**គោលនយោបាយសង្ខេបរួម៖**</u><br>ការពារសន្តិសុខជាតិ ប្រឆាំងដាច់ខាត រាល់អំពើដែលនាំទៅដល់ការបង្កអស្ថិរភាពនយោបាយ ការបង្កជម្លោះប្រដាប់អាវុធជាតិ ឬជាមួយប្រទេសជិតខាង និងមិនអនុញ្ញាតឲ្យប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង បង្ការដាច់ខាតមិនឲ្យកើតមានការគំរាម បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអាយុជីវិត ឬមហន្តរាយដែលបង្កឡើងដោយអំពើភេរវកម្ម។ |
| **វិស័យ៖ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការព្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ** | |
| ៣. | តើអ្នកពេញចិត្តលើការបំពេញ/អនុវត្តន៍គោលនយោបាយកែទម្រង់រដ្ឋបាលសាធារណៈ ឬសេវាកម្មរដ្ឋបាលសា |

| | |
|---|---|
| | ធារណៈរបស់រដ្ឋាភិបាលកម្ពុជាក្នុងកំរិតណាមួយ?<br>១. ០-២០% ២. ២១%-៤០% ៣. ៤១%-៦០% ៤. ៦១%-៨០% ៥.៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>លើកកម្ពស់វប្បធម៌សាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈរបស់មន្ត្រីរាជការ ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈ ទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព និងដែលបម្រើប្រជាជនបានកាន់តែល្អប្រសើរឡើង។ |
| ៤. | តើអ្នកពេញចិត្ត ការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើកំណែទម្រង់វិមជ្ឈការ វិសហាមជ្ឈការនៅថ្នាក់ក្រោមជាតិកំរិតណា?<br>១. ០-២០% ២. ២១%-៤០% ៣. ៤១%-៦០% ៤. ៦១%-៨០% ៥.៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>ពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ គ្រប់ស្ថាប័ន និងប្រព័ន្ធគ្រប់គ្រង បន្តអភិវឌ្ឍន៍ធនធានមនុស្ស ការផ្ទេរមុខងារ និងធនធាន ព្រមទាំងប្រព័ន្ធថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ។ |
| ៥. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្នុងកំរិតណា?<br>១. ០-២០% ២. ២១%-៤០% ៣. ៤១%-៦០% ៤. ៦១%-៨០% ៥. ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>ជម្រុញការរៀបចំក្របខ័ណ្ឌច្បាប់ឲ្យមានប្រសិទ្ធភាព និងកាន់តែទទួលបានការជឿទុកចិត្ត ព្រមទាំងពង្រឹងសមត្ថភាពមិនលម្អៀងនៃស្ថាប័នតុលាការ ដែលជាកត្តាដ៏សំខាន់នៃដំណើរការពង្រឹងនីតិរដ្ឋ ការបែងចែកអំណាចដាច់ពីគ្នា ការគោរពសិទ្ធិបុគ្គល និងការធានាភាពយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋទូទៅ។ |
| ៦. | តើអ្នកពេញចិត្តលើបំពេញ/អនុវត្តន៍គោលយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ក្នុងកំរិតណា?<br>១. ០-២០% ២. ២១%-៤០% ៣. ៤១%-៦០% ៤. ៦១%-៨០% ៥. ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>ពង្រឹង និងការបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធានការលើកស្ទួយទាំង៣គឺៈ ការអប់រំដើម្បីឲ្យម្នាក់ៗ ទាំងអ្នកដើមចម និងអ្នកទទួលផលមិនប្រព្រឹត្តអំពើពុករលួយ ការបង្ការទប់ស្កាត់ដើម្បីម្នាក់ៗ មិនអាចប្រព្រឹត្តអំពើពុករលួយនិងការបង្ក្រាបបទល្មើសបញ្ជូនទៅតុលាការដើម្បីឲ្យម្នាក់ៗមិនហ៊ានប្រព្រឹត្តអំពើពុករលួយ។ |
| **វិស័យ៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ច** | |
| ៧. | តើអ្នកពេញចិត្តនឹងការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើការបន្តរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពក្នុងកំរិតណា?<br>១. ០-២០% ២. ២១%-៤០% ៣. ៤១%-៦០% ៤. ៦១%-៨០% ៥. ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសមស្រប គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏ប្រយ័ត្នប្រយែងប្រកបដោយប្រសិទ្ធភាព និងបន្តការខិតខំធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច ដោយឈរលើមូលដ្ឋានភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា និងការផ្សារភ្ជាប់សេដ្ឋកិច្ចកម្ពុជាជាមួយបណ្តាផលិតផលក្នុងតំបន់។ |
| ៨. | តើអ្នកពេញចិត្តក្នុងកំរិតណា ចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល លើការប្រមូលថវិកាជាតិ និងផ្តល់អាទិភាពចំណាយលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធ ការបង្កើនសមត្ថភាព និងការលើកកម្ពស់ជីវភាពរបស់មន្ត្រី រាជការ និងកងកម្លាំងប្រដាប់អាវុធ? |

| | |
|---|---|
| | ១. ០-២០%　　២. ២១%-៤០%　　៣. ៤១%-៦០%　　៤. ៦១%-៨០%　　៥. ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តខិតខំជម្រុញការប្រមូលចរិកាជាតិ ទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធឲ្យមានកំណើនជារៀងរាល់ឆ្នាំ។ ទន្ទឹមនេះ ការគ្រប់គ្រងការប្រមូលចំណូល និងការចាត់ចែងចំណាយត្រូវផ្តោតការយកចិត្តទុកដាក់លើប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព គួបផ្សំជាមួយនឹងការបន្តយកចិត្តទុកដាក់ខ្ពស់ជានិច្ចក្នុងការគ្រប់គ្រងបំណុលសាធារណៈ ឲ្យស្ថិតក្នុងលទ្ធភាពទ្រទ្រង់នៃសេដ្ឋកិច្ចជាតិ។ |
| ៩. | តើអ្នកពេញចិត្តក្នុងកំរិតណា ចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល លើការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដោយរក្សាស្ថិរភាពប្រាក់រៀល និងជម្រុញការប្រើប្រាស់ប្រាក់រៀលលើមូលដ្ឋានស្ថិរភាពតម្លៃប្រាក់រៀល និងកាត់បន្ថយការប្រើប្រាស់ប្រាក់ដុល្លារ?<br>១. ០-២០%　　២. ២១%-៤០%　　៣. ៤១%-៦០%　　៤. ៦១%-៨០%　　៥.៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>កសាងប្រព័ន្ធហិរញ្ញវត្ថុមួយចំនួនដ៏រឹងមាំ មានការគ្រប់គ្រង និងការត្រួតពិនិត្យសមស្រប មានលក្ខណៈប្រកួតប្រជែង និងសមាហរណកម្ម ព្រមទាំងមានតម្លាភាព និងប្រសិទ្ធភាព ជាពិសេសផ្អែកលើគោលការណ៍ទីផ្សារដែលបម្រើឲ្យការគៀងគរ និងបែងចែកធនធានប្រកបដោយប្រសិទ្ធភាព។ |
| ១០. | តើអ្នកពេញចិត្ត ការបំពេញ/អនុវត្តន៍គោលនយោបាយសហប្រត្តិការអភិវឌ្ឍន៍ រវាងរាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន សង្គមស៊ីវិល ឬអង្គការអន្តរជាតិក្នុងកំរិតណា?<br>១. ០-២០%　　២. ២១%-៤០%　　៣. ៤១%-៦០%　　៤. ៦១%-៨០%　　៥.៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>ពង្រឹង និងពង្រីកសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានា ដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ហើយធ្វើប្រតិបត្តិការដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ និងនីតិរដ្ឋដើម្បីចូលរួមក្នុងដំណើរការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ការលើកកម្ពស់លទ្ធិប្រជាធិតេយ្យ និងការគោរពសិទ្ធិមនុស្ស ព្រមទាំងចូលរួមតាមដានការអនុវត្តន៍គោលនយោបាយផងដែរ។ |
| ១១. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍ គោលនយោបាយរបស់រាជរដ្ឋាភិបាល លើការអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងកំរិតណា?<br>១. ០-២០%　　២. ២១%-៤០%　　៣. ៤១%-៦០%　　៤. ៦១%-៨០%　　៥. ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តអភិវឌ្ឍន៍វិស័យកសិកម្មឲ្យក្លាយជាផ្នែកនាំមុខមួយ ដែលមានប្រៀបខ្លាំងពិតប្រាកដ ដើម្បីធ្វើជាមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ធានាសន្តិសុខស្បៀង បង្កើនការងារ និងប្រាក់ចំណូលសម្រាប់ប្រជាជន ពិសេសប្រជាជននៅជនបទ ហើយរួមចំណែកដល់ការការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព។ |
| ១២. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល លើកំណែទម្រង់ដីធ្លី និងការដោះស្រាយបញ្ហាដីធ្លី ក្នុងកំរិតណា?<br>១. ០-២០%　　២. ២១%-៤០%　　៣. ៤១%-៦០%　　៤. ៦១%-៨០%　　៥.៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តអនុវត្តការកែទម្រង់ដីធ្លី ដែលផ្តោតលើការងាររដ្ឋបាលដីធ្លី ការរៀបចំដែនដី និងនគរូបនីយកម្ម ការបែងចែកដីធ្លី និងការអភិវឌ្ឍន៍វិស័យសំណង់ ដើម្បីការពារសិទ្ធិលើដីធ្លីរបស់ប្រជាជន ព្រមទាំងការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ និងដីរដ្ឋប្រកបដោយតម្លាភាព សមធម៌ ចីរភាព និងប្រសិទ្ធភាព។ |
| ១៣. | តើអ្នកពេញចិត្ត ការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលលើការគ្រប់គ្រង និងការអភិវឌ្ឍន៍ |

| | |
|---|---|
| | វិស័យសំណង់ ក្នុងកំរិតណា?<br>១. ០-២០% ២. ២១%-៤០% ៣. ៤១%-៦០% ៤. ៦១%-៨០% ៥ ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>ជម្រុញវិនិយោគក្នុងវិស័យសំណង់ ការកសាងច្បាប់ ការកំណត់ស្តង់ដារសំណង់ និងពន្លឿនរយៈពេលចេញលិខិតអនុញ្ញាតសាងសង់ជូនប្រជាជន។ |
| ១៤. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្ម កម្មន្តសាល(ដោយម៉ាស៊ីន) និងសិប្បកម្ម ក្នុងកំរិតណា?<br>១. ០-២០% ២. ២១%-៤០% ៣. ៤១%-៦០% ៤. ៦១%-៨០% ៥. ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្មន្តសាល សិប្បកម្មប្រកបដោយចីរភាព ដែលមានលក្ខណៈចម្រុះ សម្បូរបែប មានការទទួលខុសត្រូវខាងបរិស្ថាន និងសង្គមខ្ពស់ ហើយពង្រីកបាននូវអន្តរកម្មសេដ្ឋកិច្ច រវាងផ្នែកកែច្នៃកម្មន្តសាលជាមួយវិស័យកសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ដើម្បីជម្រុញសមាហរណកម្មសេដ្ឋកិច្ច ខ្សែសង្វាក់តម្លៃ និងភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក។ |
| ១៥. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលរបស់នយោបាយរដ្ឋាភិបាលលើការអភិវឌ្ឍន៍ធនធានរ៉ែ ប្រេងកាត និងឧស្ម័ន ក្នុងកំរិតណា?<br>១. ០-២០% ២. ២១%-៤០% ៣. ៤១%-៦០% ៤. ៦១%-៨០% ៥. ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>លើកទឹកចិត្តឲ្យវិស័យឯកជនវិនិយោគលើការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មធនធានទាំងនោះ តាមច្បាប់ជាធរមាន ដោយយកចិត្តទុកដាក់សំខាន់លើសុវត្ថិភាព សុខមាលភាព ព្រមទាំងការការពារបរិស្ថាន និងសង្គម បន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានាដែលទាក់ទងនឹងធនធានរ៉ែ ប្រេងកាត និងឧស្ម័ន ដើម្បីធានាការអភិវឌ្ឍន៍ធនធាននេះប្រកបដោយប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។ |
| ១៦. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយបង្កើនការស្តារ ការសាងសង់ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងផ្លូវអាកាស ក្នុងកំរិតណា?<br>១. ០-២០% ២. ២១%-៤០% ៣. ៤១%-៦០% ៤. ៦១%-៨០% ៥.៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តបង្កើនការស្តារ ការសាងសង់ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ប្រកបដោយគុណភាពសម្រាប់បម្រើឲ្យការដឹកជញ្ជូនពហុរូបភាព ដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស តភ្ជាប់ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោកដើម្បីធានាការធ្វើដំណើរគ្រប់ច្រកល្ហក និងការផ្តល់សេវាដឹកជញ្ជូនបានគ្រប់គ្រាន់គ្រប់រដូវកាលប្រកបដោយជាសុខភាព សណ្តាប់ធ្នាប់ ប្រសិទ្ធភាព និងមានតម្លៃទាប។ |
| ១៧. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តគោលនយោបាយលើកកម្ពស់ការគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ធនធានទឹក និងការរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី ក្នុងកំរិតណា?<br>១. ០-២០% ២. ២១%-៤០% ៣. ៤១%-៦០% ៤. ៦១%-៨០% ៥. ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តលើកកម្ពស់ការគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព មាននិរន្តរភាព និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី ដើម្បីផ្តល់លទ្ធភាពដល់ជនគ្រប់រូបក្នុងការប្រើប្រាស់ទឹកដែលមានអនាម័យ សុវត្ថិភាព និងតម្លៃសមស្របសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃបានគ្រប់គ្រាន់។ ធានាការគ្រប់គ្រង និងបែងចែកទឹកឲ្យមានសមភាពសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម ឧស្សាហកម្ម សេវា និងសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត។ |
| ១៨. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តគោលនយោបាយ ផ្គត់ផ្គង់ទឹកស្អាត ដោយបណ្តាញរដ្ឋ និងឯកជនរបស់រដ្ឋាភិ |

| | |
|---|---|
| | បាលកម្ពុជា ក្នុងកំរិតណា?<br>១. 0-២0%  ២. ២១%-៤0%  ៣. ៤១%-៦0%  ៤. ៦១%-៨0%  ៥. ៨១%-១00% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>ជម្រុញការអភិវឌ្ឍន៍ និងវិចារណកម្មការគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត សម្រាប់ប្រើប្រាស់ក្នុងជីវភាពរបស់ប្រជាជន និងផលិតកម្ម សេវាប្រកបដោយគុណភាព ប្រសិទ្ធភាព និងថ្លៃសមរម្យដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាព ជាពិសេសកាត់បន្ថយកង្វះទឹកស្អាតប្រើប្រាស់សម្រាប់ប្រជាជន ដែលរស់នៅក្នុងតំបន់ទីប្រជុំជនជាយក្រុង និងជនបទ។ |
| ១៩. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលលើការអភិវឌ្ឍន៍ វិស័យថាមពលដើម្បីធានាការផ្គត់ផ្គង់ថាមពលដែលមានស្ថិរភាព ការជឿទុកចិត្ត និងថ្លៃសមរម្យ ក្នុងកំរិតណា?<br>១. 0-២0%  ២. ២១%-៤0%  ៣. ៤១%-៦0%  ៤. ៦១%-៨0%  ៥. ៨១%-១00% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>ន្តអភិវឌ្ឍវិស័យថាមពល ដើម្បីធានាការផ្គត់ផ្គង់ថាមពលដែលមានស្ថិរភាព ការជឿទុកចិត្ត និងថ្លៃសមរម្យសម្រាប់បម្រើជីវភាពរស់នៅរបស់ប្រជាជន។ |
| ២0. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលើការអភិវឌ្ឍន៍ប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ក្នុងកំរិតណា?<br>១. 0-២0%  ២. ២១%-៤0%  ៣. ៤១%-៦0%  ៤. ៦១%-៨0%  ៥.៨១%-១00% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តអភិវឌ្ឍន៍ប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ឲ្យមានលក្ខណៈទំនើប មានគុណភាពខ្ពស់ស្របស្តង់ដារអន្តរជាតិ មានថ្លៃសមរម្យ និងមានសេវាគ្របដណ្តប់នៅទូទាំងប្រទេស ដែលប្រជាជនទូទៅអាចប្រើប្រាស់ និងទទួលបានផលប្រយោជន៍គ្រប់ៗគ្នាពីសេវាកម្មនេះ។ |
| ២១. | តើអ្នកពេញចិត្តកំរិតណា ចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយ បន្តកសាងផ្លូវជនបទ ការជំរុញវិស័យឥណទាន ការអភិវឌ្ឍន៍សិប្បកម្ម សហគ្រាស និងមុខជំនាញគ្រួសារខ្នាតតូច និងមធ្យម ព្រមទាំងពង្រីកទីផ្សារសម្រាប់ផលិតផលជនបទ?<br>១. 0-២0%  ២. ២១%-៤0%  ៣. ៤១%-៦0%  ៤. ៦១%-៨0%  ៥. ៨១%-១00% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តខិតខំធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជនបទ តាមរយៈការបន្តកសាងផ្លូវជនបទ ការរៀបចំឲ្យមានដំណើរការនៃប្រព័ន្ធគ្រប់គ្រង និងថែទាំផ្លូវជនបទ ដោយមានការចូលរួមរបស់សហគមន៍មូលដ្ឋានជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ជាពិសេសការកែលម្អផ្លូវជនបទជាជំហានៗពីផ្លូវក្រាលក្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង។ |
| ២២. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍ វិស័យពាណិជ្ជកម្ម តាមរយៈការធ្វើការធ្វើឲ្យសំបូរបែបទីផ្សារនាំចេញ និងការបង្កើនល្បឿនសមាហរណកម្មទីផ្សារសេរីសំខាន់ៗ ក្នុងកំរិតណា?<br>១. 0-២0%  ២. ២១%-៤0%  ៣. ៤១%-៦0%  ៤. ៦១%-៨0%  ៥. ៨១%-១00% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តជំរុញការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម តាមរយៈការធ្វើពិពិធកម្មទីផ្សារនាំចេញ និងការបង្កើនល្បឿនសមាហរណកម្ម ទៅក្នុងក្របខណ្ឌពាណិជ្ជកម្មសេរីសំខាន់ៗក្នុងតំបន់ និងពិភពលោក ជាពិសេសបណ្តាប្រទេសក្នុងសមាគមអាស៊ាន ស្របតាមទិសដៅធ្វើឲ្យសម្រេចសហគមន៍អាស៊ានឆ្នាំ២០១៥ និងបណ្តាប្រទេសជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ |
| ២៣. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល លើការទាក់ទាញការវិនិយោគផ្ទាល់ |

| | |
|---|---|
| | ពីបរទេស និងជំរុញការវិនិយោគក្នុងស្រុក ក្នុងកំរិតណា?<br>១. ០-២០%    ២. ២១%-៤០%    ៣. ៤១%-៦០%    ៤. ៦១%-៨០%    ៥. ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងជំរុញការវិនិយោគក្នុងស្រុក ជាពិសេសតាមរយៈការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម និងការជំរុញសហគ្រិនភាព ដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍន៍ ធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើតការងារ។ |
| ២៤. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល លើការអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិក្នុងកំរិតណា?<br>១. ០-២០%    ២. ២១%-៤០%    ៣. ៤១%-៦០%    ៤. ៦១%-៨០%    ៥. ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាជាទេសចរណ៍វប្បធម៌ និងធម្មជាតិប្រកបដោយគុណភាព និងចីរភាពដោយប្រកាន់ខ្ជាប់នូវទស្សនៈ «ការអភិវឌ្ឍន៍បម្រើឲ្យការអភិរក្ស និងការអភិរក្សបម្រើការអភិវឌ្ឍន៍» ដើម្បីចូលរួមទ្រទ្រង់កំណើនសេដ្ឋកិច្ច លើកស្ទួយជីវភាពរបស់ប្រជាជន និងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតងជានិន្នាការរួមនៃភិភពលោក។ |
| ២៥. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយ ការថែរក្សា ការពារជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីការប្រើប្រាស់ធនធានធម្មជាតិ ក្នុងកំរិតណា?<br>១. ០-២០%    ២. ២១%-៤០%    ៣. ៤១%-៦០%    ៤. ៦១%-៨០%    ៥.៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តការថែរក្សា ការពារជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ទាំងនៅដែនគោក ទាំងនៅដែនសមុទ្រដើម្បីជាប្រយោជន៍ដល់ប្រជាជនទូទៅ ទាំងពេលបច្ចុប្បន្ន ទាំងពេលអនាគត និងដើម្បីឆ្លើយតបចំពោះការអភិវឌ្ឍន៍ឧស្សាហកម្មដែលបញ្ចេញធាតុពុលកាន់តែច្រើន និងការប្រែប្រួលអាកាសធាតុជាសកលនៅពេលបច្ចុប្បន្ន ព្រមទាំងដើម្បីធានាដល់ការលូតលាស់នៃសង្គម សេដ្ឋកិច្ច និងការលើកកម្ពស់សុខុមាលភាពសាធារណៈ។ |
| **វិស័យ៖ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច** | |
| ២៦. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សលើគ្រប់ផ្នែក រួមទាំងខាងវិទ្យាសាស្ត្រ បច្ចេកទេស និងចំណេះធ្វើក្នុងកំរិតណា?<br>១. ០-២០%    ២. ២១%-៤០%    ៣. ៤១%-៦០%    ៤. ៦១%-៨០%    ៥.៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តកសាង និងអភិវឌ្ឍន៍ធនធានមនុស្សលើគ្រប់ផ្នែកប្រកបដោយគុណភាព និងមានគុណធម៌ល្អប្រពៃ ដែលឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច ដើម្បីកសាងកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើនជឿនលឿន ដែលផ្អែកលើមូលដ្ឋានចំណេះដឹងលើគ្រប់វិស័យ រួមទាំងខាងវិទ្យាសាស្ត្របច្ចេកទេស និងចំណេះធ្វើ ហើយដើរស្របជាមួយនឹងការរីកចម្រើននៃបណ្តាប្រទេសនៅក្នុងតំបន់ និងពិភពលោក។ |
| ២៧. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍វិស័យកីឡា រួមទាំងកីឡាជនពិការ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងកំរិតណា?<br>១. ០-២០%    ២. ២១%-៤០%    ៣. ៤១%-៦០%    ៤. ៦១%-៨០%    ៥.៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>ពង្រឹងការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យអប់រំកាយ និងកីឡាឲ្យមានប្រសិទ្ធភាពខ្ពស់ សំដៅរួមចំណែកដល់ការលើកកម្ពស់សុខភាពប្រជាជន ពង្រឹងសាមគ្គីភាព និងត្រៀមលក្ខណៈសម្បត្តិឲ្យបានល្អដើម្បី |

| | |
|---|---|
| | ចូលរួម និងទទួលរៀបចំព្រឹត្តិការណ៍កីឡាធំៗជាលក្ខណៈអន្តរជាតិនានានៅពេលខាងមុខដូចជា អាស៊ានហ្គេម ជាដើម។ |
| ២៨. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍វិស័យសុខាភិបាល ដោយយកចិត្តទុកដាក់ពិសេសប្រជាជនក្រីក្រងាយរងគ្រោះ និងប្រជាជនរស់នៅជនបទក្នុងកំរិតណា?<br>**១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>ផ្តល់សេវាសុខាភិបាលប្រកបដោយប្រសិទ្ធភាព គុណភាព សមធម៌ និងមានចីរភាពដល់ប្រជាជនទូទៅ ពិសេសប្រជាជនក្រីក្រងាយរងគ្រោះ និងប្រជាជនរស់នៅជនបទ។ |
| ២៩. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការកសាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឲ្យមាននៅគ្រប់ខេត្តក្នុងកំរិតណា?<br>**១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>តម្រង់ទិសលើការធ្វើឲ្យប្រជាជនមានការងារធ្វើ មានមុខរបរសមរម្យ ត្រឹមត្រូវ និងថ្លៃថ្នូរ ការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់និយោជក និងកម្មករ និយោជិតព្រមទាំងការកសាង និងលើកកម្ពស់សមត្ថភាពបច្ចេកទេស និងវិជ្ជាជីវៈឲ្យរីកចម្រើនស្របតាមបទដ្ឋានអន្តរជាតិ។ |
| ៣០. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយលើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ធម្មជាតិ សេរីភាពខាងជំនឿ និងសាសនាក្នុងកំរិតណា?<br>**១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>ថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ ទាំងរូបិយ និងឲ្យស្ថិតស្ថេរគង់វង្សយូរអង្វែង បង្កើតផលិតផលវប្បធម៌ឲ្យបានកាន់តែច្រើន ហើយចូលរួមសកម្មភាពក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកែលម្អជីវភាពប្រជាជន ស្របតាមអត្ថន័យ វប្បធម៌ជាសេដ្ឋកិច្ច។ |
| ៣១. | តើអ្នកពេញចិត្តក្នុងកំរិតណា ចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា ដោយយកចិត្តទុកដាក់ចំពោះជនពិការ មនុស្សចាស់ អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល?<br>**១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>ធ្វើឲ្យមានសុខុមាលភាពប្រជាជនមានស្ថានភាពកាន់តែប្រសើរឡើង ដោយមានសេវាសង្គមកិច្ចគ្រប់គ្រាន់សម្រាប់ជួយជនរងគ្រោះ និងជនងាយរងគ្រោះគ្រប់ប្រភេទ មានប្រព័ន្ធសន្តិសុខសង្គមរឹងមាំ និងទូលំទូលាយសម្រាប់ធានារ៉ាប់រងចំពោះហានិភ័យសង្គម។ |
| ៣២. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ និងគោលនយោបាយឲ្យកុមារទទួលបានពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានក្នុងកំរិតណា?<br>**១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តលើកកម្ពស់សមធម៌យេនឌ័រ ជំរុញភាពអង់អាចរបស់ស្ត្រីក្នុងសេដ្ឋកិច្ច ដោយជំរុញការបណ្តុះបណ្តាលបំពាក់បំប៉នជំនាញបច្ចេកទេស និងផ្តល់កាលានុភាពដល់ស្ត្រីក្នុងពង្រឹងមុខរបរ បង្កើនចំណូល និងកសាងសហគ្រិនភាព បង្កើនឱកាសរៀនសូត្រសម្រាប់ស្ត្រី និងក្មេងស្រី ពិសេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តម |

| | |
|---|---|
| | សិក្សា។<br>ជំរុញការផ្សព្វផ្សាយ និងអនុវត្តយ៉ាងហ្មត់ចត់នូវអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធកុមារ ពិសេសធានាឲ្យកុមារបានទទួលពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺ«សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍន៍ សិទ្ធិបានការការពារ និងសិទ្ធិចូលរួមរបស់កុមារ។ |
| ៣៣. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍យុវជន ខាងចំណេះដឹង ចំណេះធ្វើ សុខភាពកាយសម្បទាន និងមានសីលធម៌រស់នៅថ្លៃថ្នូរក្នុងកំរិតណា?<br>**១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០% |
| | **<u>គោលនយោបាយសង្ខេបរួម៖</u>**<br>បន្តការលើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ បង្កើនការអប់រំ ការថែទាំ និងផ្តល់សេវាសុខភាព បន្តការពារសន្តិសុខ សុវត្ថិភាព និងយុត្តិធម៌សម្រាប់យុវជន ពង្រឹងចលនាស្ម័គ្រចិត្តរបស់យុវជនចូលរួមក្នុងសកម្មភាពកសាងយុត្តិធម៌ក្នុងសង្គម និងចលនាកាយរិទ្ធនៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ និងចលនាយុវជនកាកបាទក្រហម។ |
| **ការផ្តល់ពិន្ទុជារួមលើការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា សម្រាប់ឆ្នាំទី2** | |
| ៣៤. | តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ក្នុងកំរិតណា?<br>**១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០% |

- **តារាងលទ្ធផលនៃការផ្តល់ពិន្ទុតាមខេត្ត/រាជធានី**

## ក. វិស័យទី១៖ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

| ល.រ | រាជធានី/ខេត្ត | ការផ្តល់ពិន្ទុលើកទី១ (គិតជា%) | | | | | ការផ្តល់ពិន្ទុលើកទី២ (គិតជា%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង |
| 1 | បន្ទាយមានជ័យ | 0.00 | 11.80 | 41.20 | 35.30 | 11.80 | 0.00 | 14.70 | 41.20 | 41.20 | 2.90 |
| 2 | បាត់ដំបង | 12.90 | 22.60 | 58.10 | 6.50 | 0.00 | 2.10 | 29.80 | 44.70 | 23.40 | 0.00 |
| 3 | កំពង់ចាម | 28.60 | 42.90 | 14.30 | 10.70 | 3.60 | 24.00 | 48.00 | 20.00 | 8.00 | 0.00 |
| 4 | កំពង់ឆ្នាំង | 23.80 | 28.60 | 14.30 | 28.60 | 4.80 | 9.10 | 31.80 | 18.20 | 18.20 | 22.70 |
| 5 | កំពង់ស្ពឺ | 6.70 | 23.30 | 33.30 | 30.00 | 6.70 | 13.30 | 26.70 | 43.30 | 16.70 | 0.00 |
| 6 | កំពង់ធំ | 0.00 | 20.00 | 48.00 | 16.00 | 16.00 | 0.00 | 28.00 | 56.00 | 8.00 | 8.00 |
| 7 | កំពត | 0.00 | 46.70 | 43.30 | 10.00 | 0.00 | 3.30 | 46.70 | 40.00 | 10.00 | 0.00 |
| 8 | កណ្តាល | 0.00 | 4.20 | 25.00 | 37.50 | 33.30 | 4.20 | 29.20 | 50.00 | 16.70 | 0.00 |
| 9 | ក្រចេះ | 8.00 | 40.00 | 20.00 | 8.00 | 24.00 | 13.00 | 39.10 | 4.30 | 21.70 | 21.70 |
| 10 | មណ្ឌលគិរី | 2.90 | 11.40 | 22.90 | 60.00 | 2.90 | 6.70 | 6.70 | 23.30 | 56.70 | 6.70 |
| 11 | ភ្នំពេញ | 45.45 | 28.75 | 16.35 | 6.20 | 3.25 | 64.60 | 21.10 | 11.10 | 2.65 | 0.55 |
| 12 | ព្រះវិហារ | 31.80 | 31.80 | 27.30 | 4.50 | 4.50 | 50.00 | 31.80 | 9.10 | 4.50 | 4.50 |
| 13 | ព្រៃវែង | 0.00 | 12.50 | 16.70 | 50.00 | 20.80 | 4.20 | 12.50 | 25.00 | 25.00 | 33.30 |
| 14 | ពោធិ៍សាត់ | 8.30 | 37.50 | 33.30 | 16.70 | 4.20 | 33.30 | 25.00 | 29.20 | 12.50 | 0.00 |
| 15 | រតនគិរី | 13.30 | 40.00 | 20.00 | 13.30 | 13.30 | 9.70 | 48.40 | 25.80 | 6.50 | 9.70 |
| 16 | សៀមរាប | 8.70 | 21.70 | 21.70 | 26.10 | 21.70 | 7.70 | 15.40 | 34.60 | 30.80 | 11.50 |
| 17 | កំពង់សោម | 19.20 | 46.20 | 26.90 | 7.70 | 0.00 | 29.60 | 40.70 | 25.90 | 3.70 | 0.00 |
| 18 | ស្ទឹងត្រែង | 0.00 | 20.50 | 53.80 | 25.60 | 0.00 | 3.30 | 13.30 | 56.70 | 16.70 | 10.00 |
| 19 | ស្វាយរៀង | 0.00 | 30.80 | 38.50 | 26.90 | 3.80 | 13.80 | 20.70 | 41.40 | 24.10 | 0.00 |
| 20 | តាកែវ | 3.80 | 46.20 | 30.80 | 15.40 | 3.80 | 3.80 | 42.30 | 46.20 | 7.70 | 0.00 |
| 21 | កែប | 6.70 | 30.00 | 46.70 | 13.30 | 3.30 | 6.50 | 41.90 | 48.40 | 3.20 | 0.00 |
| 22 | ប៉ៃលិន | 5.40 | 18.90 | 8.10 | 24.30 | 43.20 | 9.10 | 12.10 | 6.10 | 24.20 | 48.50 |
| 23 | ឧត្តរមានជ័យ | 0.00 | 4.00 | 36.00 | 36.00 | 24.00 | 0.00 | 16.70 | 37.50 | 25.00 | 20.80 |
| 24 | ត្បូងឃ្មុំ | 58.10 | 35.50 | 3.20 | 0.00 | 3.20 | 43.80 | 40.60 | 12.50 | 3.10 | 0.00 |

## ខ. វិស័យទី២៖ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ

| ល.រ | រាជធានី/ខេត្ត | ការផ្តល់ពិន្ទុលើកទី១ (គិតជា%) | | | | | ការផ្តល់ពិន្ទុលើកទី២ (គិតជា%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង |
| 1 | បន្ទាយមានជ័យ | 0.00 | 20.60 | 35.30 | 32.40 | 11.80 | 2.90 | 8.80 | 52.90 | 29.40 | 5.90 |
| 2 | បាត់ដំបង | 6.50 | 16.10 | 54.80 | 19.40 | 3.20 | 6.40 | 17.00 | 40.40 | 36.20 | 0.00 |
| 3 | កំពង់ចាម | 25.00 | 53.60 | 10.70 | 7.10 | 3.60 | 32.00 | 40.00 | 20.00 | 4.00 | 4.00 |
| 4 | កំពង់ឆ្នាំង | 4.80 | 52.40 | 19.00 | 23.80 | 0.00 | 9.10 | 31.80 | 31.80 | 27.30 | 0.00 |
| 5 | កំពង់ស្ពឺ | 0.00 | 46.70 | 20.00 | 30.00 | 3.30 | 23.30 | 46.70 | 13.30 | 16.70 | 0.00 |
| 6 | កំពង់ធំ | 0.00 | 20.00 | 36.00 | 36.00 | 8.00 | 0.00 | 24.00 | 68.00 | 4.00 | 4.00 |
| 7 | កំពត | 10.00 | 50.00 | 30.00 | 10.00 | 0.00 | 10.00 | 26.70 | 56.70 | 6.70 | 0.00 |
| 8 | កណ្តាល | 0.00 | 8.30 | 45.80 | 37.50 | 8.30 | 0.00 | 41.70 | 45.80 | 12.50 | 0.00 |
| 9 | ក្រចេះ | 12.00 | 28.00 | 24.00 | 20.00 | 16.00 | 17.40 | 26.10 | 21.70 | 21.70 | 13.00 |
| 10 | មណ្ឌលគិរី | 5.70 | 8.60 | 25.70 | 57.10 | 2.90 | 6.70 | 13.30 | 16.70 | 56.70 | 6.70 |
| 11 | ភ្នំពេញ | 53.20 | 23.03 | 16.00 | 4.38 | 3.38 | 62.50 | 22.80 | 7.88 | 2.90 | 3.95 |
| 12 | ព្រះវិហារ | 31.80 | 54.50 | 4.50 | 4.50 | 4.50 | 40.90 | 45.50 | 4.50 | 4.50 | 4.50 |
| 13 | ព្រៃវែង | 4.20 | 12.50 | 29.20 | 29.20 | 25.00 | 0.00 | 16.70 | 25.00 | 37.50 | 20.80 |
| 14 | ពោធិ៍សាត់ | 12.50 | 41.70 | 29.20 | 12.50 | 4.20 | 25.00 | 29.20 | 25.00 | 20.80 | 0.00 |
| 15 | រតនគិរី | 10.00 | 43.30 | 26.70 | 6.70 | 13.30 | 12.90 | 48.40 | 16.10 | 16.10 | 6.50 |
| 16 | សៀមរាប | 4.30 | 26.10 | 30.40 | 30.40 | 8.70 | 0.00 | 30.80 | 38.50 | 26.90 | 3.80 |
| 17 | កំពង់សោម | 23.10 | 26.90 | 34.60 | 15.40 | 0.00 | 25.90 | 44.40 | 25.90 | 3.70 | 0.00 |
| 18 | ស្ទឹងត្រែង | 5.10 | 25.60 | 48.70 | 10.30 | 10.30 | 0.00 | 16.70 | 53.30 | 26.70 | 3.30 |
| 19 | ស្វាយរៀង | 0.00 | 30.80 | 42.30 | 26.90 | 0.00 | 6.90 | 37.90 | 44.80 | 10.30 | 0.00 |
| 20 | តាកែវ | 3.80 | 38.50 | 46.20 | 7.70 | 3.80 | 3.80 | 61.50 | 30.80 | 3.80 | 0.00 |
| 21 | កែប | 13.30 | 56.70 | 20.00 | 10.00 | 0.00 | 6.50 | 48.40 | 35.50 | 9.70 | 0.00 |
| 22 | ប៉ៃលិន | 5.40 | 18.90 | 8.10 | 27.00 | 40.50 | 0.00 | 18.20 | 9.10 | 39.40 | 33.30 |
| 23 | ឧត្តរមានជ័យ | 0.00 | 4.00 | 36.00 | 56.00 | 4.00 | 0.00 | 20.80 | 33.30 | 33.30 | 12.50 |
| 24 | ត្បូងឃ្មុំ | 61.30 | 38.70 | 0.00 | 0.00 | 0.00 | 53.10 | 40.60 | 6.30 | 0.00 | 0.00 |

## គ. វិស័យទី៣៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ច

| ល.រ | រាជធានី/ខេត្ត | ការផ្តល់ពិន្ទុលើកទី១ (គិតជា%) | | | | | ការផ្តល់ពិន្ទុលើកទី២ (គិតជា%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង |
| 1 | បន្ទាយមានជ័យ | 0.00 | 8.80 | 52.90 | 38.20 | 0.00 | 0.00 | 8.80 | 64.70 | 26.50 | 0.00 |
| 2 | បាត់ដំបង | 6.50 | 19.40 | 58.10 | 16.10 | 0.00 | 6.40 | 17.00 | 53.20 | 23.40 | 0.00 |
| 3 | កំពង់ចាម | 28.60 | 46.40 | 17.90 | 7.10 | 0.00 | 16.00 | 60.00 | 20.00 | 4.00 | 0.00 |
| 4 | កំពង់ឆ្នាំង | 9.50 | 47.60 | 23.80 | 19.00 | 0.00 | 4.50 | 31.80 | 36.40 | 27.30 | 0.00 |
| 5 | កំពង់ស្ពឺ | 10.00 | 33.30 | 36.70 | 16.70 | 3.30 | 23.30 | 63.30 | 13.30 | 0.00 | 0.00 |
| 6 | កំពង់ធំ | 0.00 | 8.00 | 68.00 | 16.00 | 8.00 | 0.00 | 40.00 | 44.00 | 8.00 | 8.00 |
| 7 | កំពត | 6.70 | 43.30 | 40.00 | 10.00 | 0.00 | 10.00 | 20.00 | 60.00 | 10.00 | 0.00 |
| 8 | កណ្តាល | 0.00 | 0.00 | 41.70 | 58.30 | 0.00 | 4.20 | 54.20 | 41.70 | 0.00 | 0.00 |
| 9 | ក្រចេះ | 8.30 | 33.30 | 20.80 | 16.70 | 20.80 | 4.30 | 43.50 | 13.00 | 21.70 | 17.40 |
| 10 | មណ្ឌលគិរី | 5.70 | 2.90 | 48.60 | 40.00 | 2.90 | 6.70 | 6.70 | 46.70 | 40.00 | 0.00 |
| 11 | ភ្នំពេញ | 40.74 | 31.46 | 16.11 | 6.82 | 4.87 | 49.08 | 29.45 | 12.24 | 3.79 | 5.42 |
| 12 | ព្រះវិហារ | 13.60 | 59.10 | 22.70 | 0.00 | 4.50 | 45.50 | 45.50 | 4.50 | 0.00 | 4.50 |
| 13 | ព្រៃវែង | 0.00 | 8.30 | 37.50 | 37.50 | 16.70 | 0.00 | 16.70 | 16.70 | 41.70 | 25.00 |
| 14 | ពោធិ៍សាត់ | 12.50 | 37.50 | 41.70 | 8.30 | 0.00 | 21.70 | 26.10 | 34.80 | 17.40 | 0.00 |
| 15 | រតនគិរី | 13.30 | 40.00 | 26.70 | 13.30 | 6.70 | 6.50 | 51.60 | 25.80 | 12.90 | 3.20 |
| 16 | សៀមរាប | 0.00 | 34.80 | 34.80 | 30.40 | 0.00 | 0.00 | 30.80 | 34.60 | 34.60 | 0.00 |
| 17 | កំពង់សោម | 15.40 | 30.80 | 46.20 | 3.80 | 3.80 | 18.50 | 51.90 | 25.90 | 3.70 | 0.00 |
| 18 | ស្ទឹងត្រែង | 0.00 | 23.10 | 53.80 | 23.10 | 0.00 | 0.00 | 10.00 | 63.30 | 26.70 | 0.00 |
| 19 | ស្វាយរៀង | 0.00 | 46.20 | 38.50 | 15.40 | 0.00 | 3.40 | 37.90 | 48.30 | 10.30 | 0.00 |
| 20 | តាកែវ | 3.80 | 46.20 | 34.60 | 15.40 | 0.00 | 0.00 | 73.10 | 15.40 | 11.50 | 0.00 |
| 21 | កែប | 0.00 | 36.70 | 56.70 | 6.70 | 0.00 | 0.00 | 51.60 | 41.90 | 6.50 | 0.00 |
| 22 | ប៉ៃលិន | 2.70 | 18.90 | 13.50 | 18.90 | 45.90 | 0.00 | 15.20 | 12.10 | 30.30 | 42.40 |
| 23 | ឧត្តរមានជ័យ | 0.00 | 0.00 | 60.00 | 36.00 | 4.00 | 0.00 | 0.00 | 62.50 | 37.50 | 0.00 |
| 24 | ត្បូងឃ្មុំ | 64.50 | 29.00 | 6.50 | 0.00 | 0.00 | 59.40 | 40.60 | 0.00 | 0.00 | 0.00 |

# ឃ. វិស័យទី4៖ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច

| ល.រ | រាជធានី/ខេត្ត | ការផ្តល់ពិន្ទុលើកទី១ (គិតជា%) | | | | | ការផ្តល់ពិន្ទុលើកទី២ (គិតជា%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង |
| 1 | បន្ទាយមានជ័យ | 0.00 | 5.90 | 50.00 | 35.30 | 8.80 | 0.00 | 8.80 | 50.00 | 29.40 | 11.80 |
| 2 | បាត់ដំបង | 6.50 | 19.40 | 45.20 | 22.60 | 6.50 | 4.30 | 6.40 | 55.30 | 25.50 | 8.50 |
| 3 | កំពង់ចាម | 28.60 | 42.90 | 17.90 | 10.70 | 0.00 | 12.00 | 64.00 | 20.00 | 0.00 | 4.00 |
| 4 | កំពង់ឆ្នាំង | 9.50 | 28.60 | 28.60 | 28.60 | 4.80 | 9.50 | 28.60 | 28.60 | 33.30 | 0.00 |
| 5 | កំពង់ស្ពឺ | 13.30 | 40.00 | 23.30 | 20.00 | 3.30 | 16.70 | 56.70 | 23.30 | 3.30 | 0.00 |
| 6 | កំពង់ធំ | 0.00 | 12.00 | 56.00 | 24.00 | 8.00 | 0.00 | 24.00 | 60.00 | 16.00 | 0.00 |
| 7 | កំពត | 6.70 | 50.00 | 40.00 | 3.30 | 0.00 | 13.80 | 37.90 | 44.80 | 3.40 | 0.00 |
| 8 | កណ្តាល | 0.00 | 0.00 | 41.70 | 58.30 | 0.00 | 0.00 | 33.30 | 50.00 | 16.70 | 0.00 |
| 9 | ក្រចេះ | 4.20 | 25.00 | 33.30 | 16.70 | 20.80 | 4.30 | 34.80 | 21.70 | 21.70 | 17.40 |
| 10 | មណ្ឌលគិរី | 2.90 | 5.70 | 25.70 | 57.10 | 8.60 | 3.30 | 3.30 | 50.00 | 40.00 | 3.30 |
| 11 | ភ្នំពេញ | 42.28 | 29.70 | 16.35 | 6.09 | 5.59 | 47.40 | 29.65 | 12.61 | 3.38 | 7.03 |
| 12 | ព្រះវិហារ | 9.50 | 76.20 | 9.50 | 0.00 | 4.80 | 31.60 | 63.20 | 0.00 | 0.00 | 5.30 |
| 13 | ព្រៃវែង | 0.00 | 8.30 | 20.80 | 45.80 | 25.00 | 0.00 | 17.40 | 17.40 | 34.80 | 30.40 |
| 14 | ពោធិ៍សាត់ | 8.30 | 25.00 | 33.30 | 33.30 | 0.00 | 17.40 | 21.70 | 39.10 | 21.70 | 0.00 |
| 15 | រតនគិរី | 10.00 | 36.70 | 30.00 | 13.30 | 10.00 | 9.70 | 54.80 | 16.10 | 12.90 | 6.50 |
| 16 | សៀមរាប | 4.30 | 21.70 | 39.10 | 34.80 | 0.00 | 0.00 | 34.60 | 38.50 | 23.10 | 3.80 |
| 17 | កំពង់សោម | 11.50 | 30.80 | 34.60 | 15.40 | 7.70 | 20.00 | 44.00 | 32.00 | 4.00 | 0.00 |
| 18 | ស្ទឹងត្រែង | 0.00 | 17.90 | 53.80 | 28.20 | 0.00 | 0.00 | 13.30 | 63.30 | 23.30 | 0.00 |
| 19 | ស្វាយរៀង | 0.00 | 34.60 | 38.50 | 26.90 | 0.00 | 10.30 | 31.00 | 27.60 | 31.00 | 0.00 |
| 20 | តាកែវ | 0.00 | 30.80 | 50.00 | 11.50 | 7.70 | 7.70 | 50.00 | 34.60 | 7.70 | 0.00 |
| 21 | កែប | 0.00 | 40.00 | 56.70 | 3.30 | 0.00 | 0.00 | 48.40 | 38.70 | 12.90 | 0.00 |
| 22 | ប៉ៃលិន | 0.00 | 18.90 | 10.80 | 24.30 | 45.90 | 0.00 | 14.30 | 7.10 | 14.30 | 64.30 |
| 23 | ឧត្តរមានជ័យ | 0.00 | 8.00 | 40.00 | 36.00 | 16.00 | 0.00 | 4.20 | 66.70 | 20.80 | 8.30 |
| 24 | ត្បូងឃ្មុំ | 58.10 | 32.30 | 9.70 | 0.00 | 0.00 | 53.10 | 37.50 | 6.30 | 3.10 | 0.00 |

# ង. គោលនយោបាយទាំង៤វិស័យ៖

| ល.រ | រាជធានី/ខេត្ត | ការផ្តល់ពិន្ទុលើកទី១ (គិតជា%) | | | | | ការផ្តល់ពិន្ទុលើកទី២ (គិតជា%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | 2.ពេញចិត្តខ្លះ | 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 4.ពេញចិត្តច្រើន | 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង |
| 1 | បន្ទាយមានជ័យ | 0.00 | 11.78 | 44.85 | 35.30 | 8.10 | 0.73 | 10.28 | 52.20 | 31.63 | 5.15 |
| 2 | បាត់ដំបង | 8.10 | 19.38 | 54.05 | 16.15 | 2.43 | 4.80 | 17.55 | 48.40 | 27.13 | 2.13 |
| 3 | កំពង់ចាម | 27.70 | 46.45 | 15.20 | 8.90 | 1.80 | 21.00 | 53.00 | 20.00 | 4.00 | 2.00 |
| 4 | កំពង់ឆ្នាំង | 11.90 | 39.30 | 21.43 | 25.00 | 2.40 | 8.05 | 31.00 | 28.75 | 26.53 | 5.68 |
| 5 | កំពង់ស្ពឺ | 7.50 | 35.83 | 28.33 | 24.18 | 4.15 | 19.15 | 48.35 | 23.30 | 9.18 | 0.00 |
| 6 | កំពង់ធំ | 0.00 | 15.00 | 52.00 | 23.00 | 10.00 | 0.00 | 29.00 | 57.00 | 9.00 | 5.00 |
| 7 | កំពត | 5.85 | 47.50 | 38.33 | 8.33 | 0.00 | 9.28 | 32.83 | 50.38 | 7.53 | 0.00 |
| 8 | កណ្តាល | 0.00 | 3.13 | 38.55 | 47.90 | 10.40 | 2.10 | 39.60 | 46.88 | 11.48 | 0.00 |
| 9 | ក្រចេះ | 8.13 | 31.58 | 24.53 | 15.35 | 20.40 | 9.75 | 35.88 | 15.18 | 21.70 | 17.38 |
| 10 | មណ្ឌលគិរី | 4.30 | 7.15 | 30.73 | 53.55 | 4.33 | 5.85 | 7.50 | 34.18 | 48.35 | 4.18 |
| 11 | ភ្នំពេញ | 45.42 | 28.23 | 16.20 | 5.87 | 4.27 | 55.90 | 25.75 | 10.96 | 3.18 | 4.24 |
| 12 | ព្រះវិហារ | 21.68 | 55.40 | 16.00 | 2.25 | 4.58 | 42.00 | 46.50 | 4.53 | 2.25 | 4.70 |
| 13 | ព្រៃវែង | 1.05 | 10.40 | 26.05 | 40.63 | 21.88 | 1.05 | 15.83 | 21.03 | 34.75 | 27.38 |
| 14 | ពោធិ៍សាត់ | 10.40 | 35.43 | 34.38 | 17.70 | 2.10 | 24.35 | 25.50 | 32.03 | 18.10 | 0.00 |
| 15 | រតនគិរី | 11.65 | 40.00 | 25.85 | 11.65 | 10.83 | 9.70 | 50.80 | 20.95 | 12.10 | 6.48 |
| 16 | សៀមរាប | 4.33 | 26.08 | 31.50 | 30.43 | 7.60 | 1.93 | 27.90 | 36.55 | 28.85 | 4.78 |
| 17 | កំពង់សោម | 17.30 | 33.68 | 35.58 | 10.58 | 2.88 | 23.50 | 45.25 | 27.43 | 3.78 | 0.00 |
| 18 | ស្ទឹងត្រែង | 1.28 | 21.78 | 52.53 | 21.80 | 2.58 | 0.83 | 13.33 | 59.15 | 23.35 | 3.33 |
| 19 | ស្វាយរៀង | 0.00 | 35.60 | 39.45 | 24.03 | 0.95 | 8.60 | 31.88 | 40.53 | 18.93 | 0.00 |
| 20 | តាកែវ | 2.85 | 40.43 | 40.40 | 12.50 | 3.83 | 3.83 | 56.73 | 31.75 | 7.68 | 0.00 |
| 21 | កែប | 5.00 | 40.85 | 45.03 | 8.33 | 0.83 | 3.25 | 47.58 | 41.13 | 8.08 | 0.00 |
| 22 | ប៉ៃលិន | 3.38 | 18.90 | 10.13 | 23.63 | 43.88 | 2.28 | 14.95 | 8.60 | 27.05 | 47.13 |
| 23 | ឧត្តរមានជ័យ | 0.00 | 4.00 | 43.00 | 41.00 | 12.00 | 0.00 | 10.43 | 50.00 | 29.15 | 10.40 |
| 24 | ត្បូងឃ្មុំ | 60.50 | 33.88 | 4.85 | 0.00 | 0.80 | 52.35 | 39.83 | 6.28 | 1.55 | 0.00 |

- **តារាងព័ត៌មានទំនាក់ទំនងរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនីតិកាលទី៥**

| **ល.រ** | **ស្ថាប័ន** | **រដ្ឋមន្ត្រី និង ព័ត៌មានផ្ទាល់ខ្លួន** | **ទំនាក់ទំនង** | **អាសយដ្ឋាន** |
|---|---|---|---|---|
| ១ | ទីស្ដីការគណៈរដ្ឋមន្ត្រី | **ឯ. សុខ អាន**<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ/ទូរសារ៖(៨៥៥)២៣ ៨៨០ ៦២៨ | ទូរស័ព្ទ៖<br>+៨៥៥ - (0)១២ - ៨0៤ ៤៤២<br>+៨៥៥ - (0)២៣ - ៨៨0 ៦២៤<br>អ៊ីម៉ែល៖ ocm@cambodia.gov.kh | #41 មហាវិថី សហព័ន្ធរុស្ស៊ី រាជធានី ភ្នំពេញ<br>គេហទំព័រ៖ www.ocm.gov.kh |
| ២ | ក្រសួងមហាផ្ទៃ | **ឯ. ស ខេង**<br>កំរិតវប្បធម៌៖ សញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រនយោបាយ<br>ទូរស័ព្ទ៖(៨៥៥)១២ ៨៥៨ ៨៥៨ | ទូរស័ព្ទ / ទូរសារ៖ (៨៥៥)២៣ ៧២១៩០៥, (៨៥៥)២៣ ៧២៦០៥២/៧២១១៩០<br>E-Mail: moi@interior.gov.kh | Address: #275 Norodom Blvd., Phnom Penh<br>គេហទំព័រ៖ http://www.interior.gov.kh/ |
| ៣ | ក្រសួងការពារជាតិ | **ឯ. ទា បាញ់**<br>កំរិតវប្បធម៌៖ បណ្ឌិតកិត្តិយសវិទ្យាសាស្ត្រនយោបាយ<br>ទូរស័ព្ទ៖(៨៥៥)១២ ៨១០ ០៧៧ | ទូរស័ព្ទ / ទូរសារ៖ +៨៥៥(២៣) ៨៨៣ ២៧៤<br>អ៊ីម៉ែល: generalsec@mod.gov.kh | អាសយដ្ឋាន៖ វិថីសហព័ន្ធរុស្ស៊ី កែងផ្លូវ ១៧៥, ខណ្ឌ ៧មករា, រាជធានី ភ្នំពេញ<br>គេហទំព័រ៖ http://www.mod.gov.kh |

| | | | | |
|---|---|---|---|---|
| ៤ | ក្រសួងការបរទេស | **ឯ. ហោ ណាំហុង**<br>កំរិតវប្បធម៌៖ អនុបណ្ឌិតផ្នែកនីតិសាស្ត្រ<br>ទូរស័ព្ទ៖ (៨៥៥)១២ ៨០៩ ២៩១ | ទូរស័ព្ទ៖ ០២៣ ២១៤ ៤៤១ / ២១៦ ១២២<br>អ៊ីម៉ែល៖ mfaicasean@bigpond.com.kh | អគារលេខ០៣ វិថី សម្តេចហ៊ុនសែន រាជធានីភ្នំពេញ<br>គេហទំព័រ៖ www.mfaic.gov.kh |
| ៥ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | **ឯ. អូន ព័ន្ធមុន្នីរ័ត្ន**<br>កំរិតវប្បធម៌៖ បណ្ឌិតទស្សនៈវិជ្ជា<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖<br>+៨៥៥ ) -0(២៣ - ៧២៤ ៦៦៤ / ៤២៨ ៦៣៤<br>អ៊ីម៉ែល៖ efi@camnet.com.kh | អគារលេខ ៦០ ផ្លូវលេខ ៩២ ខណ្ឌ ដូនពេញ រាជធានី ភ្នំពេញ<br>គេហទំព័រ៖ www.mef.gov.kh |
| ៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ឯ. អ៊ុក រ៉ាប៊ុន<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖ (៨៥៥)២៣ ៧២៦ ១២៨<br>(៨៥៥)២៣ ៧២៦ ១២៩<br>ទូរសារ៖ (៨៥៥) ២៣ ២១៧ ៣២០<br>អ៊ីម៉ែល៖ info@maff.gov.kh | អាស័យដ្ឋាន៖ លេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ<br>គេហទំព័រ៖ http://www.maff.gov.kh/ |
| ៧ | ក្រសួងអភិវឌ្ឍន៍ជនបទ | **ឯ. ជា សុផារ៉ា**<br>កំរិតវប្បធម៌៖សញ្ញាបត្រមធ្យមសិក្សាបត្រ ភាគ ២<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទលេខៈ )៨៥៥ (២៣ ៨៨៤ ៥៣៩/<br>ទូរសារលេខៈ )៨៥៥ (២៣ ៩៩១ ១១៧<br>អ៊ីម៉ែល៖ គ្មានព័ត៌មាន | អាសយដ្ឋានៈ ផ្លូវលេខ ១៦៩)ឆេកូឆ្លូវ៉ាគី (កាច់ជ្រុង ផ្លូវ សហព័ន្ធរុស្ស៊ី,រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។<br>គេហទំព័រ៖ www.mrd.gov.kh |

| | | | | |
|---|---|---|---|---|
| ៨ | ក្រសួងពាណិជ្ជកម្ម | **ឯ. ស៊ុន ចាន់ថុល**<br>កំរិតវប្បធម៌៖គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖ 023 866 425<br>ទូរស័ព្ទ៖ 077 677 599<br>អ៊ីម៉ែល៖ moc.gov.kh@gmail.com | អាសយដ្ឋាន៖<br>ឡូតិ៍ លេខ១៩-៦១, វិថីក្រសួងពាណិជ្ជកម្ម )ផ្លូវលេខ១១៣បេ (, ភូមិទឹកថ្លា, សង្កាត់ទឹកថ្លា, ខណ្ឌសែនសុខ, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា<br>គេហទំព័រ៖ http://www.moc.gov.kh/ |
| ៩ | ក្រសួងឧស្សាហកម្ម | **ឯ. ចម ប្រសិទ្ធ**<br>កំរិតវប្បធម៌៖គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖ គ្មានព័ត៌មាន<br>អ៊ីម៉ែល៖ គ្មានព័ត៌មាន | អាសយដ្ឋាន៖ អគារលេខ ៤៥, មហាវិថីព្រះនរោត្តម, ភ្នំពេញ<br>គេហទំព័រ៖ http://www.mih.gov.kh/ |
| ១០ | ក្រសួងរ៉ែ និងថាមពល | **ឯ. ស៊ុយ សែម**<br>កំរិតវប្បធម៌៖គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖ (៨៥៥) ២៣ ២១៩ ៥៧៤<br>ទូរសារ៖ (៨៥៥) ២៣ ២១៩ ៥៨៤<br>អ៊ីម៉ែល៖ info@mme.gov.kh | អាសយដ្ឋាន៖ អគារលេខ ៧៩-៨៩, វិថីប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>គេហទំព័រ៖ http://www.mme.gov.kh/ |
| ១១ | ក្រសួងផែនការ | **ឯ. ឆាយ ថន**<br>កំរិតវប្បធម៌៖គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖ (៨៥៥)២៣ ២១២ ០៤៩<br>(៨៥៥)២៣ ៧២០ ៩០១<br>(៨៥៥)២៣ ២១២ ០៥៥<br>ទូរសារ៖ (៨៥៥) ២៣ ២១០ ៦៩៨<br>(៨៥៥)២៣ ២១០ ៩៤៤<br>អ៊ីម៉ែល៖ mop@cambodia.gov.kh | អាសយដ្ឋាន៖ អគារលេខ ៣៨៦ មហាវិថី ព្រះមុនីវង្ស រាជធានី ភ្នំពេញ<br>គេហទំព័រ៖ www.mop.gov.kh |

| | | | | |
|---|---|---|---|---|
| ១២ | ក្រសួងអប់រំ យុវជន និងកីឡា | **ឯ. ហង់ ជួនណារ៉ុន**<br>កំរិតវប្បធម៌៖ អនុបណ្ឌិតច្បាប់អន្តរជាតិ និងការប្រៀបធៀប<br>ទូរស័ព្ទ៖ (៨៥៥)១២ ៨៤៣ ៨៨៩<br>(៨៥៥)២៣ ២១៧ ២៥០ | ទូរស័ព្ទ/ទូរសារ៖ (៨៥៥ - ២៣) ២១៩ ២៨៥<br>អ៊ីមែល៖ info@moeys.gov.kh | អាសយដ្ឋាន៖ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>គេហទំព័រ៖ http://www.moeys.gov.kh/ |
| ១៣ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | **ឯ. វង សូត**<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ/ទូរសារ៖ គ្មានព័ត៌មាន<br>អ៊ីមែល៖ គ្មានព័ត៌មាន | អាសយដ្ឋាន៖ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>គេហទំព័រ៖ http://www.mosvy.gov.kh |
| ១៤ | ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | **ឯ. អ៊ឹម ឈុនលឹម**<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ/ទូរសារ៖ គ្មានព័ត៌មាន<br>អ៊ីមែល៖ គ្មានព័ត៌មាន | អាស័យដ្ឋាន៖ អគារលេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>គេហទំព័រ៖http://www.mlmupc.gov.kh |
| ១៥ | ក្រសួងបរិស្ថាន | **ឯ. សាយ សំអាល់**<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ/ទូរសារ៖ គ្មានព័ត៌មាន<br>អ៊ីមែល៖ គ្មានព័ត៌មាន | អាស័យដ្ឋាន៖ អគារលេខ ៤៨ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ<br>គេហទំព័រ៖ http://www.moe.gov.kh |
| ១៦ | ក្រសួងធនធានទឹក និងឧតុនិយម | **ឯ. លឹម គានហោ**<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន | ទូរស័ព្ទ/ទូរសារ៖ គ្មានព័ត៌មាន<br>អ៊ីមែល៖ គ្មានព័ត៌មាន | អាសយដ្ឋាន៖ វិថីតេជោដំឌិន រាជធានីភ្នំពេញ<br>គេហទំព័រ៖ http://www.mowram.gov.kh |

| | | | | |
|---|---|---|---|---|
| | | **ទូរស័ព្ទ៖ គ្មានព័ត៌មាន** | | |
| ១៧ | ក្រសួងព័ត៌មាន | **ឯ. ខៀវ កាញារីទ្ធ**<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖<br>+៨៥៥ ) -0(២៣ - ៤៣៧ ៦៩៤ / ៤៣០ ៦៩៧<br>+៨៥៥ ) -0(១២ -៨០៣ ៧៩១ / ៤០៨ ៣៧៧<br>អ៊ីម៉ែល៖<br>cabinet@information.gov.kh<br>kang_sarath@information.gov.kh | អគារលេខ ៦២ មហាវិថី ព្រះមុនីវង្ស រាជធានីភ្នំពេញ<br>គេហទំព័រ៖ www.information.gov.kh |
| ១៨ | ក្រសួងយុត្តិធម៌ | **ឯ. អង្គ វង្សវឌ្ឍានា**<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖ (៨៥៥)២៣ ៣៦០ ៣២៧<br>(៨៥៥)២៣ ៣៦៣២០៤<br>(៨៥៥)២៣ ៣៦០ ៤២១<br>(៨៥៥)២៣ ៣៦០ ៣២៩<br>(៨៥៥)២៣ ៣៦៤ ១១៩<br>ទូរសារ៖ (៨៥៥)២៣ ៣៦៤ ១១៩<br>អ៊ីម៉ែល៖ moj@cambodia.gov.kh | អាសយដ្ឋាន៖ អគារលេខ ២៤០ មហាវិថីសុធារស រាជធានីភ្នំពេញ<br>គេហទំព័រ: មិនមានព័ត៌មាន |
| ១៩ | ក្រសួងទំនាក់ទំនងជួយរដ្ឋសភា និង ព្រឹទ្ធសភា និង អធិការកិច្ច | **ជំ. ម៉ែន សំអន**<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន | ទូរស័ព្ទលេខ ) :855( 23 221 417<br>)855(23 213 571 | អាស័យដ្ឋាន៖ អគារលេខ ១២៦ ផ្លូវលេខ ៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ |

| | | | | |
|---|---|---|---|---|
| | | ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរសារលេខ ) :855(23 221 416<br>អ៊ីមែល : info@monasri.gov.kh<br>ទំព័រហ្វេសបុក: www.facebook.com/monasri.gov.kh | គេហទំព័រ : www.monasri.gov.kh |
| ២០ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | **ឯ. ប្រាក់ សុខុន**<br>កំរិតវប្បធម៌៖ សញ្ញាប័ត្រនៃមជ្ឈមណ្ឌលសិក្សាផ្នែកការទូត និងយុទ្ធសាស្ត្រ ក្រុងបារីស<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ :(៨៥៥) ២៣ ៧២៤ ៨០៩<br>(៨៥៥)២៣ ៤២៨ ២៤៦<br>អ៊ីម៉ែល :info@mptc.gov.kh | អាសយដ្ឋាន: ផ្លូវកែងលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>គេហទំព័រ: www.mptc.gov.kh |
| ២១ | ក្រសួងសុខាភិបាល | **ឯ. ម៉ម ប៊ុនហេង**<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖ (៨៥៥)២៣ ៤២៦ ៨៧៣<br>(៨៥៥)២៣ ៨៨០ ២៦១<br>(៨៥៥)២៣ ៨៨១ ៤០៥<br>(៨៥៥)២៣ ៨៨១ ៤០៩<br>ទូរសារ៖ (៨៥៥)២៣ ៤២៦ ៨៤១<br>(៨៥៥)២៣ ៧២២ ៨៧៣<br>(៨៥៥)២៣ ៨៨០ ២៦១ | អាសយដ្ឋាន៖ អគារលេខ ១៥១-១៥៣ មហាវិថីកម្ពុជាក្រោម រាជធានីភ្នំពេញ<br>គេហទំព័រ: មិនមានព័ត៌មាន (មិនដំណើរការ) |
| ២២ | ក្រសួងសាធារណការ និង ដឹកជញ្ជូន | **ឯ. ត្រាំ អ៊ីវតឹក**<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖ (៨៥៥)២៣ ៤២៧ ៨៤៥<br>អ៊ីម៉ែល៖ info@mpwt.gov.kh | អាសយដ្ឋាន៖ មហាវិថីព្រះនរោត្តមកែងផ្លូវ១០៦ រាជធានីភ្នំពេញ<br>គេហទំព័រ៖ http://www.mpwt.gov.kh |

| | | | | |
|---|---|---|---|---|
| ២៣ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | **ជំ. ភឿង សកុណា**<br>កំរិតវប្បធម៌៖ បណ្ឌិតផ្នែកវិទ្យាសាស្ត្រចំណីអាហារ<br>អ៊ីម៉ែល៖<br>phoeurng.sackona@mcfa.gov.kh,<br>sackonap@gmail.com<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖ +(៨៥៥(២៣ ២១៨ ១៤៨<br>អ៊ីម៉ែល៖ info@mcfa.gov.kh | អាស័យដ្ឋាន៖ មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>គេហទំព័រ៖ http://www.mcfa.gov.kh/ |
| ២៤ | ក្រសួងទេសចរណ៍ | **ឯ. ថោង ខុន**<br>កំរិតវប្បធម៌៖ បណ្ឌិតទស្សនៈវិជ្ជាផ្នែកគ្រប់គ្រងទេសចរណ៍<br>អ៊ីម៉ែល៖thongkhon@mot.gov.kh<br>thongkhon@gmail.com<br>ទូរស័ព្ទ៖(855)23 885 018<br>(855)12 808 254 | ទូរស័ព្ទ៖ (៨៥៥)២៣ ៨៨ ៤៩ ៧២<br>ទូរសារ៖ (៨៥៥)២៣ ៨៨ ៤៩ ៧៤<br>អ៊ីម៉ែល៖ admin@mot.gov.kh<br>Promotions@tourismcambodia.org | អាសយដ្ឋាន៖ អគារ ៣ក ផ្លូវ១៦៩, វាលវង់, ៧មករា, រាជធានីភ្នំពេញ<br>គេហទំព័រ៖ www.mot.gov.kh |
| ២៥ | ក្រសួងធម្មការ និងសាសនា | **ឯ. មិន ឃិន**<br>កំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ៖ (៨៥៥)២៣ ៧២២ ៦៩៩<br>(៨៥៥)១២ ៦១១ ៨៧៩<br>(៨៥៥)១២ ៣៧៨ ៣៧១<br>អ៊ីម៉ែល៖ គ្មានព័ត៌មាន | អាសយដ្ឋាន៖ អគារលេខ ៣៩៣ វិថីព្រះស៊ីសុវត្ថិ ជ័យជំនះ ដូនពេញ រាជធានីភ្នំពេញ<br>គេហទំព័រ៖ http://www.mocar.gov.kh |

| | | | | |
|---|---|---|---|---|
| ២៦ | ក្រសួងកិច្ចការនារី | **ជំ.អ៊ឹង កន្ថាផាវី**<br>គំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | **ទូរស័ព្ទ៖ )៨៥៥(២៣ ៤២៨ ៩៦៥**<br>**ទូរសារ៖ )៨៥៥(២៣ ៤២៦ ៥៣៩**<br>**អ៊ីម៉ែល៖**mwva@online.com.kh<br>youay.mwva@online.com.kh | **អាសយដ្ឋាន៖ អគារលេខ០៣ មហាវិថីរោត្តម រាជធានីភ្នំពេញ** |
| ២៧ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | **ឯ. អ៊ិត សំហេង**<br>គំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ: ០២៣ ៨៨ ៤៣ ៧៥<br>ទូរសារ: ០២៣ ៨៨ ៤៣ ៧៦<br>អ៊ីម៉ែល: info@mlvt.gov.kh | អាសយដ្ឋាន៖ អគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ<br>គេហទំព័រ៖ http://www.mlvt.gov.kh |
| ២៨ | ក្រសួងមុខងារសាធារណៈ | **ឯ. ពេជ្រ ប៊ុនធិន**<br>គំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ/ទូរសារ ៖ +៨៥៥-២៣-៨៦៦៥០១ | អាសយដ្ឋាន៖ផ្លូវវត្តអង្គតាម៉ិញភូមិគោកចំបក់ សង្កាត់ចោមចៅ ខ័ណ្ឌពោធិ៍សែនជ័យ<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>គេហទំព័រ៖ http://www.mcs.gov.kh |
| ២៩ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | **ឯ. ម៉ៅ ហាវណ្ណាល់**<br>គំរិតវប្បធម៌៖ គ្មានព័ត៌មាន<br>ទូរស័ព្ទ៖ គ្មានព័ត៌មាន | ទូរស័ព្ទ/ទូរសារ៖ (៨៥៥)២៣ ២១១ ០១៩<br>អ៊ីម៉ែល៖ sengvany@camnet.com.kh | អាសយដ្ឋាន៖ អគារ៦២ ផ្លូវនរោត្តម រាជធានីភ្នំពេញ<br>គេហទំព័រ៖ http://www.civilaviation.gov.kh/ |

- **អត្ថបទសារព័ត៌មានចុះផ្សាយអំពីរបាយការណ៍៖**

## ខុមហ្វ្រែលបង្ហាញលទ្ធផលនៃការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល

ដោយ សាន សែល

2016-02-23

http://www.rfa.org/khmer/news/politics/comfrel-reports-on-govt-work-02232016215804.html



គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា ខុមហ្វ្រែល (COMFREL) ធ្វើសន្និសីទបង្ហាញរបាយការណ៍វាយតម្លៃលើការអនុវត្តរបស់រដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥ កាលពីថ្ងៃទី២៣ កុម្ភៈ ឆ្នាំ២០១៦។

RFA/San Sel

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា ខុមហ្វ្រែល (COMFREL) រកឃើញថា ក្នុងឆ្នាំទី២ រដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥ បានសម្រេចការអនុវត្តន៍គោលនយោបាយចំនួន៦ចំណុច ហើយ៧ចំណុចទៀតសម្រេចបានខ្លះ ក្នុងចំណោមគោលនយោបាយទាំង៣៣ចំណុច។

អង្គការខុមហ្វ្រែល បានវាយតម្លៃលើការអនុវត្តរបស់រដ្ឋាភិបាល ផ្អែកទៅលើការដាក់ពិន្ទុរបស់ប្រជាពលរដ្ឋចំនួន៧៩៧នាក់ ក្នុង២៤រាជធានី ខេត្តដែលបានចូលរួមក្នុងវេទិកាម្ចាស់ឆ្នោត ព្រមទាំងផ្អែកទៅលើការវិភាគព័ត៌មានដែលបានមកពីរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយសង្គមស៊ីវិល និងរដ្ឋាភិបាល។

ជារួម ខុមហ្វ្រែលបង្ហាញថា ប្រជាពលរដ្ឋដែលបានចូលរួមផ្តល់ពិន្ទុមានប្រមាណ២៦ភាគរយពេញចិត្ត ប្រមាណ៦២ភាគរយពេញចិត្តខ្លះ និង១២ភាគរយមិនពេញចិត្តនូវការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាល។

របាយការណ៍របស់ខុមហ្វ្រែល រដ្ឋាភិបាលបានសម្រេចនូវការអនុវត្តន៍គោលនយោបាយការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ការបង្កើតគោលនយោបាយ ស្តីពីមុខរបរ និងការងារ កំណើនសេដ្ឋកិច្ច៧ភាគរយក្នុងមួយឆ្នាំ ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង គោលដៅនៃចំនួនទេសចរណ៍ពីក្រៅប្រទេស និងការកាត់បន្ថយភាពក្រីក្រក្នុងអត្រា១ភាគរយក្នុងមួយឆ្នាំ។

ចំណែកគោលនយោបាយដែលបានអនុវត្ត ឬសម្រេចបានខ្លះ រួមមានការនាំចេញអង្ករឲ្យបាន១លានតោននៅឆ្នាំ២០១៥ ការចុះបញ្ជីដីធ្លី ការបង្កើតគោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅឋាន ការផ្តល់សេវាទឹកស្អាតដល់ប្រជាជន ការពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ ការបន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ និងការរក្សាផ្ទៃនេសាទទឹកសាប។

លទ្ធផលនៃការអង្កេតរបស់ខុមហ្វ្រែល បញ្ជាក់ថា គោលនយោបាយចំនួន៣ ដែលរដ្ឋាភិបាលបានអនុវត្ត តែមិនអាចសម្រេចបានមានដូចជា ការរក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ ការដាក់ដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន និងការកែលម្អផ្លូវលំជនបទ។

នាយកប្រតិបត្តិនៃអង្គការខុមហ្វ្រែល លោក គល់ បញ្ញា ថ្លែងថា នៅក្នុងរបាយការណ៍មិនបានបង្ហាញពីមូលហេតុនៃការអនុវត្តន៍មិនបានសម្រេចគោលនយោបាយរបស់រដ្ឋាភិបាល។ លោកឆ្លល់ថា រដ្ឋាភិបាលនៅឆ្នាំ២០១៥ មានខ្ទង់ចំណាយសម្រាប់គ្រប់វិស័យ ក៏ប៉ុន្តែមិនអាចសម្រេចបានតាមផែនការចំណាយ៖ *«(មូលហេតុ) សម្រេចបានខ្លះៗ មិនពេញ។ (ការអនុវត្តន៍គោលនយោបាយ) ខ្ញុំមិនអាចពន្យល់បាន។ ក៏ប៉ុន្តែថវិកាជាតិ ដូចជាមានទេ ទៅក្នុងវិស័យដែលរដ្ឋាភិបាលមិនអាចអនុវត្តបាន ក៏ប៉ុន្តែមិនដឹងមូលហេតុអ្វីនៅក្រោយហ្នឹង»*។

គម្រោងថវិកាជាតិឆ្នាំ២០១៥ មានចំនួនជិត៤ពាន់ (៣.៧៥៨) លានដុល្លារសហរដ្ឋអាមេរិក។ ក្នុងថវិកាជាតិសរុប រដ្ឋាភិបាលគ្រោងចំណាយលើវិស័យសង្គមកិច្ចចំនួន២៧,៨២ភាគរយ ចំណាយលើវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈចំនួន១៦,២៤ភាគរយ ចំណាយលើវិស័យរដ្ឋបាលទូទៅចំនួន ១១,១៨ភាគរយ។

កម្មវិធីគោលនយោបាយរបស់រដ្ឋាភិបាលនីតិកាលទី៥ ផ្តោតលើវិស័យ៤សំខាន់ៗ មានគោលនយោបាយការការពារជាតិសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គោលនយោបាយការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងគោលនយោបាយការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច។

អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី លោក ផៃ ស៊ីផាន មានមោទនភាពចំពោះការសម្រេចនូវការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ ការប្រមូលពន្ធ ការកាត់បន្ថយប្រព័ន្ធការិយាធិបតេយ្យជាដើម។

ឆ្លើយតបនឹងភាពបរាជ័យនៃការអនុវត្តន៍គោលនយោបាយមួយចំនួន លោក ផៃ ស៊ីផាន បញ្ជាក់ថា គ្មានរដ្ឋាភិបាលណាមួយ ដែលអាចសម្រេចបានទាំងស្រុងទេ៖ *«គ្មានរដ្ឋាភិបាលណាមួយក្នុងលោកអាចធ្វើបាន ១០០ភាគរយនោះទេ។ ក៏ប៉ុន្តែជាទូទៅ យើងធ្វើបាន៧០ ទៅ៨០ភាគរយនៃអ្វីដែលបានគ្រោងនៅក្នុងគោលនយោបាយចតុកោណ។ យើងស្ថិតនៅក្នុងអ្វីដែលជាកំណែទម្រង់»*។

យ៉ាងណាក៏ដោយ លោក ផៃ ស៊ីផាន មានប្រសាសន៍ថា រដ្ឋាភិបាលមិនទាន់មានរបាយការណ៍ ស្តីពីការវាយតម្លៃលើការអនុវត្តន៍គោលនយោបាយនៅឡើយទេ។ លោកថា ការវាយតម្លៃនេះនឹងធ្វើនៅឆ្នាំទីបីនៃនីតិកាលទី៥៕

# Voters give government mixed marks

Wed, 24 February 2016

Vong Sokheng

http://www.phnompenhpost.com/national/voters-give-government-mixed-marks



Prime Minister Hun Sen raises his voting ballot and poses for the media at a polling station on election day in 2013. Hong Menea

Just a quarter of Cambodian voters are fully satisfied with the government's efforts to deliver on its promises thus far in the fifth mandate, though more than half rated themselves partly so, according to the results of a nationwide survey conducted by election watchdog Comfrel.

In a series of focus groups held last year across 24 provinces, Comfrel assessed the level of satisfaction voters had with the government's ability to deliver on 16 planks of its election platform – from maintaining 7 per cent economic growth to creating a transportation policy to building schools.

The survey of nearly 800 voters found that 26 per cent of people were completely satisfied with the government's efforts, while 62 per cent were partly satisfied and 12 per cent were not satisfied.

—According to the numbers, people are still not satisfied with the government's implementation of their political platform," Comfrel executive director Koul Panha said at the launch of the results yesterday. —This is the opinion of the voters and we wanted to encourage the voters to have influence on the government."

Using data gathered from NGOs, media agencies and national institutions, Comfrel also declared yesterday that the government has so far fulfilled six of the 16 pledges, including a 1 per cent annual reduction in poverty, a halt to the issuance of economic land concessions and the creation of a national jobs policy.

However, other initiatives relating to such things as supplying of electricity to villages, land title registration and a national housing policy had only been partly fulfilled.

Ruling Cambodian People's Party spokesman Sok Eysan defended his party yesterday, saying that the government would make good on its promises over time. —The government has been working step by step in accordance with its strategy plan, and some factors depend on human resources and technical issues that cannot be fully fulfilled in accordance with our desire."

Breaking down the survey by its four broader components, the percentage of satisfaction in each sub-section more or less mirrored the final outcome. The components included decentralisation, strengthening law and order and curbing corruption; economic development; education, health and labour; and defence.

Kem Monovithya, deputy public affairs head for the opposition CNRP, said yesterday that little had changed in the current mandate from the CPP's political platforms of the past. ―You get the same products, except now they're branded differently and more aggressively," she said.

Voters want change related to social justice and inclusive development, she added, and her party would address this via judicial reforms, clamping down on corruption and modernising the agriculture sector.

Ou Virak, founder of the think tank Future Forum, said the government lacked the political will to engage in substantial reforms, particularly of the courts, which are ―weak and corrupted".

Additional reporting by Daniel de Carteret

# Government Achieved Less Than 40 Percent of 2015 Policy Targets

**BY KANG SOTHEAR | FEBRUARY 24, 2016**

HTTPS://WWW.CAMBODIADAILY.COM/NEWS/GOVERNMENT-ACHIEVED-LESS-THAN-40-PERCENT-OF-2015-POLICY-TARGETS-108903/

The government fully achieved 6 out of 16 measureable policy targets last year, according to a re-port re¬leased by the Committee for Free and Fair Elections (Com¬frel) on Tuesday.

The fulfilled targets included 7 percent annual economic growth, 1 percent poverty reduction, an increase in foreign tourists and the creation of a national jobs policy, according to Comfrel.

Targets related to access to running water, electrification in villages and schooling had only been —partly ful¬filled," while the remaining three platform promises were unmet—and unlikely to be achieved anytime soon—said a state¬ment released with the report.

—These include maintenance of ex¬isting forest cover and implementation of retirement allowance in the pri¬vate sector and improvement of ru¬ral roads," the statement said.

The study was based on data from NGOs, news outlets and state institutions, the state¬ment said.

—A policy is considered failed if it is less than 20 percent complete, partly fulfilled if up to 50 percent complete, and fulfilled if almost 100 percent is complete," said Koul Panha, director of Comfrel.

For 17 targets that were more subjective—such as anti-corruption efforts—the organization conducted a nationwide survey of 797 potential voters. Only 26 percent were fully satisfied with the government's work on those targets, while 62 percent were partly satisfied and 12 percent not satisfied.

Tith Sothea, a spokesman for the Council of Ministers, said it was important to look at the broader successes and reforms overseen by the government.

—Economic growth is a very big success achieved with political stability and sustainable development," he said.

However, opposition lawmaker Son Chhay said some of the government's achievements, par¬tic-ularly poverty reduction, were questionable.

—People may be able to earn a bit more money, but many people are in debt," he said.

(Additional Reporting By Tej Parikh)

# អង្គការខុមហ្វ្រែលថាពលរដ្ឋនៅភ្នំពេញដែលពេញចិត្តការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាលមានការកើនឡើង

http://vodhotnews.com/2016/02/gov-platform-implementation/

ដោយ កញ្ញា ខាន់ លក្ខិណា | ថ្ងៃពុធ ទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦




សន្និសីទបង្ហាញរបាយការណ៍ស្តីពីការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផលនៃការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល

អង្គការឃ្លាំមើលការបោះឆ្នោតនៅកម្ពុជាហៅកាត់ថាខុមហ្វ្រែលបានឲ្យដឹងថា របាយការណ៍ឃ្លាំមើល និងការផ្តល់ពិន្ទុពីប្រជាពលរដ្ឋបង្ហាញថា ពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញ ដែលពេញចិត្តនឹងការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាបាលកើនឡើង៥% ក្នុងឆ្នាំ២០១៥ បើធៀបនឹងឆ្នាំ២០១៤។

របាយការណ៍របស់អង្គការខុមហ្វ្រែល ដែលត្រូវបានផ្សព្វផ្សាយកាលពីថ្ងៃអង្គារម្សិលមិញបង្ហាញថា បើប្រៀបធៀបលទ្ធផលផ្តល់ពិន្ទុឆ្នាំ២០១៤ និងឆ្នាំ២០១៥នៅរាជធានីភ្នំពេញ ដោយប្រើវិធីសាស្ត្រដូចគ្នានោះ ចំនួនប្រជាពលរដ្ឋមិនពេញចិត្ត នឹងការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាលធ្លាក់ចុះពី៥៥% នៅក្នុងឆ្នាំ២០១៤មកនៅត្រឹម៥០% ខណៈចំនួនពលរដ្ឋដែលពេញចិត្តនឹងការអនុវត្តន៍របស់រដ្ឋាភិបាលនៅដដែល គឺ២០%។ របាយការណ៍បន្តថា ប្រជាពលរដ្ឋដែលផ្តល់ពិន្ទុនៅរាជធានីភ្នំពេញចំនួន៥% បានប្រែប្រួលពីមិនពេញចិត្តទៅពេញចិត្តខ្លះ។

របាយការណ៍ដដែលឲ្យដឹងដែរថា ក្នុងឆ្នាំទី២នៃរដ្ឋាភិបាលនីតិកាលទី៥ ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានសម្រេចពេញលេញនូវការអនុវត្តន៍គោលនយោបាយបានតែចំនួន៦នៃ១៦ចំណុច ឬស្មើនឹង៣៧,៥%នៃគោលនយោបាយដែលមានសូនាករច្បាស់លាស់ ដែលមានដូចជា កំណើនសេដ្ឋកិច្ចបាន៧% ក្នុងមួយឆ្នាំ ការកាត់បន្ថយភាពក្រីក្រក្នុង១%ក្នុងមួយឆ្នាំ ការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង គោលដៅនៃចំនួនទេសចរណ៍ពីក្រៅប្រទេស និងការបង្កើតគោលនយោបាយជាតិស្តីពីមុខរបប និងការងារ។

របាយការណ៍បន្តថា គោលនយោបាយ៧ចំណុចដែលរដ្ឋាភិបាលអនុវត្តសម្រេចបានខ្លះរួមមាន ការរក្សាផ្ទៃទឹកនេសាទទឹកសាប ការចុះបញ្ជីដីធ្លី ការកសាងគោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅស្ថាន ប្រជាជនទទួលសេវាទឹកស្អាត ពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ បន្តកសាងអនុវិទ្យាឲ្យបានគ្រប់ឃុំ និងការនាំចេញអង្ករឲ្យបាន១លានតោនក្នុងឆ្នាំ២០១៥។ ឯគោលនយោបាយចំនួន៣ទៀត រដ្ឋាភិបាលបានអនុវត្តតែមិនអាចសម្រេចបាន ឬបានតិចតួច។

សម្រាប់ការផ្តល់ពិន្ទុលើគោលនយោបាយ ដែលមិនមានសូចនាករច្បាស់លាស់ ប្រជាពលរដ្ឋ២៦%ពេញចិត្តប្រមាណ៦២%ពេញចិត្តខ្លះ និងប្រមាណ១២%មិនពេញចិត្តនឹងលទ្ធផលនៃការអនុវត្តន៍គោលនយោបាយទាំងនោះ។

នាយកប្រតិបត្តិអង្គការខុមហ្វ្រែល លោក គល់ បញ្ញា ឲ្យដឹងថា របាយការណ៍ស្តីពីការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផលនៃការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាលត្រូវបានធ្វើឡើង ដោយផ្អែកលើការវិភាគព័ត៌មាន ឬទិន្នន័យដែលមានស្រាប់មកពីប្រព័ន្ធផ្សព្វផ្សាយ និងអង្គការជាតិ អន្តរជាតិ ព្រមទាំងការផ្តល់ពិន្ទុពីប្រជាពលរដ្ឋ៧៩៧នាក់ ក្នុង២៤រាជធានីខេត្ត រយៈពេល៩ខែ៕

# រដ្ឋាភិបាល ច្រានចោលរបាយការណ៍ខុមហ្វ្រែល ដែលថា ការអនុវត្តន៍កម្មវិធីគោលនយោបាយរដ្ឋាភិបាលគ្មានសូចនាករច្បាស់លាស់

24/02/201624/02/2016

http://km.rfi.fr/cambofia/comfrel-24-02-2016



លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីRFI/ Siv Channa

មន្ត្រីរដ្ឋាភិបាល នៅថ្ងៃពុធនេះ បានច្រានចោលរបាយការណ៍របស់គណៈកម្មធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា(ខុមហ្វ្រែល) ដែលថាការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជា នៅឆ្នាំទី២ នីតិកាលទី៥ មានសូចនាករមិនច្បាស់លាស់ និងសម្រេចបានចំណុចគោលនយោបាយ ត្រឹមតែ៦ចំណុចប៉ុណ្ណោះ នៅក្នុងចំណោមគោលនយោបាយ១៦ចំណុច។ រដ្ឋាភិបាលបានចាត់ទុកថា របាយការណ៍របស់ខុមហ្វ្រែល គ្មានសុចរិតភាព និងឯករាជ្យភាព។

អត្ថបទដោយ៖ សរ ពិសី

អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី លោក ផៃ ស៊ីផាន នៅថ្ងៃទី ២៤ កុម្ភៈ បានទាត់ចោលនូវរបាយការណ៍របស់គណៈកម្មាធិការជាតិដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ដែលបានលើកឡើងថា ការអនុវត្តន៍កម្មវិធីគោលនយោបាយរបស់រដ្ឋាភិបាល នាឆ្នាំទី២ នីតិកាលទី៥ គ្មានសូចនាករច្បាស់លាស់ និងសម្រេចបានតែគោលនយោបាយតែ៦ចំណុចលើគោលនយោបាយចំនួន១៦ចំណុច ប្រមាណជា ៣៧,៥% តែប៉ុណ្ណោះ។

បើតាមរបាយការណ៍ គោលនយោបាយទាំង៦ចំណុច ដែលរដ្ឋាភិបាលបានសម្រេចនោះ រួមមាន៖ ទី១ កំណើនសេដ្ឋកិច្ចចំនួន៧%ក្នុងមួយឆ្នាំ ទី២៖ ការកាត់បន្ថយភាពក្រីក្រក្នុងអត្រា១%ក្នុងមួយឆ្នាំ ទី៣៖ ការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ទី៤៖ ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ទី៥៖ គោលដៅនៃចំនួនទេសចរណ៍ពីក្រៅប្រទេស និងទី៦៖ ការបង្កើតគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ។

យ៉ាងណាក៏ដោយ អ្នកនាំពាក្យរូបនេះបានឲ្យដឹងថា របាយការណ៍របស់ខុមហ្វ្រែល គឺគ្មានសុចរិតភាព និងគ្មានឯកទេសច្បាស់លាស់ ក្នុងការងាររដ្ឋាភិបាលនោះទេ ព្រោះថាខុមហ្វ្រែលគ្រាន់តែជាអង្គការក្រៅរដ្ឋាភិបាលមួយប៉ុណ្ណោះ។

សូមរំឭកជូនថា កាលពីថ្ងៃទី២៣កុម្ភៈម្សិលមិញនេះ អង្គការខុមហ្វ្រែលបានចេញរបាយការណ៍មួយ ស្ដីពីការឃ្លាំមើល និងការផ្ដល់ពិន្ទុលើការឃ្លាំមើល និងការផ្ដល់ពិន្ទុលើលទ្ធផលនៃការបំពេញ និងការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាលនិតិកាលទី៥ ឆ្នាំទី២ ដោយបញ្ជាក់ថា ក្នុងចំណោមគោលនយោបាយ ១៦ ចំណុច រដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា សម្រេចបានគោលនយោបាយតែ៦ចំណុចប៉ុណ្ណោះ។

ខណៈដែលគោលនយោបាយចំនួន៣ទៀត ដែលរដ្ឋាភិបាលបានអនុវត្តមិនអាចសម្រេចបាន ឬបានតិចតួចតាមការសន្យារបស់ខ្លួនមានដូចជា ទី១៖ ការរក្សាផ្ទៃដីដែលគ្របដណ្ដប់ដោយព្រៃឈើ ទី២៖ ការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន និងទី៣៖ ការកែលម្អផ្លូវលំជនបទ។

ទោះបីជាយ៉ាងណាក៏ដោយ បើប្រៀបធៀបនឹងលទ្ធផលផ្ដល់ពិន្ទុឆ្នាំ២០១៤ និងឆ្នាំ២០១៥ នៅរាជធានីភ្នំពេញ ក្នុងឆ្នាំ២០១៥ ចំនួនប្រជាពលរដ្ឋមិនពេញចិត្តនឹងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលធ្លាក់ចុះពី៥៥% ក្នុងឆ្នាំ២០១៤ មកត្រឹម៥០% ក្នុងឆ្នាំ២០១៥។ ផ្ទុយមកវិញ ចំនួនប្រជាពលរដ្ឋពេញចិត្តកើនឡើងពី៣៥% ទៅ៤០%។

បើតាមខុមហ្វ្រែល របាយការណ៍ស្ដីពីការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាលនេះ បានធ្វើឡើងដោយផ្អែកលើការវិភាគព័ត៌មាន ឬទិន្នន័យដែលមានស្រាប់មកពីប្រព័ន្ធផ្សព្វផ្សាយ របាយការណ៍បឋមរបស់អង្គការជាតិ និងអន្តរជាតិ សារព័ត៌មានជាតិ និងអន្តរជាតិ ស្ថាប័ននានា។ ក៏ដូចជាតាមរយៈវេទិកាម្ចាស់ឆ្នោតដែលត្រូវបានរៀបចំឡើងនៅក្នុងរាជធានីខេត្តចំនួន២៤៕

**ផលិតដោយ៖**

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)**

http://www.comfrel.org

ខ្លឹមសារក្នុងរបាយការណ៍ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ម្ចាស់ជំនួយឡើយ។

រូបថតក្របមុខ៖ ដកស្រង់ពីគេហទំព័រ

**ឧបត្ថម្ភដោយ៖**